ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- ការងារប្រមូលឯកសារ
- ការជំនុំជម្រះឧក្រិដ្ឋកម្មបំផ្លាញសម្បត្តិវប្បធម៌

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៨០ ខែសីហា ឆ្នាំ២០០៦

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ៨០ ខែសីហា ឆ្នាំ២០០៦

## មាតិកា


◆ សំបុត្រ : ការផ្សារប្រមូលឯកសារ ....................................១

### ផ្នែកឯកសារ

◆ ឈឹម សំណាង : តំណាងរាស្ត្រមណ្ឌលតាកែវ ..........................៦

◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១ ...............៨

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ គុកខ្មែរក្រហម ...........................................................១០

◆ ទីតាំងសោកនាដកម្ម.......................................................១៧

◆ រឿងរ៉ាវដែលមិនចេះសាបសូន្យ........................................១៩

◆ កុមារសន្តិសុខនៅមន្ទីរស-២១ ........................................២៤

◆ សម្របខ្លួនក្នុងបដិវត្តន៍.....................................................២៦

◆ ចំណាងឧក្រិដ្ឋកម្ម មន្ទីរសន្តិសុខភូមិភាគនិរតី ........................២៩

### ផ្នែកច្បាប់

◆ ការជំនុំជម្រះឧក្រិដ្ឋកម្មបំផ្លាញសម្បត្តិវប្បធម៌........................៣៧

### វេទិកាពិភាក្សាសាធារណៈ

◆ ការធានាភាពមិនលម្អៀងនិងឯករាជ្យភាពនៃក្រុមចៅក្រម .........៤៥

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ បាត់បងប្អូនពីរនៅក្នុងរបបខ្មែរក្រហម ..................................៥២







## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ :** ប៊ុន ពីរ៉ែន, ស៊ីវ សាវីណា, ផេង ពង្សរ៉ាស៊ី, ញាណ សុជាតិ, អៀប ឌុច, អៀ ម៉េងទ្រី, សារ៉ា ជេ. ថមម៉ាស, ស៊ូស្សាណា លីនតុន **អ្នកនិពន្ធ និងស្រាវជ្រាវ :** លី សុផល, ណយ សុផារី, ឌី ខាំបូលី **អ្នកបកប្រែ :** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ :** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ :** គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ :** រ័ត្ន តារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ការងារប្រមូលឯកសារ

## បទសម្ភាសន៍ជាមួយនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

***១) អស់រយៈពេលជាច្រើនឆ្នាំ មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមែប្រមូលបាននូវឯកសារនិងរឿងរ៉ាវរាប់ពាន់រាប់ម៉ឺនច្បាប់ ដែលនិយាយអំពីអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ តើលោកជួបការលំបាកបញ្ហាអ្វីខ្លះក្នុងពេលប្រមែប្រមូលឯកសារទាំងនោះ?***

*មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្តើមបើកការិយាល័យស្រាវជ្រាវដំបូងនៅក្នុងសាកលវិទ្យាល័យយែលនៅក្នុងឆ្នាំ១៩៩៥ ។ ថវិការបស់យើងសម្រាប់ការប្រមែប្រមូលឯកសារគឺមានបន្តិចតួចបំផុត ។ ពីរឆ្នាំក្រោយមក នៅពេលដែលយើងបានក្លាយទៅជាមជ្ឈមណ្ឌលស្រាវជ្រាវកម្ពុជាឯករាជ្យ យើងមានតែឯកសារ ១.៧០០ទំព័រនិងមានកម្មវិធីបញ្ចូលទិន្នន័យមួយប៉ុណ្ណោះ ។*

*យើងខិតខំប្រឹងប្រែងនិងពង្រីកទំនាក់ទំនងយ៉ាងល្អជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាដោយបានកសាងនូវកេរ្តិ៍ឈ្មោះល្អៗសម្រាប់កម្មវត្ថុមួយនេះ ។ ដូច្នេះហើយទើបយើងអាចទទួលបាននូវឯកសារជាច្រើន ដូចជាឯកសារប្រវត្តិរូបអតីតកម្មាភិបាលខ្មែរក្រហមពីប្រភពផ្សេងៗដូចជាមកពីរដ្ឋាភិបាលនានា ពីបុគ្គលទាំងឡាយ និងពីស្ថាប័នផ្សេងៗជាច្រើនទៀត ។ សព្វថ្ងៃនេះយើងមានឯកសារជាង៦សែន ហើយជាក់ស្តែងឯកសារទាំងនេះគឺសុទ្ធតែជាឯកសារដើម លើកលែងតែឯកសាររបស់លោក ដេវីដហក ជាសកម្មជនសិទ្ធិមនុស្សជនជាតិអាមេរិក ដែលបានមកកាន់ប្រទេសកម្ពុជាមួយរយៈពេលខ្លី បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបណ្តេញចេញពីអំណាច ។ យើងតែងតែមានជំនឿលើប្រភពឯកសាររបស់យើង និងមានការប្រុងប្រយ័ត្នក្នុងការថែរក្សាឯកសារទាំងនេះដែលជួយពង្រីកការប្រមែប្រមូលឯកសាររបស់យើងជាច្រើនឆ្នាំឲ្យកាន់តែរីកធំធាត់ឡើងៗ ។*

*ប្រជាពលរដ្ឋកម្ពុជាគឺជាប្រជាពលរដ្ឋដែលមានសន្តានចិត្តល្អក្នុងការចែករំលែកឯកសារដល់យើង ជាពិសេសគឺរូបថតដែលថតមុននិងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងកំពុងតែបន្តប្រមែប្រមូលព័ត៌មានសំខាន់ទីពីរ គឺតាមរយៈការធ្វើបទសម្ភាសន៍ ។*

*ការប្រមែប្រមូលឯកសារពីប្រទេសក្រៅមានការលំបាកបន្តិច ។ ប្រជាពលរដ្ឋដែលរស់នៅក្រៅប្រទេសមួយចំនួនដែលព្យាយាមលក់ឯកសារស្តីពីរបបកម្ពុជាប្រជាធិបតេយ្យមកយើង បានផ្តល់ឯកសារទាំងនោះមកឲ្យយើង ក៏ប៉ុន្តែយើងមិនបានបង់ថ្លៃឯកសារទាំងនោះឡើយ ។ ប្រសិនបើអង្គការឬកន្លែងផ្សេងទៀតក៏មិនបានចំណាយប្រាក់ទិញឯកសារទាំងនេះ អ្នកដែលរក្សាទុកឯកសារនឹងយល់ថា ការបន្តរក្សាទុកឯកសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនទទួលបាននូវប្រាក់រង្វាន់អ្វីឡើយ ។ យើងសង្ឃឹមថាអ្នកទាំងនោះនឹងធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ ហើយផ្តល់ឯកសារទាំងនោះមកមជ្ឈមណ្ឌលឯកសារកម្ពុជា ឬអង្គការផ្សេងមួយទៀតដែលមានភារៈការពារនិងថែរក្សាឯកសារទាំងនេះ ។*

*អង្គការមួយចំនួនមានកំហុសឆ្គងដោយបណ្តោយនិងយកឯកសារដើមចេញពីប្រទេសកម្ពុជា ។ ការយកឯកសារដើមត្រឡប់មកវិញ មិនមែនជាការងាយស្រួលនោះទេ ។ យើងកំពុងតែជំរុញឲ្យបុគ្គលក្រុមហ៊ុន គ្រឹះស្ថានសិក្សានានា និងរដ្ឋាភិបាលប្រគល់ឯកសារដើមស្តីពីរបបកម្ពុជាប្រជាធិបតេយ្យមកឲ្យកម្ពុជាដែលជាម្ចាស់កម្មសិទ្ធិឯកសារដើម ។ យើងទទួលបានជោគជ័យនៅក្នុងការងារប្រមែប្រមូលឯកសារនេះ ហើយយើងនឹងបន្តការងារប្រមែប្រមូលឯកសារទាំងនេះត្រឡប់មកកម្ពុជាវិញ ។*

***២) ជាមួយការចងក្រងនូវឯកសារទាក់ទងនឹងឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ លោកកំពុងតែធ្វើគម្រោងស្តីពីការអប់រំ និងការផ្សព្វផ្សាយជាសាធារណៈទៅកាន់តំបន់ឆ្ងាយៗ រួមទាំងការផលិតខ្សែភាពយន្តឯកសារ កម្មវិធីវិទ្យុ និងការដាក់តាំងពិព័រណ៍ជាដើម ។ តើលោកមានអារម្មណ៍សប្បាយរីករាយយ៉ាងដូចម្តេច នៅពេលទៅជួបប្រជាពលរដ្ឋកម្ពុជាជាក្រុមតូចផ្សេងៗគ្នានោះ?***

*ខ្ញុំមានការពេញចិត្តនឹងសមត្ថភាពបុគ្គលិកទាំងអស់របស់*

យើងក្នុងការចុះទៅជួបអ្នកដែលនៅរស់រានពីរបបកម្ពុជាប្រជាធិបតេយ្យនៅតាមមូលដ្ឋាន ។ គាត់ទទួលស្គាល់ការងាររបស់យើងថែមទាំងសរសើរការងារដែលយើងកំពុងតែធ្វើទៀតផង ។ ជារៀងរាល់ខែ យើងតែងទទួលសំបុត្រសរសើរ និងសំបុត្រថ្លែងអំណរគុណពីសំណាក់ប្រជាពលរដ្ឋកម្ពុជាទាំងនៅក្នុងស្រុកនិងក្រៅប្រទេស ។ ម្យ៉ាងវិញទៀត ខ្ញុំយល់ឃើញថាក្នុងខណៈពេលដែលដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់កំពុងរិតជិតមកដល់ការចាប់អារម្មណ៍របស់ប្រជាពលរដ្ឋកម្ពុជាទាំងក្នុងនិងក្រៅប្រទេសកើនឡើងជារៀងរាល់ថ្ងៃ ទាំងនៅក្នុងដំណើរការច្បាប់ និងការចែករំលែកនូវបទពិសោធន៍របស់ខ្លួនក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ពិតប្រាកដណាស់ មានជនមួយចំនួនមិនពេញចិត្តនឹងកិច្ចការដែលយើងកំពុងតែធ្វើនោះទេ ។ ទាំងអ្នកនៅក្នុងប្រទេសនិងក្រៅប្រទេសរិះគន់យ៉ាងខ្លាំងក្លាទៅលើកិច្ចការរបស់យើង ។ យើងធ្លាប់បានទទួលនូវការរិះគន់អនាមិកយ៉ាងច្រើនពីសំណាក់អ្នកទាំងនោះ ។ បើទោះបីជាយើងទទួលការគំរាមកំហែងជាច្រើនលើកយ៉ាងណាក៏ដោយ ក៏យើងមិនទុកឲ្យការគំរាមកំហែងនេះបញ្ឈប់កិច្ចការរបស់យើងបានឡើយ ។

អ្វីដែលខ្ញុំកំពុងគិតនៅក្នុងពេលបច្ចុប្បន្ននេះ គឺកូនខ្មែរជំនាន់ក្រោយដែលរីកធំធាត់ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។ ឪពុកម្តាយជាច្រើននិយាយប្រាប់កូនៗរបស់ខ្លួនអំពីជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាច្រើនលើកដែរ ជាពិសេសគឺការឈឺចាប់របស់ខ្លួនតែម្តង ។ ក៏ប៉ុន្តែកូនៗរបស់គាត់មិនចាប់អារម្មណ៍និងមិនជឿថាគាត់ជួបការស្រេកឃ្លាន ការសម្លាប់មនុស្សជាច្រើន ឬមនុស្សជាច្រើនបានស្លាប់នោះទេ ។

នេះគឺជាបញ្ហាដែលយើងកំពុងតែដោះស្រាយតាមមធ្យោ-បាយពីរយ៉ាង ។ មធ្យោបាយទីមួយ មជ្ឈមណ្ឌលឯកសារកម្ពុជាមានសិស្សនិងនិស្សិតស្ម័គ្រចិត្តចេញទៅកាន់បណ្តាខេត្ត ដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ តុលាការ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ យើងបណ្តុះបណ្តាល និងផ្តល់ឱកាសឲ្យសិស្សនិងនិស្សិតទាំងនោះជួបជាមួយអ្នកស្រុកអ្នកភូមិដោយផ្ទាល់ ព្រមទាំងថតសម្លេងសម្ភាសន៍របស់ខ្លួន ។ សិស្សនិងនិស្សិតទាំងនេះមានអារម្មណ៍រំភើបរីករាយយ៉ាងខ្លាំងនូវអ្វីដែលខ្លួនកំពុងតែធ្វើ ហើយយើងអាចមើលឃើញការចាប់អារម្មណ៍របស់សិស្សនិងនិស្សិតខ្មែរចំពោះប្រវត្តិសាស្ត្ររបស់ខ្លួនដែលកំពុងតែរីកចម្រើនទៅមុខពីមួយថ្ងៃទៅមួយថ្ងៃ ។

មធ្យោបាយទីពីរ ថ្មីៗនេះយើងទើបតែបញ្ចប់ការសរសេរអត្ថបទប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យសម្រាប់សិស្សានុសិស្សថ្នាក់វិទ្យាល័យសិក្សាស្វែងយល់ក្រោមការជួយឧបត្ថម្ភពីទេយ្យទានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ ។ នេះគឺជាអត្ថបទដែលសរសេរឡើងដោយបញ្ញវ័ន្តកម្ពុជាម្នាក់សម្រាប់ក្រុមសិស្ស ហើយយើងយល់ថាអត្ថបទនេះមានសារសំខាន់ខ្លាំងណាស់ ។ សៀវភៅសិក្សាបច្ចុប្បន្ននេះពុំមាននិយាយអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទាល់តែសោះ សូម្បីតែមួយឃ្លាក៏គ្មានដែរ ។ ម្យ៉ាងវិញទៀត លោកគ្រូអ្នកគ្រូពុំមានឯកសារពិគ្រោះគ្រប់គ្រាន់ ដែលធ្វើឲ្យគាត់មិនអាចឆ្លើយសំណួរនៅពេលដែលសិស្សចង់ដឹងចង់ឮអំពីប្រវត្តិសាស្ត្រនេះ ។ យើងសង្ឃឹមថា អត្ថបទនេះនឹងបោះពុម្ពផ្សព្វផ្សាយនៅក្នុងឆ្នាំនេះ ។

**៣) បន្ទាប់ពីការអាននូវបទសម្ភាសន៍មួយចំនួនតាមប្រព័ន្ធទិន្នន័យកុំព្យូទ័រ បង្ហាញថាប្រជាពលរដ្ឋកម្ពុជាមិនចាំឈ្មោះ កាលបរិច្ឆេទ និងពេលវេលា ឬមានការស្ទាក់ស្ទើរក្នុងការពិភាក្សាបញ្ហាមួយចំនួន ។ តើមែនដែរឬទេ?**

អ្នកគិតបែបនេះគឺជាការត្រឹមត្រូវណាស់ ។ ប្រជាពលរដ្ឋកម្ពុជាពិបាកនឹងចងចាំឲ្យបានច្បាស់លាស់នូវព្រឹត្តិការណ៍ដែលបានកើតឡើងកាលពី៣០ឆ្នាំមុន ហើយរឿងរ៉ាវលម្អិតទាំងឡាយក៏បាត់បង់តាំងពីពេលនោះមកដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ អារម្មណ៍របស់គាត់នៅតែដក់ជាប់នឹងព្រឹត្តិការណ៍ ហើយរឿងរ៉ាវជីវិតរបស់ជនរងគ្រោះដោយសាររបបកម្ពុជាប្រជាធិបតេយ្យគឺមានលក្ខណៈស៊ីសង្វាក់គ្នា ។

នៅពេលដែលជនរងគ្រោះស្ទាក់ស្ទើរមិនចង់ពិភាក្សារឿងរ៉ាវពិត យើងអាចចាប់ផ្តើមទិសដៅមួយ ក្នុងចំណោមទិសដៅពីររបស់យើងដោយអាស្រ័យទៅលើជនរងគ្រោះនិងស្ថានភាព ។ នៅតំបន់ខ្លះទៀត ប្រសិនបើជនរងគ្រោះមានអារម្មណ៍ឈឺចាប់ខ្លាំង ឬមិនចង់ពិភាក្សាអ្វីទាំងអស់នោះ យើងក៏មិនបង្ខំឲ្យគាត់

និយាយដែរ ។ ក្រុមស្រាវជ្រាវរបស់យើងក៏ត្រូវបានបណ្តុះបណ្តាលមិនឲ្យសួរនូវសំណួរបែបប្រដេញឬបង្ខំដែលធ្វើឲ្យជនរងគ្រោះនិយាយអ្វីដែលគាត់មិនចង់និយាយឬដែលធ្វើឲ្យគាត់ផ្តល់ចម្លើយដែលគាត់មិនចង់ឆ្លើយនោះដែរ ។

ម្យ៉ាងទៀត នៅពេលដែលយើងមានអារម្មណ៍ថាជនរងគ្រោះចង់ឈប់និយាយជាមួយនឹងយើង យើងផ្លាស់ប្តូរប្រធានបទមួយរយៈពេលសិន ។ ដូច្នេះគាត់អាចនិយាយអ្វីដែលធ្វើឲ្យគាត់អាចបន្ធូរអារម្មណ៍របស់គាត់បានប្រសើរជាងមុនបន្តិច ។ ឧទាហរណ៍ ជនរងគ្រោះទាំងអស់ចូលចិត្តនិយាយអំពីបញ្ហាជីវភាព ។ ការនិយាយបែបនេះ គឺជាហេតុផលល្អនិងសាមញ្ញសម្រាប់ក្រុមការងាររបស់យើង ។ បន្ទាប់មកយើងនឹងវិលត្រឡប់ទៅប្រធានបទដែលយើងសង្ឃឹមថាគាត់នឹងនិយាយប្រាប់ ។

ក្នុងករណីខ្លះ គឺត្រូវការពេលវេលាយូរដើម្បីឲ្យជនរងគ្រោះមានទំនុកចិត្តមកលើយើង ។ ជនរងគ្រោះដែលរស់នៅក្នុងតំបន់មួយដែលជាអតីតតំបន់លាក់ខ្លួនរបស់ខ្មែរក្រហមស្ទាក់ស្ទើរមិនចង់និយាយជាមួយនឹងយើងទេ ។ តំបន់នោះជាតំបន់ដាច់ស្រយាលហើយការទៅលេងក្រុមគ្រួសារនៅទីនោះមានការលំបាកក្នុងការស្វែងរកភូមិដ្ឋានទាំងនោះខ្លាំងណាស់ ។ដូច្នេះយើងបានធ្វើជាផ្លាកសញ្ញាយ៉ាងសាមញ្ញសម្រាប់បង្ហាញផ្លូវឆ្ពោះទៅកាន់ភូមិទាំងនោះ ។ ក្រោយពីយើងបានទៅលេងសួរសុខទុក្ខអតីតកម្មាភិបាលខ្មែរក្រហមជាច្រើនលើក អតីតកម្មាភិបាលខ្មែរក្រហមនោះចាប់ផ្តើមជឿទុកចិត្តក្រុមការងាររបស់យើង ហើយគាត់មានចំណាប់អារម្មណ៍ចង់និយាយប្រាប់យើងច្រើនជាងមុន ។

ក្នុងករណីខ្លះទៀត នៅពេលដែលយើងកំពុងតែធ្វើការសម្ភាសន៍ជាមួយជនរងគ្រោះនូវសំណួរដែលប៉ះពាល់ដល់អារម្មណ៍របស់គាត់ ដូចជាការចាប់រំលោភជាដើម យើងសួរគាត់ថា តើគាត់ចង់និយាយតែជាមួយស្ត្រីចាស់ទុំដែលជាបុគ្គលិករបស់យើងឬក៏ជាលក្ខណៈបុគ្គល ។

### តើលោកអាចជំរុញឲ្យមានការចូលរួមយ៉ាងស្មោះត្រង់ដោយរបៀបណា ជាពិសេសពីជនដៃដល់?

ជាមនុស្ស យើងមានការយល់ដឹងអំពីភាពខុសប្លែកគ្នារវាងត្រូវនិងខុស ក៏ប៉ុន្តែភាគច្រើនជាពិសេសអ្នកដែលប្រព្រឹត្តខុសម្តងម្កាល ស្ទាក់ស្ទើរក្នុងចិត្តមិនចង់និយាយពីសកម្មភាពរបស់ខ្លួនដោយចំហនោះទេ ។ នេះជាចរិតធម្មជាតិរបស់មនុស្ស ។ អ្នកទាំងនោះភ័យខ្លាចចំពោះផលវិបាកផ្សេងៗអំពីជីវិតរបស់ខ្លួននាពេលបច្ចុប្បន្នឬទៅអនាគត ។ ដូច្នេះមធ្យោបាយល្អបំផុតដែលយើងអាចសម្រេចបាន គឺការសំដែងភាពស្មោះត្រង់ និងការគោរពចំពោះគាត់តែប៉ុណ្ណោះ ។

### តើលោកអាចបញ្ជាក់ព័ត៌មានដែលអ្នកទទួលបានពីជនរងគ្រោះតាមរយៈការសម្ភាសន៍ផ្ទាល់មាត់ដោយរបៀបណានិងតាមកម្រិតណាដែរ?

មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាអង្គការផ្នែកច្បាប់នោះទេ ដូច្នេះយើងមិនបញ្ជាក់ថាតើជនរងគ្រោះនិយាយរឿងពិតឬយ៉ាងណាឡើយ ។ យើងជាអ្នកសរសេរប្រវត្តិសាស្ត្រផ្ទាល់មាត់ និងជាអ្នករក្សាឯកសារ ហើយយើងចាត់ទុកកិច្ចការរបស់យើងជាកិច្ចការកត់ត្រាប្រវត្តិសាស្ត្រដែលបានមកពីគ្រប់មជ្ឈដ្ឋានទាំងអស់ ។ ពេលខ្លះនៅពេលដែលយើងផ្សព្វផ្សាយរឿងរ៉ាវរបស់ជនរងគ្រោះពីការសម្ភាសន៍ ឬចងក្រងរឿងរ៉ាវរបស់ជនរងគ្រោះតាមរយៈកំណត់ហេតុជាប្រវត្តិសាស្ត្រ មានប្រជាពលរដ្ឋកម្ពុជាខ្លះបានសរសេររឿងរ៉ាវផ្ទាល់ខ្លួននិងផ្ញើមកកាន់មជ្ឈមណ្ឌលយើងដើម្បីបោះពុម្ពដែរ ។ ជាធម្មតាប្រវត្តិសាស្ត្រផ្ទាល់មាត់ដែលជនរងគ្រោះផ្តល់ឲ្យទទួលបាននូវលទ្ធផលល្អជាវិជ្ជមាន ព្រោះប្រវត្តិសាស្ត្រផ្ទាល់មាត់ជួយបង្កើនទាំងចំណេះដឹងនិងការយល់ដឹង ។

### ៨) ដោយសារតែជនដៃដល់និងជនរងគ្រោះរស់នៅជិតគ្នា តើគម្រោងរបស់លោកមានឥទ្ធិពលលើការផ្សះផ្សានៅក្នុងសង្គមដែរឬទេ?

យើងមានការព្រួយបារម្ភដែរចំពោះស្ថានភាពដ៏លំបាកនេះ ក៏ប៉ុន្តែយើងកំពុងតែចាប់ផ្តើមមើលឃើញពីការរីកចម្រើនលើផ្នែកនេះ ។ ឧទាហរណ៍ យើងទើបតែបានបញ្ចប់ដំណាក់កាលសម្រាប់ពិសោធន៍មើលគម្រោងមួយដែលជួយទាំងជនរងគ្រោះនិងជនដៃដល់ដែលជនដៃដល់ក៏ជាជនរងគ្រោះដែរ ដើម្បីឲ្យអ្នកទាំងនោះចេះព្យាបាលជំងឺផ្លូវចិត្តដោយខ្លួនឯង ។ ដៃគូការងាររបស់យើង អង្គការអន្តរវប្បធម៌ចិត្តសង្គម បានរៀបចំការពិភាក្សាគ្នា អំពី

ការព្យាបាលជំងឺជាក្រុមដែលទាំងជនរងគ្រោះនិងជនដៃដល់ពិភាក្សាអំពីជីវិតរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងស្វែងយល់ពីគ្នាទៅវិញទៅមក (ការផ្តល់ប្រឹក្សានៅតែស្ថិតក្នុងដំណាក់កាលចាប់កំណើតនៅកម្ពុជាដែលមានគ្រូពេទ្យចិត្តសាស្ត្រតែ១២នាក់ប៉ុណ្ណោះ និងអ្នកជំងឺក្នុងគម្រោងនេះមួយចំនួនអាចសម្រាកលក់ស្កប់ស្កល់បានមួយយប់ជាលើកដំបូងក្នុងរយៈពេល២៥ឆ្នាំដោយសារតែជំនួយពីគម្រោងនេះ) ។ ភាពជោគជ័យនៃគម្រោងនេះក៏ជាកត្តាមួយជំរុញឲ្យអ្នកដទៃទៀត ចូលរួមជួយចែករំលែកនូវបទពិសោធន៍របស់ខ្លួន ។

យើងក៏បានអញ្ជើញជនរងគ្រោះនិងជនដៃដល់ចូលរួមដំណើរទស្សនកិច្ចជាមួយគ្នា នៅទីក្រុងភ្នំពេញដើម្បីទស្សនាអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ដែលត្រូវបានស្គាល់ថាសាលាក្តីខ្មែរក្រហម) ។ នៅក្នុងដំណើរទស្សនកិច្ចមួយ យើងបាននាំបុរសម្នាក់ដែលជាអតីតឆ្មាំគុក នៅគុកក្រាំងតាចាន់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជួបជាមួយនឹងកូនប្រុសរបស់បុរសម្នាក់ ដែលឆ្មាំគុកនេះបាននាំយកទៅសម្លាប់ ។ បុរសជាឆ្មាំគុកនិងបុរសដែលមានឪពុកត្រូវឆ្មាំគុកសម្លាប់ រស់នៅក្នុងភូមិជាមួយគ្នា ហើយបុរសជាក្មេងកំព្រាមានអារម្មណ៍ភ័យខ្លាចអតីតជនដៃដល់នេះយូរមកហើយដែលគំរាមកំហែងបុរសជាក្មេងកំព្រាជាញឹកញាប់ ។ នៅក្នុងដំណើរទស្សនកិច្ច អ្នកទាំងពីរបានស្នាក់នៅក្នុងបន្ទប់ជាមួយគ្នា ។ ដំបូងអ្នកទាំងពីរស្ទាក់ស្ទើរមិនចង់ស្នាក់នៅក្នុងបន្ទប់ជាមួយគ្នាទេ ក៏ប៉ុន្តែគាត់ទាំងពីរបាននិយាយរកគ្នា ហើយឥឡូវអតីតឆ្មាំគុកនិងបុរសជាក្មេងកំព្រាកំពុងតែចាប់ផ្តើមយល់គ្នាទៅវិញទៅមកនិងរស់នៅជាមួយគ្នាប្រសើរជាងមុន ។

***៥) ចាប់តាំងពីអ្នកផ្លាស់មករស់នៅក្នុងទីក្រុងភ្នំពេញ តើលោកធ្លាប់បានចុះទៅជួបអ្នកស្រុកអ្នកភូមិដែលរស់នៅក្នុងបណ្តាខេត្តនានាដោយរបៀបណា? តើអ្នកស្រុកអ្នកភូមិមានប្រព័ន្ធអ៊ីនធឺណែត ដើម្បីមើលព័ត៌មានដូចជាប្រព័ន្ធទិន្នន័យគន្លងនិទ្ទេសនិងប្រព័ន្ធទិន្នន័យប្រវត្តិរូបបានដែរឬទេ?***

ការទាក់ទងមិនមែនជាការងារងាយស្រួលឡើយ នៅកម្ពុជាជាពិសេសគឺនៅតាមជនបទដែលប្រជាជនកម្ពុជាភាគច្រើនមិនអាចទទួលបានព័ត៌មានតាមរយៈការអានសៀវភៅ កាសែត ទស្សនាវដ្តី ឬមើលទូរទស្សន៍ឡើយ ។ អ៊ីនធឺណែតគឺមាននៅក្នុងទីរួមខេត្តតែប៉ុណ្ណោះ ។ បើទោះបីជាអ្នកស្រុកអ្នកភូមិពិតជាអាចប្រើប្រាស់ទំនាក់ទំនងបែបនេះក៏ដោយ ក៏គាត់មិនអាចចេះប្រើប្រាស់ ឬអានព័ត៌មានតាមប្រព័ន្ធអ៊ីតធឺណែតបានដែរ ។ ដូច្នេះយើងផ្សព្វផ្សាយព័ត៌មានដល់អ្នកស្រុកអ្នកភូមិបានដឹងតាមមធ្យោបាយផ្សេងៗ ។ យើងបោះពុម្ពទស្សនាវដ្តីជារៀងរាល់ខែដែលមជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀតនៅកម្ពុជាចែកចាយទៅគ្រប់សាលាស្រុក និងសាលាឃុំទូទាំងប្រទេស ។ យើងក៏មានកម្មវិធីវិទ្យុប្រចាំសប្តាហ៍ដែលផ្សព្វផ្សាយគ្រប់ខេត្តទាំងអស់ ។

ក្នុងពេលដែលយើងបញ្ជូនក្រុមការងារឲ្យចុះទៅធ្វើការសម្ភាសន៍ជាមួយនឹងអតីតកម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិផ្សេងៗ យើងតែងព្យាយាមអស់ពីសមត្ថភាពដើម្បីចុះជួបជនរងគ្រោះ ។ ក្រោយពីរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានចាប់ផ្តើមបង្កើតការិយាល័យតុលាការរបស់ខ្លួនភ្លាម យើងក៏បានចាប់ផ្តើមបញ្ជូនក្រុមការងាររបស់យើងទៅភូមិទាំងឡាយដើម្បីបញ្ចាំងខ្សែភាពយន្តឯកសារប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យពិភាក្សាអំពីការវិវឌ្ឍន៍របស់សាលាក្តីខ្មែរក្រហម ផ្តល់ឱកាសឲ្យអ្នកស្រុកអ្នកភូមិរៀបរាប់រឿងរ៉ាវផ្ទាល់ខ្លួន និងស៊ើបសួររកព័ត៌មានស្វែងរកសាច់ញាតិជាទីស្រលាញ់របស់ខ្លួនដែលបានបាត់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ជាចុងក្រោយ ប្រជាពលរដ្ឋកម្ពុជាពុំមានលទ្ធភាពធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញនោះទេ ។ ដោយសារតែរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិមិនទាន់ប្រកាសនូវផែនការ ថាតើរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនឹងផ្សព្វផ្សាយព័ត៌មានស្តីអំពីដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហមទៅឲ្យអ្នកស្រុកអ្នកភូមិបានដឹងដោយរបៀបណានៅឡើយ យើងសម្រេចចិត្តនាំអ្នកស្រុកអ្នកភូមិដែលជាជនរងគ្រោះមកឲ្យជួបជាមួយក្រុមមន្ត្រីដែលធ្វើកិច្ចការតុលាការនេះវិញ ។ នៅខែកុម្ភៈ ក្នុងឆ្នាំ២០០៦នេះ យើងបានចាប់ផ្តើមរៀបចំដំណើរទស្សនកិច្ចអង្កេតមុនការកាត់ក្តីចំនួនពីរដងក្នុងមួយខែម្តងសម្រាប់អ្នកភូមិ ប្រធានភូមិ សិស្សនិស្សិត និងដូនជី ។ រយៈពេលបីថ្ងៃស្នាក់នៅទីក្រុងភ្នំពេញ គាត់ទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតបឹងជើងឯក

និងអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នៅក្នុងអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អ្នកស្រុកអ្នកភូមិបានជួបជាមួយមន្ត្រីអង្គការសហប្រជាជាតិនិងមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាដែលកំពុងតែបំពេញការងារក្នុងសាលាក្តីនេះ និងបានពន្យល់អំពីតុលាការព្រមទាំងឆ្លើយសំណួររបស់អ្នកស្រុកអ្នកភូមិ ។ ក្នុងឆមាសទី១ នៃឆ្នាំ២០០៦ មានអ្នកស្រុកអ្នកភូមិប្រមាណជាង ៣០០០នាក់បានចូលរួមដំណើរទស្សនកិច្ចទាំងនេះ ។ នៅពេលដែលដំណើរការជំនុំជម្រះក្តីចាប់ផ្តើមយើងគ្រោងនឹងនាំអ្នកស្រុកអ្នកភូមិទូទាំងប្រទេសចូលរួមសវនាការរយៈពេលមួយសប្តាហ៍ ។ បន្ទាប់ពីការចូលរួមក្នុងសវនាការរយៈពេលមួយសប្តាហ៍ គាត់នឹងទៅនិយាយប្រាប់អ្នកភូមិរបស់គាត់នៅពេលដែលគាត់វិលត្រឡប់ទៅភូមិរបស់គាត់វិញ ព្រមទាំងមានការពិភាក្សាគ្នាអំពីអ្វីដែលគាត់បានឃើញនិងសិក្សាស្វែងយល់ ។ បុគ្គលិករបស់យើងនឹងថតវេទិកាពិភាក្សាទាំងនេះ និងយកវេទិកាពិភាក្សានេះមកចាក់ផ្សព្វផ្សាយនៅក្នុងភូមិផ្សេងៗទៀត សម្រាប់អ្នកស្រុកអ្នកភូមិដែលមិនបានចូលរួមដំណើរការទស្សនកិច្ច ។ តាមរយៈមធ្យោបាយនេះ យើងសង្ឃឹមថាដំណើរការចូលរួមនេះនឹងក្លាយជាដំណើរស្វែងរកយុត្តិធម៌នៅកម្ពុជា ។

**៦) ដោយសារការងាររបស់អ្នកប្រមែប្រមូលឯកសារមួយផ្នែករបស់លោកមានអត្ថប្រយោជន៍សម្រាប់ការជំនុំជម្រះក្តីនាពេលខាងមុខនេះ តើលោកមើលឃើញដំណើរវិវត្តជាសន្ទឹមៗនៃការរៀបចំការកាត់សេចក្តីនេះយ៉ាងដូចម្តេច បន្ទាប់ពីតុលាការត្រូវបានកើតឡើងនោះ?**

យើងក៏បានចោទសួរខ្លួនឯងអំពីតួនាទីបន្ទាប់ពីសវនាការចប់ដែរ ។ ដោយមានគម្រោងប្រែក្លាយមជ្ឈមណ្ឌលឯកសារកម្ពុជាទៅជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍នៅកម្ពុជាឯកសារទាំងឡាយដែលយើងប្រមែប្រមូលនឹងបន្តប្រើប្រាស់ជាសំណុំឯកសារដ៏មានតម្លៃសម្រាប់បញ្ញាជនទាំងនៅក្នុងប្រទេសកម្ពុជានិងក្រៅប្រទេសធ្វើការស្រាវជ្រាវ ។

ក្រៅពីកិច្ចការប្រមែប្រមូលឯកសារ មជ្ឈមណ្ឌលអចិន្ត្រៃយ៍នេះនឹងត្រូវប្រើប្រាស់ជាស្ថាប័នអប់រំដែលផ្តល់វគ្គសិក្សាសម្រាប់សិស្សនិងនិស្សិតកម្ពុជានិងបរទេសធ្វើការសិក្សាលើមុខវិជ្ជាដូចជាការអប់រំអំពើប្រល័យពូជសាសន៍ ប្រវត្តិសាស្ត្រ ច្បាប់ ការសិក្សាអំពីសន្តិភាពនិងការផ្សះផ្សា ។ ស្ថាប័ននេះក៏នឹងមានអគារសារមន្ទីរពិពណ៌ដែលមានការដាក់តាំងបង្ហាញពី សិល្បៈ រូបថត និងផ្សេងៗទៀតជាច្រើនទៀតដែលទាក់ទិននឹងប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប និងនយោបាយនាពេលបច្ចុប្បន្ន ។ សារមន្ទីរនេះនឹងបើកជូនសាធារណជនចូលទស្សនា ។

យើងក៏មានគម្រោងផ្តល់សេវាប្រឹក្សាមិនត្រឹមតែសម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ក្រុមគ្រួសាររបស់ជនរងគ្រោះថែមទៀត ដែលជាញឹកញាប់ជួបនូវផលប៉ះពាល់ជាអវិជ្ជមានពីកេរ្តិ៍ដំណែលនៃរបបកម្ពុជាប្រជាធិបតេយ្យនូវការភ័យខ្លាច កំហឹងគុំគួន ភាពសោកសៅ និងហិង្សាដែលញាំញីសង្គមយើងបច្ចុប្បន្ននេះ ។ ក្នុងគម្រោងនេះយើងនឹងបង្កើតនូវសកម្មភាពជាក់ស្តែងដើម្បីដោះស្រាយនូវកេរ្តិ៍ដំណែលនេះ ជាពិសេសសកម្មភាពទាំងឡាយដែលត្រូវបានបង្កើតដើម្បីកាត់បន្ថយភាពក្រីក្រ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ពាក្យស្លោកខ្មែរក្រហម

- **ផ្អែកឱ្យរឹងមាំលើវណ្ណៈអធន សាមគ្គីយ៉ាងជិតស្និទ្ធជាមួយកម្លាំងប្រជាជាតិទាំងមូល មកខាងបដិវត្តន៍ឯកោ ខ្ទាំងសត្រូវមួយក្តាប់តូចជាអតិបរមា!**
- **ក្តាប់ជាប់ និងអនុវត្តឱ្យល្អ ផែនការបង្កើនចំនួនប្រជាជននឹងឱ្យបានច្រើនជាអតិបរមាពី១៥-២០លាននាក់ក្នុង១០-១៥ឆ្នាំខាងមុខនេះ។**
- **ក្តាប់ជាប់ និងអនុវត្តឱ្យបានល្អ ផែនការបង្កើនចំនួនប្រជាជនឱ្យបានច្រើន ជាអតិបរមាក្នុង១ឆ្នាំ ៣ឆ្នាំ ៥ឆ្នាំ ១០ឆ្នាំ និង១៥ឆ្នាំ។**

*(សៀវភៅកំណត់ហេតុលេខ០៧៦)*

- **ខ្ទះខ្ទែងអនុវត្តន៍កម្មវិធីនយោបាយនិងលក្ខន្តិកៈរបស់ "សម្ព័ន្ធយុវកក"** *(សៀវភៅកំណត់ហេតុលេខ០៧៧)*

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ឈឹម សំណាង : តំណាងរាស្ត្រមណ្ឌលតាកែវ

ឈឹម សំណាង អាយុ៤៣ឆ្នាំ ជាអតីតតំណាងរាស្ត្រមណ្ឌលបឹងត្រាញ់ ខេត្តតាកែវ ក្នុងសម័យសាធារណរដ្ឋខ្មែរ ។ សំណាង កើតនៅសង្កាត់លេខ៩ទីក្រុងភ្នំពេញ ។ សំណាង បានសិក្សានៅសាលាហ្វ្រង់ស័រ សាលាគរុវិជ្ជា និងវិទ្យាស្ថានជាតិគរុកោសល្យ នៅទីក្រុងភ្នំពេញ រហូតបានសញ្ញាបត្រសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិផ្នែកធម្មជាតិវិទ្យា ។ សំណាង ត្រូវអង្គការឃាត់ខ្លួននៅខេត្តបាត់ដំបងនៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៦ និងបញ្ជូនមកសួរចម្លើយនៅមន្ទីរស-២១អំពីការធ្វើសកម្មភាពបម្រើសេ.អ៊ី.អា. ។


ឈឹម សំណាង

នៅឆ្នាំ១៩៥៨ សំណាង ធ្វើជាគ្រូបង្រៀនថ្នាក់បឋមសិក្សានៅខេត្តតាកែវ ។ នៅឆ្នាំ១៩៦០ សំណាង បានធ្វើជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិផ្នែកធម្មជាតិវិទ្យា ។ ពីរឆ្នាំក្រោយមក សំណាង ធ្វើជានាយកមធ្យមសិក្សាខេត្តតាកែវ ។ នៅឆ្នាំ១៩៧១ សំណាង ត្រូវបានចាត់តាំងឲ្យធ្វើជាអគ្គលេខាធិការរងនៃវិទ្យាស្ថានជាតិខេមរយានកម្មនៅភ្នំពេញ ។ សំណាង និងក្រុមគ្រួសារក៏ផ្លាស់មករស់នៅទីក្រុងភ្នំពេញនៅម្តុំឃ្លាំងរំសេវ ក្នុងសង្កាត់លេខ៣ ។

### ការងារមុនថ្ងៃ១៧ខែមេសាឆ្នាំ១៩៧៥

នៅឆ្នាំ១៩៧២ សំណាង ត្រូវបានជ្រើសតាំងជាតំណាងរាស្ត្រមណ្ឌលបឹងត្រាញ់ ខេត្តតាកែវ ។ សំណាង បានចូលជាសមាជិកសមាគមទ្រទ្រង់ខេត្តតាកែវ សមាគមបុគ្គលិកសិក្សាខ្មែរ និងសមាគម“ប៊ីក្លិប” ។ នៅសមាគម “ប៊ីក្លិប” សំណាង បានស្គាល់ ឡុង បុត្តា, ប៉ុក ថន និង ប៉ាន់ សុធី ហើយ អ្នកទាំងបីបានណែនាំសំណាង ឲ្យស្គាល់ពីលោកសេរីនិងអង្គការសេ.អ៊ី.អា. ។ នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំដដែល សំណាង ចូលជាសមាជិកសេ.អ៊ី.អា. នៅការិយាល័យរបស់ ប៉ាន់ សុធី នៅសភាជាតិ ក្រោមការឧទ្ទេសនាមពី ប៉ាន់ សុធី ។ ចាប់តាំងពីចូលជាសមាជិកសេ.អ៊ី.អា. សំណាង ទទួលបានប្រាក់បៀវត្សរ៍ចំនួនប្រាំម៉ឺនរៀលក្នុងមួយខែពី ប៉ាន់ សុធី ។

សំណាង ទទួលការអប់រំពីទ្រឹស្តីប្រឆាំងនឹងកុម្មុយនិស្តក្នុងរយៈពេលប្រហែល២សប្តាហ៍ នៅផ្ទះរបស់ លន់ ណុន និងផ្ទះរបស់ ហង្ស ធុនហាក់ និងបង្រៀនដោយ ហង្ស ធុនហាក់, តាន់ គីមហួន, លន់ ណុន និងឧត្តមសេនីយ៍ យូ ក្វាង មកពីប្រទេសតៃវ៉ាន់ ។ ខ្លឹមសារសំខាន់នៃការអប់រំគឺផ្តោតសំខាន់ទៅលើលិទ្ធិកុម្មុយនិស្តនិងលោកសេរី ដូចជា តើកុម្មុយនិស្តឃោសនារបៀបយ៉ាងណា? ក្នុងមជ្ឈដ្ឋានណា? តើកុម្មុយនិស្តវាយប្រហារលោកសេរីយ៉ាងណាខ្លះ? តើត្រូវក្តោបមនុស្សមជ្ឈដ្ឋានណាខ្លះដើម្បីឈ្នះកុម្មុយនិស្ត?

សំណាង បានដើរឃោសនាសិស្ស អ្នកភៀសខ្លួន និងប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ឲ្យស្អប់លទ្ធិកុម្មុយនិស្តឲ្យស្រឡាញ់លោកសេរី និងបង្កើតខ្សែរយៈសេ.អ៊ី.អានៅខេត្តតាកែវ ដើម្បីប្រឆាំងនឹងកុម្មុយនិស្តវិញ ។ ខ្សែរយៈនេះមានសមាជិក៥នាក់គឺ សូ ឆាន់, សុខ ទង, អ៊ឹង ឈឿក, ឡាយ ឈាត និង មុត ហឿន ។

### ការងារក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥

ពេលរដ្ឋាភិបាលរបស់លោកសេនាប្រមុខ លន់ នល់ ចាញ់សង្គ្រាម សំណាង និងក្រុមគ្រួសារត្រូវបានជម្លៀសទៅភូមិវត្តកណ្តាល ស្រុក២០ តំបន់២៥ (ខេត្តកណ្តាល) ។ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥ សំណាង ត្រូវជម្លៀសម្តងទៀតទៅ ភូមិតាវែង សង្កាត់ពន្លៃ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។

ចាប់តាំងពីពេលជម្លៀសចេញ សំណាង ពុំអាចធ្វើសកម្មភាពចងខ្សែរយៈ ឬបង្កើតខ្សែថ្មីបានទេ ដោយសារថា ទី១) ខ្សែរយៈចាស់ដាច់និងបែកគ្នាទៅតំបន់ផ្សេងៗ ទី២) អង្គការបដិវត្តន៍នៅតំបន់២៥ និងតំបន់៥ ចាត់វិធានការយ៉ាងតឹងរ៉ឹងមិនអនុញ្ញាតមានការជួបជុំគ្នា ឬផ្តល់លទ្ធភាពឲ្យមានការបន្តខ្សែរយៈវិញឡើយ ទី៣) ប្រជាជនទាំងចាស់ក្មេងយល់អំពីនយោបាយអង្គការ និងនាំគ្នាគាំទ្រមាគ៌ាបដិវត្តន៍ទាំងស្រុង ហើយក្នុងពេលធ្វើការម្តងៗ

ប្រធានភូមិតែងរំឭកដល់ប្រជាជនថា«ការប្រឆាំងមាគ៌ាអង្គការបដិវត្តន៍ មិនត្រូវកសាងទេ គឺត្រូវសម្លាប់ចោលភ្លាមតែម្តង» ។

ប៉ុន្តែ សំណាង នៅតែឆ្លៀតបំផុសបំផុលចិត្តគំនិតនិងកសាងប្រជាជនថ្មីបានចំនួន៣នាក់ ដែលមានឈ្មោះ ឈុន គៀង អតីតស័ក្តិ៥ខាងខុទ្ទកាល័ម្ភាគចក្រ, ឃី តាំងលី អតីតនាយក្រសួងប៉ុស្តិ៍និងប្រៃសណីយ៍ និង ឃួន ឃិន អតីតសាស្ត្រាចារ្យបរិញ្ញាបត្រនៅវិទ្យាស្ថានជាតិខេមរយានកម្មឲ្យជួយផ្សព្វផ្សាយប្រឆាំងលិទ្ធិកុម្មុយនិស្តនិងស្រលាញ់លិទ្ធិលោកសេរី ។

## អំពីក្រុមគ្រួសារ

ឪពុករបស់ សំណាង ឈ្មោះ ហុក ជ្រីវ និងម្តាយឈ្មោះ ឈុន គោ ។ សំណាង មានបងប្អូនបង្កើតចំនួន៧នាក់ (ស្រី២និងប្រុស៥) ។ ទី១) ហុក កាម (ស្រី) រស់នៅភ្នំពេញមុនឆ្នាំ១៩៧៥ ២) ជ្រីវ ប៉េង ឈាង (ប្រុស) រស់នៅភ្នំពេញមុនឆ្នាំ១៩៧៥ ៣) ឈូវ សំអ៊ុល (ប្រុស) ធ្វើជាពេទ្យសត្វនិងយោធាអតីតស័ក្តិ៥នៅភ្នំពេញ ៤) សំណាង ៥) ហុក ឈន (ប្រុស) អតីតនាយការិយាល័យសេដ្ឋកិច្ច ក្រសួងមហាផ្ទៃនៅភ្នំពេញ ៦) ហុក សារិន (ស្រី) មានប្តីបារាំងរស់នៅប្រទេសកាមីរូន (អាហ្វ្រិក) និង៧) ហុក សេង បើកហាងលក់បាយឈ្មោះ "ចង្កឹះមាស" ជាមួយម្តាយមីងនៅប្រទេសកាមីរូន (អាហ្វ្រិក) ។

ប្រពន្ធរបស់ សំណាង ឈ្មោះ ឈាវ គឹមហុង និងមានកូន៩នាក់គឺ ១) ឈឹម ណារ៉ា រស់នៅជាមួយជីតាឈ្មោះ ឈាវ ស៊ា (មុនឆ្នាំ១៩៧៥) ២) ឈឹម ណារ៉េត រស់នៅជាមួយម្តាយមីងឈ្មោះ ហុក កាម នៅទីក្រុងភ្នំពេញមុនឆ្នាំ១៩៧៥ ៣) ឈឹម ណារិទ្ធ ៤) ឈឹម ណារ៉ាទ ៥) ឈឹម ណារីកា ៦) ឈឹម ណារីដា ៧) ឈឹម ណារីតា ៨) ឈឹម ណារ៉ូ និង ៩) ឈឹម ណារី រស់នៅជាមួយម្តាយមីងឈ្មោះ ឈុន កូស៊ុំ នៅប្រទេសកាមីរូន ។ ក្នុងចំណោមកូនទាំង៩នាក់ មានកូនចំនួន៥នាក់រស់នៅនិងត្រូវបានជម្លៀសទៅតាមសំណាងនិងប្រពន្ធ ។

## ការចាប់ខ្លួននិងចម្លើយសារភាព

សំណាង ត្រូវអង្គការឃាត់ខ្លួននៅកន្លែងរៀនសូត្រនៅស្រុកភ្នំស្រុក តំបន់៥ នៅល្ងាចថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៦ ដោយសារពាក់ព័ន្ធជាមួយសេ.អ៊ី.អា. និងយកមកឃុំខ្លួននៅមន្ទីរ៤៤តាខ្មៅនៅថ្ងៃទី១៤ ខែ២ឆ្នាំ១៩៧៦ រួចបញ្ជូនមកសួរចម្លើយនៅមន្ទីរស-២១ (គុកទួលស្លែង) ។

ក្នុងឯកសារចម្លើយសារភាពរបស់ សំណាង មានបញ្ជាក់អំពីផែនការរបស់អង្គការសេ.អ៊ី.អា មុនចាញ់សង្គ្រាមជាមួយកងទ័ពខ្មែរក្រហម និងផែនការត្រៀមចាញ់សង្គ្រាម (ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥) និងអំពីប្រវត្តិរូបសង្ខេបរបស់អ្នកជាប់ពាក់ព័ន្ធផ្សេងៗទៀតដែលភាគច្រើនជាតំណាងរាស្ត្រក្នុងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ រួមទាំងតារាងរចនាសម្ព័ន្ធអង្គការសេ.អ៊ី.អានៅក្នុងរដ្ឋសភាជាតិ ។

យោងតាមបញ្ជីកម្មេចអ្នកទោសនៅគុកទួលស្លែងដែលចងក្រងដោយសារមន្ទីរទួលស្លែង សំណាង ត្រូវឃុំឃាំងក្នុងផ្ទះក០២ បន្ទប់ធំ១ និងកម្មេចនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦ ។ ក៏ប៉ុន្តែគ្មានឯកសារណា បញ្ជាក់ពីវាសនារបស់សមាជិកដទៃទៀតក្នុងក្រុមគ្រួសាររបស់ សំណាង ទេ ។

## ឈ្មោះអ្នកពាក់ព័ន្ធក្នុងចម្លើយសារភាព

នៅក្នុងឯកសារប្រវត្តិរូបសង្ខេបរបស់អ្នកដែលពាក់ព័ន្ធក្នុងអង្គការសេ.អ៊ី.អា មានចំណាវបែងចែកឈ្មោះនៅក្នុងចម្លើយរបស់ សំណាង ជា៣ក្រុម ÷

**ខ្មែរលើ ៖** ប៉ាន់ សុធី, ប៉ុក ថន និង ឡុង បូត្តា ។

**ខ្មែរស្មើ ៖** តាន់ គឹមហួន, អេង សុទ្ធ, ប៊ុន ចាន់ម៉ុល, អ៊ីវ យ៉ាង, យុល សារិន, នូ រិន, អ៊ុប សុង, រស់ វុនធុល, គឹម ផែន, គឹម ស៊ីយ៉ុង, គីក ឡាយ, ខេង នៅ, អ្នកស្រី ស៊ឹម វ៉ាន់ស៊ី, ប៊ុន គី, ឆាយ យ៉ត, ជា នាង, ញឹក គឹមឡុង, ញាណ គឿន, ប៊ុន វ៉ាន់ថា, ហួត ប៊ុនថេង, កាន់ ឈុំ, ថាច់ ស៊ុយយែម, គោ ឈន់, អ៊ុក ម៉ឺល, កែន យ៉ាន, លី សន, ទី សំផន, ឡោ ប៊ុនណា, នួន ជាន, ថាច់ គ្មាន, សន ថាត, អ៊ឹម យូហៃ, អ្នកស្រី ម៉ា លីសលា (ប្រពន្ធរបស់ ប៉ាន់ សុធី), អ៊ុង ខាន់, ម៉ែន ហឿន, ជួង អេងហាប់, ចាន់ ទិត, ខេង សាភ័ន, ប៊ិល ទីម៉ន, នុត ឈួន, រត់ ភុន, អ្នកស្រី ម៉ៅ ម៉ាឡាំង នាមដើម ជា, អ្នកស្រី ឡុង វ៉ាន់ថេត, អៀម រិត, ជូ ផុត និង ឈឿយ ប៊ុនធិន ។

**ខ្មែរក្រោម ៖** សូ ឆាន់, សុខ ទង, អ៊ឹង ឈៀក, ឡាយ ឈាត, មុត ហឿន, ឈុន គៀង, ឃី តាំងលី និង ឃួន ឃិន ។

**ណយ សុផារី**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយ : យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៨៣៣ | លឿង គីមលាង ហៅ ភី (ស្រី) | ប្រពន្ធ ជុំ ថៃអ៊ី ហៅ ប៉ឹក | ? | ? | ១៤-៦-៧៧ |
| ២៨៣៤ | យង់ វន់ (ស្រី) | ប្រពន្ធ ចិន ឡុក ហៅ សាត | ? | ? | ១៤-៦-៧៧ |
| ២៨៣៥ | ឈៀក អ៊ុក (ស្រី) | កូន មុយ ឡាំង | ? | ? | ១៤-៦-៧៧ |
| ២៨៣៦ | ដាំ យង់ (ស្រី) | យុទ្ធនារី | ស្ទឹងមានជ័យ | ? | ១៤-៦-៧៧ |
| ២៨៣៧ | ងី គីមហុង (ស្រី) | វ័យចាស់ | ស្ទឹងមានជ័យ | ? | ១៤-៦-៧៧ |
| ២៨៣៨ | យឹម ណៃអ៊ន ហៅ ណៃ (ស្រី) | ប្រពន្ធ ហៀប កាណន ហៅ អន | ? | ? | ១៤-៦-៧៧ |
| ២៨៣៩ | វិន វន (ស្រី) | យុទ្ធនារី | ស្ទឹងមានជ័យ | ? | ១៤-៦-៧៧ |
| ២៨៤០ | ស្នួ លី (ស្រី) | ម្ដាយ ជុំ | ? | ? | ១៤-៦-៧៧ |
| ២៨៤១ | មិន គីមសេង ហៅ ពិន | កង១៣ | ពាណិជ្ជកម្ម | ? | ១៤-៦-៧៧ |
| ២៨៤២ | ស៊ិន តេក | រដ្ឋករទឹក | ចំការមន | ? | ១៤-៦-៧៧ |
| ២៨៤៣ | ហៀប កាណន | រដ្ឋករទឹក | ភូមិព្រែក | ? | ១៤-៦-៧៧ |
| ២៨៤៤ | អោក ប៊ុនសេង ហៅ សេន | ? | ស្ទឹងមានជ័យ | ? | ១៤-៦-៧៧ |
| ២៨៤៥ | ពុត ឈួន ហៅ ក្រាន | ស្ទឹងមានជ័យ | ស្ទឹងមានជ័យ | ? | ១៤-៦-៧៧ |
| ២៨៤៦ | ម៉ម ផាន ហៅ វើត | អប់រំ | កងពល៣១០ | ? | ១៤-៦-៧៧ |
| ២៨៤៧ | ស៊ិន សាខន ហៅ ស្មី | ? | កងពល៤៥០ | ? | ១៤-៦-៧៧ |
| ២៨៤៨ | ញ៉ឹក សារី ហៅ សារឹម | យុទ្ធជន | កងពល៣១០ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៤៩ | យ៉ាន់ មឿន | យុទ្ធជន | កងពល៣១០ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៥០ | ញ៉ែម សាន | យុទ្ធជន | កងពល៣១០ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៥១ | ដួន ជឿន ហៅ រឿន | អនុយោធាកងធំ | កងពល៣១០ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៥២ | ចេង ស៊ាត | លេខាកងធំ | កងពល៤៥០ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៥៣ | ឈឹម ណូ ហៅ ស៊ុន | យុទ្ធជន | កងពល៤៥០ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៥៤ | សោម ភាព | យុទ្ធជន | កងពល៤៥០ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៥៥ | កែវ ហួយ | យុទ្ធជន | កងពល១៧០ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៥៦ | ចាន់ ធី ហៅ រឹម | មេក្រុម | សេនាធិការ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៥៧ | ឌុក ម៉ៅ | យុទ្ធជន | សេនាធិការ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៥៨ | អ៊ុន ឆុន ហៅ ឃន | មេក្រុម | សេនាធិការ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៥៩ | ស៊ឹម គាន | យុទ្ធជន | សេនាធិការ | ១២-៦-៧៧ | ១៤-៦-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៨៦០ | ចាន់ ខាន់ ហៅ យ៉ន | មេពួក | សេនាធិការ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៦១ | អ៊ិច នេន | មេពួក | សេនាធិការ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៦២ | គីម ស៊ីម | អនុក្រុម | សេនាធិការ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៦៣ | យ៉ៅ យ៉ាត ហៅ រ៉ុម | មេក្រុម | សេនាធិការ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៦៤ | សិត សំអឿន | យុទ្ធជន | មន្ទីរវ-៦៦ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៦៥ | ដួប លឹម ហៅ វ៉េត | យុទ្ធជន | មន្ទីរវ-៦៦ | ១២-៦-៧៧ | ១៤-៦-៧៧ |
| ២៨៦៦ | នុត យ៉ាន | កម្មករចាស់ | រោងចក្រអុកស៊ីសែន | ៨-២-៧៧ | ២០-៦-៧៧ |
| ២៨៦៧ | តូ សំបូរ | កម្មករចាស់ | រោងចក្រកង់រថយន្ត | ៤-៣-៧៧ | ២០-៦-៧៧ |
| ២៨៦៨ | តូច តែម | កម្មករចាស់ | រោងចក្រកង់រថយន្ត | ៨-៣-៧៧ | ២០-៦-៧៧ |
| ២៨៦៩ | ជា ម៉ូលី | កម្មករចាស់ | រោងចក្រ អ-៣ | ៤-១-៧៧ | ២០-៦-៧៧ |
| ២៨៧០ | ឆយ យុកឃាង | កម្មករចាស់ | រោងចក្រ ដ-២ | ២៣-៣-៧៧ | ២០-៦-៧៧ |
| ២៨៧១ | ជី យិន | កម្មករចាស់ | រោងចក្រ គ-៧ | ២៨-៥-៧៧ | ២០-៦-៧៧ |
| ២៨៧២ | ជា ហ៊ីម (ស្រី) | ប្រពន្ធ ហ៊ិន | រោងចក្រ គ-៧ | ៩-៦-៧៧ | ២០-៦-៧៧ |
| ២៨៧៣ | អ៊ុម ជាត ហៅ ជា (ស្រី) | យុទ្ធនារីសេដ្ឋកិច្ច | រោងចក្រ គ-៣ | ១-៤-៧៧ | ២០-៦-៧៧ |
| ២៨៧៤ | ឡឿ អេង ហៅ រ៉ុម (ស្រី) | យុទ្ធនារី | រោងចក្រ គ-៧ | ៣១-៣-៧៧ | ២០-៦-៧៧ |
| ២៨៧៥ | ព្រាប យិត ហៅ សូត្រ (ស្រី) | យុទ្ធនារី | រោងចក្រ គ-៧ | ៦-៤-៧៧ | ២០-៦-៧៧ |
| ២៨៧៦ | សួស សាម៉េត ហៅ រិន (ស្រី) | យុទ្ធនារី | រោងចក្រ គ-៧ | ១-៤-៧៧ | ២០-៦-៧៧ |
| ២៨៧៧ | ភឹម សុខុន (ស្រី) | យុទ្ធនារី | រោងចក្រ គ-៣ | ១-៤-៧៧ | ២០-៦-៧៧ |
| ២៨៧៨ | ប៉ា ស៊ាងលឹម (ស្រី) | យុទ្ធនារី | រោងចក្រ គ-៣ | ១៤-៣-៧៧ | ២០-៦-៧៧ |
| ២៨៧៩ | ឆាង ជា (ស្រី) | យុទ្ធនារី | រោងចក្រ គ-៧ | ៦-៤-៧៧ | ២០-៦-៧៧ |
| ២៨៨០ | ចាន់ សុជាត (ស្រី) | ប្រពន្ធ អែម ជា | រោងចក្រ ក-៥ | ១១-៥-៧៧ | ២០-៦-៧៧ |
| ២៨៨១ | ម៉ៅ ហ៊ឹម (ស្រី) | កម្មករចាស់ | រោងចក្រ គ-៥ | ២៨-៣-៧៧ | ២០-៦-៧៧ |
| ២៨៨២ | ម៉ី ចាន់បូ ហៅ បូ | សាខារោងពុម្ព | មន្ទីរអគ្គការ | ១៧-២-៧៧ | ២០-៦-៧៧ |
| ២៨៨៣ | ម៉ី សន ហៅ ឆាំ | អនុមន្ទីរសភា | មន្ទីរសភា | ?-២-៧៧ | ២០-៦-៧៧ |
| ២៨៨៤ | អេង គីមគេង ហៅ កែវ (ស្រី) | សមាជិក | កាត់ដេរវដ្ត | ៣-២-៧៧ | ២០-៦-៧៧ |
| ២៨៨៥ | គុណ ចុនថាណារៈ ហៅ ពេញ | យុទ្ធជន | រោងពុម្ព | ១៩-៣-៧៧ | ២០-៦-៧៧ |
| ២៨៨៦ | ឡៅ មាន ហៅ ឡោម | យុទ្ធជន | រោងពុម្ព | ១៤-៣-៧៧ | ២០-៦-៧៧ |
| ២៨៨៧ | ដៀង ភីកា ហៅ រិន | មេក្រុម | រោងពុម្ព | ៦-១០-៧៦ | ២០-៦-៧៧ |
| ២៨៨៨ | យូ ថាន់ ហៅ ផល | គណៈមន្ទីរ | រោងពុម្ព | ២៥-១០-៧៦ | ២០-៦-៧៧ |
| ២៨៨៩ | ឈុន ហែម ហៅ ស្រស់ | ធ្មើស្ថាន | ភូមិភាគឦសាន | ៥-១១-៧៦ | ២០-៦-៧៧ |
| ២៨៩០ | ឌី សយ ហៅ ម៉ាប់ | ប្រធានផ្នែក | រទេះភ្លើង | ២០-១២-៧៦ | ២០-៦-៧៧ |

**(នៅមានត)**

# គុកខ្មែរក្រហម

*(តពីលេខមុន)*

### ១២) មន្ទីរសន្តិសុខអូរលាច

មន្ទីរសន្តិសុខអូរលាចត្រូវបានបង្កើតឡើងនៅដើមឆ្នាំ១៩៧៦ រហូតដល់មន្ទីរសន្តិសុខនេះរលាយទៅវិញនៅចុងឆ្នាំ១៩៧៨ ។ មនុស្សជាច្រើននាក់បានត្រូវចោទប្រកាន់ពីបទប្រឆាំងនឹងអង្គការ ហើយត្រូវចាប់ខ្លួនបញ្ជូនមកកាន់មន្ទីរសន្តិសុខនេះ បន្ទាប់មកទើបនាំទៅសម្លាប់ចោលនៅទីតាំងព្រៃខ្មោច ។

មន្ទីរសន្តិសុខអូរលាចស្ថិតនៅក្នុងភូមិអូរលាច ឃុំបន្ទាយព្រាល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ មន្ទីរនេះជាមន្ទីរសន្តិសុខរបស់ស្រុក២០ (ស្រុករលាប្អៀរដើម) ។ អ្នកទោសដែលជាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខនេះមានបីប្រភេទ ។ អ្នកទោសជាប្រជាជន១៧មេសានិងប្រជាជនមូលដ្ឋានត្រូវបានបែងចែកជាអ្នកទោសធ្ងន់ និងស្រាល ហើយអ្នកទោសទាំងអស់ត្រូវធ្វើពលកម្មជាប្រចាំក្រោមការឃ្លាំមើលពីកងសន្តិសុខប្រចាំមន្ទីរ ។ ការងាររបស់អ្នកទោសធ្ងន់គឺកាស់គល់ឈើទាំងជើងជាប់ខ្នោះ ហើយអ្នកទោសស្រាលត្រូវកងឈ្លបដាក់ច្រវាក់ចាក់សោជាប់នឹងចង្កេះភ្ជាប់គ្នាពីបួនទៅប្រាំនាក់ក្នុងមួយខ្សែៗ រួចបណ្តើរទៅដាំដំឡូង កាប់ដីធ្វើចម្ការ និងភ្ជួរស្រែនៅតំបន់ឆ្ងាយៗពីមន្ទីរឃុំឃាំង ។ ចំណែកអ្នកទោសមួយប្រភេទទៀតជាអតីតកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទថាក្បត់បដិវត្តន៍ ។ អតីតប្រធានកងឈ្លបស្រុក២០របស់ខ្មែរក្រហម ឈ្មោះ សឿន ត្រូវបានចាប់ខ្លួនមកដាក់នៅក្នុងមន្ទីរសន្តិសុខអូរលាច ព្រោះរឿងខុសសីលធម៌ជាមួយនារី១៧មេសាម្នាក់រហូតដល់មានផ្ទៃពោះ ។ ខូយ ដែលជាអតីតកងឈ្លបប្រចាំនៅមន្ទីរសន្តិសុខអូរលាច បានលួចប្រាប់ នុន គួរ នៅជំនាន់ដែលគាត់បម្រើការងារក្នុងមន្ទីរសន្តិសុខថា នារី ដែល សឿន បានរួមមេត្រីជាមួយបានត្រូវ សឿន បញ្ជាឲ្យកងឈ្លបរបស់ខ្លួននាំយកទៅសម្លាប់ចោលដើម្បីកុំឲ្យបែកការណ៍ ។ ក្រៅពី សឿន នៅមានកម្មាភិបាលផ្សេងទៀតក៏ទទួលរងទណ្ឌកម្មដូចគ្នាដែរ ឲ្យតែអង្គការតាមដានទៅឃើញថា មានកំហុសទោះជាកំហុសនោះស្រាល ឬធ្ងន់ក៏ដោយ ។

មន្ទីរស្នូរចម្លើយមួយដែលគ្មាននរណាដឹងពីមុនមកសោះ បានត្រូវប្រជាជនរកឃើញបន្ទាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ព្រោះនៅមានសល់គុ កៅអី ខ្សែតី ដំបង ព្រនង់ ខ្នោះឈើជាច្រើន និងក្រដាសស្នាមផ្សេងៗ ដែលនៅរាយប៉ាយនិងគ្មានសណ្តាប់ធ្នាប់ក្នុងទីនោះ ។ នុន គួរ អាយុ៦៣ឆ្នាំ ជាអតីតប្រធានឃុំបន្ទាយព្រាល ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើននាក់ដែលបានឃើញហេតុការណ៍នេះ ។

រហូតមកដល់បច្ចុប្បន្ន អតីតមន្ទីរសន្តិសុខប្រចាំស្រុក២០ អូរលាចបានក្លាយទៅជាដីព្រៃគ្មានមនុស្សរស់នៅឡើយ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ អូរលាចស្ថិតនៅក្នុងភូមិអូរលាច ឃុំបន្ទាយព្រាល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** ៖ អូរលាចជាមន្ទីរសន្តិសុខរបស់ស្រុក២០ ។ មន្ទីរសន្តិសុខនេះមានឃុំឃាំងអ្នកទោសបីប្រភេទខុសគ្នាគឺ ប្រជាជនជម្លៀស ប្រជាជនមូលដ្ឋាន និងអតីតកម្មាភិបាលខ្មែរក្រហមដែលមានកំហុស ។ អ្នកទោសទាំងបីប្រភេទនេះមានចំនួនរាប់ពាន់នាក់ ហើយបានត្រូវខ្មែរក្រហមនាំយកទៅសម្លាប់នៅព្រៃខ្មោចទាំងអស់ ។

## ស្រុកសាមគ្គីមានជ័យ

### ១៣) មន្ទីរសន្តិសុខស្រែជ្រៅ

មន្ទីរសន្តិសុខបណ្តោះអាសន្នមួយរបស់ខ្មែរក្រហមឈ្មោះថា ស្រែជ្រៅ បានត្រូវបង្កើតឡើងនៅលើដីទួលខ្ពស់មួយមានវាលស្រែព័ទ្ធជុំវិញ ស្ថិតនៅក្នុងភូមិជិតាវជ្រែង ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

បិន ម៉េត ចៅអធិការវត្តក្រាំងល្វាបានមានពុទ្ធដីកាថា មន្ទីរសន្តិសុខបណ្តោះអាសន្នស្រែជ្រៅបានឃុំឃាំងមនុស្សជាច្រើនដែលត្រូវចោទប្រកាន់ពីបទឃុបឃិតជាមួយខ្មាំងប្រឆាំងនឹងបដិវត្ត ។ ព្រៃត្រពាំងអម្ពិល ដែលស្ថិតនៅក្បែរមន្ទីរសន្តិសុខស្រែជ្រៅ ជា

ទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហម ។ អ្នកទោសជាប្រជាជន និងយុទ្ធជនដែលកងឈ្លបបញ្ជូនមកពីភូមិ-ឃុំទូទាំងស្រុក និងពីសមរភូមិកំពង់ឆ្នាំង និងខេត្តផ្សេង ត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងអស់នៅក្នុងព្រៃត្រពាំងអម្ពិលនេះ ។ ចំណែកក្មេងតូចៗដែលរស់នៅជាមួយឪពុកម្តាយជាខ្មាំងរបស់អង្គការ ក៏ត្រូវកងឈ្លបខ្មែរក្រហមសម្លាប់ផ្តាច់ពូជដែរ ។ ប៊ិន ម៉េត និងប្រជាជនដទៃទៀតធ្លាប់ឃើញកងឈ្លបខ្មែរក្រហមយួរបង្វេចខោអាវ មុងភួយ កន្ទេលរបស់ប្រជាជនដែលខ្មែរក្រហមកុហកថាត្រូវទៅរៀនសូត្រ ត្រឡប់មកសហករណ៍វិញ ។ នរណាក៏ដឹងថាអ្នកទាំងនោះពិតជាត្រូវកងឈ្លបសម្លាប់អស់ហើយដែរ ។

សារិន ជាអតីតប្រធានមន្ទីរសន្តិសុខស្រែជ្រៅ និងជាអ្នកបញ្ជាឲ្យកងឈ្លបបំផុសឲ្យប្រជាជនទៅរៀនសូត្រ ។ តាឡាំង ជាអនុប្រធាន និង គួន ជាលេខាកត់ត្រា ។ ប៊ិន ម៉េត បានឲ្យដឹងទៀតថា អ្នកទោសជានារីភេទត្រូវកងឈ្លបខ្មែរក្រហមចាប់រំលោភសិន ទើបនាំយកទៅសម្លាប់ជាក្រោយ ។

## ទិន្នន័យសង្ខេប

**ទីតាំង** ៖ មន្ទីរសន្តិសុខស្រែជ្រៅស្ថិតនៅក្នុងភូមិជំទាវជ្រែង ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** ៖ ស្រែជ្រៅជាទីតាំងឃុំឃាំងមនុស្សបណ្តោះអាសន្នមួយ មុនពេលខ្មែរក្រហមនាំយកទៅសម្លាប់ចោលនៅព្រៃត្រពាំងអម្ពិល ។ អ្នកទោសរាប់សិបនាក់ត្រូវខ្មែរក្រហមសម្លាប់ក្រោមបញ្ជាផ្ទាល់របស់ សារិន ជាប្រធានសន្តិសុខ ឡាំង ជាអនុប្រធាន និង គួន ជាលេខា ។

## ១៤) មន្ទីរសន្តិសុខព្រៃដីស្រុត

មន្ទីរសន្តិសុខព្រៃដីស្រុត ត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៧០និងមានទីតាំងនៅក្នុងភូមិច្រកសង្កែ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ បន្ទាប់ពីថ្ងៃជ័យជម្នះរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរសន្តិសុខនេះត្រូវបានប្រែក្លាយឲ្យទៅជាមន្ទីរសន្តិសុខប្រចាំស្រុក១២ ។ រោងឃុំឃាំងអ្នកទោសមួយ បានសាងសង់ឡើងពីឈើប្រក់ស្លឹក គ្មានជញ្ជាំង និងមានទទឹងប្រហែល៧ម៉ែត្រ បណ្តោយប្រហែល២១ម៉ែត្រ ។ ក្រៅពីនេះនៅមានរោងមួយទៀតដែលកសាងរបៀបជាផ្ទះធ្វើពីឈើប្រក់ក្បឿងសម្រាប់ជាកន្លែងស្នាក់នៅរបស់កម្មាភិបាលខ្មែរក្រហម ។

មន្ទីរព្រៃដីស្រុត បានឃុំឃាំងអ្នកទោសជាច្រើននាក់ ដែលភាគច្រើនជាប្រជាជន១៧មេសា ។ អ្នកទោសត្រូវបានបែងចែកជាប្រភេទធ្ងន់ មធ្យម និងស្រាល ។ អ្នកទោសប្រភេទស្រាល គឺអ្នកមានកំហុសក្នុងការដាំស្រូវខុសពូជ ខុសសីលធម៌ និងធ្វេសប្រហែសពេលបំពេញការងារ ។ អ្នកទោសប្រភេទនេះមិនជាប់ឃុំឃាំងនៅក្នុងអគារគុកទេ ។ គឹម ពន ជាអតីតអ្នកទោសស្រាលនៅមន្ទីរសន្តិសុខព្រៃដីស្រុត បានរៀបរាប់រឿងរ៉ាវក្នុងពេលធ្វើការងារថា រៀងរាល់ថ្ងៃអ្នកទោសត្រូវភ្ញាក់នៅម៉ោង៥ព្រឹក ហើយចេញទៅធ្វើការនៅម៉ោង៦ព្រឹក ។ នៅម៉ោង១២ថ្ងៃត្រង់អ្នកទោសទាំងអស់បានសម្រាកដើម្បីហូបបបររាវៗ ។ ក្រោយពេលសម្រាកមួយម៉ោង អ្នកទោសទាំងនោះត្រូវចាប់ផ្តើមធ្វើការងារបន្តទៀតរហូតដល់ម៉ោង៥ល្ងាច ។ ចំណែកការងារពេលយប់ ចាប់ផ្តើមនៅពេលខែរះ ។ កងសន្តិសុខជាង១០នាក់ដែលប្រដាប់ដោយកាំភ្លើង និងរំពាត់វែងៗ បានឈរយាមអ្នកទោសពេលកំពុងធ្វើការ ។

អ្នកទោសប្រភេទមធ្យម និងប្រភេទធ្ងន់ ជាអតីតទាហានមន្ត្រីរាជការនៃរបបសាធារណរដ្ឋខ្មែរ និងអ្នកជាប់និន្នាការនយោបាយផ្សេងៗ ។ កងសន្តិសុខបានឲ្យអ្នកទោសប្រភេទនេះ ធ្វើការងារធ្ងន់ៗ ហើយជើងទាំងពីរត្រូវដាក់ខ្នោះជាប់រហូត ។ នៅក្នុងមន្ទីរឃុំឃាំងអ្នកទោសប្រភេទធ្ងន់ទាំងនេះត្រូវដេកជាពីរជួរ ដោយដាក់ជើងទល់គ្នា ។ ចំណែកក្មេងៗក៏ជាប់ឃុំឃាំងជាមួយឪពុកម្តាយដែលជាខ្មាំងរបស់អង្គការដែរ ។

ដោយសារតែធ្វើការងារហួសកម្លាំង គ្មានរបបអាហារគ្រប់គ្រាន់ និងរងការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ អ្នកទោសភាគច្រើនបានស្លាប់យ៉ាងវេទនា ហើយមានតែចំនួនតិចតួចប៉ុណ្ណោះដែលត្រូវកងឈ្លបខ្មែរក្រហមនាំយកទៅសម្លាប់ចោល ។ សាកសពអ្នកទោសមួយចំនួនត្រូវកងឈ្លបកាត់ផ្តាច់ជាពីរកំណាត់ ហើយជញ្ជូនយកទៅដាក់តាមចន្លោះរងដំឡូង និងតាមរណ្តៅដាំដើមដូង ។

គ្រូច គ្រុយ បានចង្អុលប្រាប់វាលស្មៅដែលមានស្នាមរណ្តៅដើមដូងស្ទើរតែលុបបាត់អស់ទៅហើយ ថាដើមដូង

ប្រហែល២០០ដើម ដែលដាំនៅក្នុងរបបខ្មែរក្រហមដោយមានកប់សាកសពមនុស្សនៅបាតរណ្តៅត្រូវរលុបបាត់អស់ដោយសារប្រជាជននៅជុំវិញតំបន់នោះបាននាំគ្នាគាស់យកទៅដាំនៅតាមផ្ទះរៀងៗខ្លួន ។ មេឃុំស្វាយជុក ក៏បានចូលរួមគាស់ដើមដូងចំនួន៣ដើមយកទៅដាំនៅផ្ទះរបស់គាត់ដែរ ។ រហូតមកដល់សព្វថ្ងៃដើមដូងទាំងប៉ុន្មានគឺនៅរស់ទាំងអស់ ។ គ្រុយ បានប្រាប់ថា អ៊ុលជាប្រធានមន្ទីរសន្តិសុខព្រៃដីស្រែគដំបូងគេ ហើយបន្ទាប់មកទៀតមាន សួន អែម និង សឿន ។ អែម បច្ចុប្បន្នរស់នៅភូមិត្បែងខ្ពស់ ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ ចំណែក អ៊ុល រស់នៅភូមិច្រេស ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ សួន ត្រូវប្រជាជនសម្លាប់ចោលបន្ទាប់ពីថ្ងៃរំដោះខែមករា ឆ្នាំ១៩៧៩ ។

ក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខព្រៃដីស្រែគត្រូវបានប្រជាជនរុះរើរកគារគុកគ្មានសល់ ។ មេឃុំស្វាយជុក ឈ្មោះ អុកទួន បានចង្អុលបង្ហាញពីបំណែកគ្រឿងតូចៗដែលនៅរាត់រាយពាសពេញដីថា នេះជាកន្លែងស្នាក់នៅរបស់កម្មាភិបាលខ្មែរក្រហមដែលមានភារកិច្ចមើលការខុសត្រូវរួមក្នុងមន្ទីរសន្តិសុខ ។ ចំណែកបរិវេណមន្ទីរសន្តិសុខទាំងមូលក៏គ្មានសេសសល់អ្វីបន្តិចបន្តួចដែរ ក្រៅតែពីទីលានរាបស្មើដែលមានស្មៅដុះជុំជិត និងដើមឈើធំមួយដើមប៉ុណ្ណោះ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** : មន្ទីរសន្តិសុខព្រៃដីស្រែគ ស្ថិតនៅក្នុងភូមិច្រកសង្កែ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** : មន្ទីរសន្តិសុខព្រៃដីស្រែគ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧០ ។ ក្រោយមកទៀត មន្ទីរសន្តិសុខនេះបានប្រែក្លាយទៅជាមន្ទីរសន្តិសុខប្រចាំស្រុក១២វិញ ។ អ្នកទោសជាច្រើននាក់បានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខនេះ ហើយត្រូវខ្មែរក្រហមបែងចែកជា៣ប្រភេទគឺ អ្នកទោសប្រភេទស្រាល មធ្យម និងធ្ងន់ ។ អ្នកទោសភាគច្រើនបំផុតបានស្លាប់ដោយសារការអត់អាហារ និងការលត់ដំធ្វើការខ្លាំងហួសប្រមាណ ។

## ស្រុកទឹកផុស

### ១៥) មន្ទីរសន្តិសុខវត្តសុវណ្ណេ

វត្តសុវណ្ណេស្ថិតនៅក្នុងភូមិស្រែគាជ័យ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង និងមានចម្ងាយប្រហែល៥០០ម៉ែត្រពីសាលាស្រុកទឹកផុសប៉ែកខាងកើត ។ ព្រះវិហារវត្តសុវណ្ណេត្រូវខ្មែរក្រហមជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខរបស់ខ្លួន ។ ទីតាំងសម្លាប់អ្នកទោសគឺនៅជុំវិញព្រះវិហារតែម្តង ។ អ្នកទោសច្រើនណាស់សុទ្ធសឹងជាប្រជាជនត្រៀមដែលត្រូវកងឈ្លបដឹកយកមកសម្លាប់នៅក្នុងបរិវេណវត្តសុវណ្ណេនេះ ដោយពុំមានឆ្លងកាត់ការឃុំឃាំងឡើយ ។ ជនរងគ្រោះភាគច្រើនជាទាហានរបបសាធារណរដ្ឋខ្មែរដែលត្រូវខ្មែរក្រហមសម្លាប់នៅក្នុងអំឡុងឆ្នាំ១៩៧៥-៧៦ និងយុទ្ធជនសេរីរបស់ភូមិភាគបូព៌ាដែលត្រូវសម្លាប់នៅឆ្នាំ១៩៧៨ ។ ក្រៅពីនេះ នៅមានជនរងគ្រោះរាប់សិបនាក់ទៀតដែលជាប្រជាជនសាមញ្ញ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** : វត្តសុវណ្ណេស្ថិតនៅក្នុងភូមិស្រែគាជ័យ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** : ព្រះវិហារវត្តសុវណ្ណេ ត្រូវបានជ្រើសរើសយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោស ។ អ្នកទោសភាគច្រើនដែលសុទ្ធសឹងជាប្រជាជនត្រៀម ដែលត្រូវខ្មែរក្រហមនាំយកមកសម្លាប់នៅក្នុងបរិវេណវត្តសុវណ្ណេ ដោយពុំមានដាក់ឃុំឃាំងឡើយ ។ នៅឆ្នាំ១៩៧៥-៧៦ អ្នកទោសជាទាហានរបបសាធារណរដ្ឋត្រូវបានសម្លាប់ និងនៅឆ្នាំ១៩៧៨ អ្នកទោសជាយុទ្ធជនភូមិភាគបូព៌ាក៏ត្រូវបានសម្លាប់ក្នុងលក្ខណៈដូចគ្នាដែរ ។

**ទិន្នន័យកុំព្យូទ័រ** : រយៈកម្ពស់ (N) 13º 03' 10:87", រយៈទទឹង (E) 104º 31' 72:97", និងលេខកូដ (ID No.) 040802 ។

### ១៦) មន្ទីរសន្តិសុខអូរស្ពាន ហៅ ធ្លកជ្រុំ

តាំងពីឆ្នាំ១៩៧៥រហូតដល់ចុងឆ្នាំ១៩៧៨ មន្ទីរសន្តិសុខដែលមានឈ្មោះថា "មន្ទីរសន្តិសុខអូរស្ពាន ឬ ធ្លកជ្រុំ" ត្រូវខ្មែរក្រហមកសាងឡើងនៅចំកណ្តាលព្រៃជ្រៅមួយកន្លែងដើម្បីឃុំឃាំងអ្នកទោស ។ ជនរងគ្រោះជាច្រើនរយនាក់ត្រូវខ្មែរក្រហមបែងចែកឲ្យស្នាក់អាស្រ័យក្នុងរោងដែលសង់នៅក្នុងព្រៃនោះ ។

មុនដំបូង ប្រជាជនទាំងអស់ត្រូវកំណត់ឲ្យរស់នៅដោយឡែកពីគ្នា ទាំងការហូបចុក និងដេកពួន ។ ប៉ុន្តែយូរៗទៅ ការរស់

នៅកន្លែងនោះត្រូវបានរឹតបន្តឹងរហូតដល់មានការហូបរួម ដេករួម និងមានដាក់ខ្នោះឈើដែលធ្វើឡើងជាខ្សែៗផង ។ តានិន និង តាបេះ ត្រូវប្រជាជនស្គាល់ច្បាស់ថា ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខនេះតាំងពីដើមរហូតមក ។ ប៉ុន្តែក្រោយមកត្រូវស្លាប់ទាំងអស់នៅពេលដែលកងទ័ពវៀតណាមចូលវាយរំដោះប្រទេសកាលពីឆ្នាំ១៩៧៩ ។

ស៊ុំ រឿន បានប្រាប់ថា ប្រជាជនដែលជាប់នៅក្នុងមន្ទីរសន្តិសុខអូរស្ពាន ភាគច្រើនជាអ្នកមកពីទីក្រុងភ្នំពេញ ខេត្តកំពង់ចាម ស្វាយរៀង និងអ្នកធ្វើប្រវត្តិរូបដែលដាក់ថាធ្លាប់ធ្វើជាគ្រូបង្រៀន ទាហាន ប៉ូលិស និងបញ្ញវន្ត ។ ឈឹម ខាត់ ដែលជាប្រធានភូមិរលុង ឃុំទួលខ្ពស់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង បានរៀបរាប់ថា ចំណែកអ្នកមូលដ្ឋានវិញ ទាល់តែអ្នកនោះមានកំហុសធ្ងន់ដូចជា លួចដំឡូង ខ្ជិលច្រអូសក្នុងការងារ ធ្លាប់មានបងប្អូនធ្វើទាហានពីសង្គមចាស់ ទើបត្រូវចាប់បញ្ជូនទៅកាន់ទីនោះ ។ ខាត់ បន្តថា ឪពុករបស់គាត់ត្រូវកោះហៅឲ្យទៅកាន់មន្ទីរសន្តិសុខអូរស្ពាន ដើម្បីអប់រំពីមាគ៌ាបដិវត្តន៍ ប៉ុន្តែរហូតមកដល់សព្វថ្ងៃ ឪពុករបស់គាត់ នៅតែមិនឃើញត្រឡប់មកវិញសោះ ។ ខាត់ សន្និដ្ឋានថា ឪពុករបស់គាត់ត្រូវខ្មែរក្រហមសម្លាប់រួមជាមួយប្រជាជនជាច្រើននាក់ទៀត ។ ការសម្លាប់នេះបានចាប់ផ្តើមតាំងពីឆ្នាំ១៩៧៥ម្ល៉េះ ។ រណ្តៅជាច្រើន ត្រូវអ្នកទោសជីកនៅតាមចន្លោះដើមឈើទាំងធំទាំងតូច ។ មនុស្សភាគច្រើនមិនបានដឹងពីការសម្លាប់មនុស្សការចាប់មនុស្សឃុំឃាំងនៅទីតាំងមន្ទីរសន្តិសុខអូរស្ពាននេះឡើយ ព្រោះជាផែនការសម្ងាត់របស់ខ្មែរក្រហម ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏រឿងរ៉ាវទាំងអស់ត្រូវលាតត្រដាងឡើងបន្ទាប់ ពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដោយអ្នកឃ្វាលគោក្របីនៅក្បែរៗ នោះបានរកឃើញទីតាំងនេះ ហើយក៏លេចឮពីមាត់មួយទៅមាត់ មួយទូទាំងស្រុកទឹកផុស ។

ស៊ុំ រឿន បានដឹងយ៉ាងច្បាស់ថានេះជាទីតាំងឃុំឃាំងនិងសម្លាប់មនុស្ស ព្រោះគាត់ធ្លាប់ឃើញខ្មែរក្រហមដឹកមនុស្សចូលទៅក្នុងទីតាំងក្រាំងត្នោត ហើយក្រោយបែកឆ្នាំ១៩៧៩ គាត់ធ្លាប់បានចូលទៅពិនិត្យដោយផ្ទាល់ថែមទៀត ។ ចំណែក សៅ ចិន បានដឹងតាំងពីដំបូងថាមានការសម្លាប់មនុស្សនៅក្រាំងត្នោតនិងនៅអូរស្ពាន ព្រោះគាត់ធ្លាប់ត្រូវកងឈ្លបខ្មែរក្រហមនាំចូលទៅកាន់កន្លែងសម្លាប់នោះ ។ សៅ ចិន បានឃើញរណ្តៅជាច្រើនដែលនៅឃ្លាតពីគ្នា២ទៅ ៣ម៉ែត្រ ។ សៅ ចិន រំឭកថាគាត់ត្រូវខ្មែរក្រហមនាំទៅមើលការសម្លាប់មនុស្សដោយផ្ទាល់ ប៉ុន្តែគាត់បង្ខំចិត្តវិលត្រឡប់មកផ្ទះវិញ ព្រោះមិនអាចទប់ចិត្តបាន ។


វត្តចំប៉ា ឬវត្តសេរីតេជះ ក្នុងភូមិចក ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

រហូតមកដល់បច្ចុប្បន្ន រណ្តៅទាំងប៉ុន្មានត្រូវរលុបស្ទើរតែទាំងអស់ ដោយសារទឹកភ្លៀង និងទឹកដែលហូរធ្លាក់ពីលើកំពូលភ្នំឱរ៉ាល់ លើកលែងតែរណ្តៅធំពីរប៉ុណ្ណោះដែលនៅមានសល់ស្លាកស្នាមនៅឡើយ ។ កម្ទេចកម្ទីឆ្អឹងក៏នៅមានក្នុងរណ្តៅទាំងពីរនេះដែរ ។ កែ រួន ជានាយរង នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំក្បាលទឹកបានរៀបរាប់ថា ប៉ុន្មានឆ្នាំមុន (មុនឆ្នាំ២០០០) គាត់សង្កេតឃើញមានរណ្តៅនិងឆ្អឹងច្រើនជាងនេះ ។ ក្រោយឆ្នាំ១៩៧៩ អតីតមន្ទីរសន្តិសុខនេះត្រូវប្រជាជនរុះរើខ្ទេចខ្ទី ហើយរហូតមកដល់ពេលនេះពុំមានបន្សល់វត្ថុតាងអ្វីបន្តិចបន្តួចឡើយ ។

## ទិន្នន័យសង្ខេប

**ទីតាំង** ៖ អូរស្ពានហៅធ្លកជ្រុំ ស្ថិតនៅក្នុងទឹកដីឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

***ស្ថិតិ*** ៖ មន្ទីរសន្តិសុខអូរស្ពាន ឬថ្លុកជ្រៃ បានកសាងឡើងនៅឆ្នាំ១៩៧៥ ក្នុងព្រៃជ្រៅមួយក្បែរជើងភ្នំឱរ៉ាល់ ។ អ្នកទោសច្រើនណាស់ដែលត្រូវខ្មែរក្រហមនាំទៅកាន់មន្ទីរសន្តិសុខនេះ ហើយក្រោយមក ត្រូវបានសម្លាប់ទាំងអស់ ។ មន្ទីរសន្តិសុខនេះត្រូវប្រជាជនរុះរើគ្មានសល់នៅក្រោយឆ្នាំ១៩៧៩ ។ រណ្តៅជាច្រើនត្រូវរលុបបាត់ស្ទើរតែទាំងអស់ដោយសារទឹកភ្លៀងនិងទឹកធ្លាក់ពីលើភ្នំឱរ៉ាល់ហូរនាំដីល្បាប់មកចាក់ ។ លើកលែងតែរណ្តៅចំនួនពីរប៉ុណ្ណោះដែលនៅមានរូបរាងនៅឡើយ ។

## ១៧) មន្ទីរសន្តិសុខនៅវត្តមង្គលខាន់

ក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ភ្លាម វត្តមង្គលខាន់បានត្រូវអង្គការជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងប្រជាជន១៧មេសាជាច្រើននាក់ ដែលត្រូវខ្មែរក្រហមជម្លៀសឲ្យមកស្នាក់នៅក្នុងបរិវេណវត្តមង្គលខាន់នេះ ។ រោងតូចៗជាច្រើនកន្លែងដែលត្រូវប្រជាជនជម្លៀសមកដល់ក្រោយៗសាងសង់ឡើងបន្ទាប់ពីសាលាឆាន់ ព្រះវិហារ និងកុដិនានាក្នុងទីវត្តទាំងមូល ។ ក្រោយមកមិនយូរប៉ុន្មាន ប្រជាជនទាំងអស់ដែលជម្លៀសមកពីទីក្រុងភ្នំពេញ កំពង់ចាម ស្វាយរៀង និងកន្លែងដទៃទៀតមកដាក់ឲ្យស្នាក់នៅក្នុងបរិវេណវត្តមង្គលខាន់ ត្រូវបាននាំយកទៅសម្លាប់ចោលទាំងអស់នៅខាងជើងភ្នំកញ្ជើបាយ ។

តាំ រី បានប្រាប់ថា ព្រឹត្តិការណ៍នេះកើតឡើងនៅក្នុងឆ្នាំ១៩៧៧ ។ ចាប់ពីដើមឆ្នាំ១៩៧៨ មន្ទីរសន្តិសុខវត្តមង្គលខាន់បានឃុំឃាំងអ្នកទោសជាអតីតកងទ័ពរបស់ សោ ភឹម ដែលត្រូវចោទថាក្បត់នឹងអង្គការ ។ កងទ័ពខ្មែរក្រហមខាងភូមិភាគបូព៌ាជាច្រើននាក់ត្រូវកងសន្តិសុខដឹកមកកាន់វត្តមង្គលខាន់ ដើម្បីអប់រំកសាងខ្លួនជាថ្មី ។ កុដិ ព្រះវិហារ និងរោងធំតូចជាច្រើនទៀត គឺជាជម្រករបស់អ្នកទាំងនោះ ។ មិនយូរប៉ុន្មាន រថយន្តធំៗដែលមានដំបូលបិទបាំងយ៉ាងជិតដោយក្រណាត់កៅស៊ូ បានមកដឹកអ្នកទោសទាំងនោះទៅកាន់ប៉ែកខាងជើងភ្នំកញ្ជើបាយដើម្បីសម្លាប់ចោល ។ តាំ រី បានឃើញក្បួនរថយន្តដឹកអ្នកទោសនៅពេលដែលគាត់កំពុងឃ្វាលគោក្បែរនោះ ។ កងទ័ពខ្លះបានដើរពីក្រោយរថយន្តក្នុងឯកសណ្ឋានកងទ័ពភូមិភាគបូព៌ា ។ នៅទីបញ្ចប់ ជីវិតកងទ័ពទាំងនោះត្រូវបានសម្លាប់ដោយគ្មាននរណាម្នាក់រួចខ្លួនឡើយ ។

ក្នុងចំណោមឃាតករពីរនាក់ដែលទទួលបន្ទុកសម្លាប់មនុស្សនៅវត្តមង្គលខាន់មានម្នាក់ឈ្មោះ សេក ប៉ាន ហៅ ង៉ែត ព្រិល ដែលប្រជាជនស្គាល់ច្បាស់ថា សព្វថ្ងៃមានទីលំនៅនៅភូមិរការទង ឃុំទួលខ្ពស់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង គឺនៅជិតវត្តមង្គលខាន់តែម្តង ។ ចំណែកម្នាក់ទៀតគ្មានប្រជាជនណាបង្ហើបឲ្យដឹងឈ្មោះឡើយ ។ តាំ រី ប្រាប់ថា ប៉ាន ជាប្រធានកងឈ្លបប្រចាំឃុំទួលខ្ពស់ ដែលបានបញ្ជាឲ្យកងឈ្លបរបស់គាត់សម្លាប់អ្នកទោសនៅវត្តមង្គលខាន់នេះ ។ ឃាតករម្នាក់ទៀតដែល រី មិនបានបញ្ចេញឈ្មោះគឺជាអ្នកទទួលបញ្ជាផ្ទាល់ពី“ប៉ាន”ឲ្យយកអ្នកទោសទៅសម្លាប់ ។ រី បន្តទៀតថា ប៉ាន ជាមនុស្សស្អប់ខ្ពើមជនជាតិចាមខ្លាំងណាស់ ។

នៅក្រោមដើមអម្ពិលដូរមួយដើមធំស្ថិតនៅចំហៀងខ្ទមរបស់ ប៉ាន គាត់បាននិយាយប្រាប់ថា គាត់បានរត់ទៅកាន់ស្រុកអន្លង់វែងតាំងពីឆ្នាំ១៩៧៩ ហើយបានត្រឡប់មកកាន់ស្រុកកំណើតវិញនៅឆ្នាំ១៩៩៨ ។ ដោយរស់នៅក្នុងជីវភាពដុនដាប ប៉ាន បាននិយាយប្រាប់ពីប្រវត្តិការងាររបស់គាត់កាលពីជំនាន់ខ្មែរក្រហម ហើយបានបញ្ជាក់ថា ថ្វីត្បិតតែគាត់មិនដែលបានឃើញមុខ តាម៉ុក ឬយាយម៉ែន យ៉ាងណាក៏ដោយ ប៉ុន្តែគាត់ធ្លាប់ទទួលបញ្ជាពីពួកគាត់យកមកអនុវត្តដែរ ។

តាំ រី រំឭកថា នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និង១៩៩០ គាត់បានវាយប្រយុទ្ធជាមួយកងទ័ពរបស់ ប៉ាន ជាញឹកញាប់ណាស់ព្រោះ ប៉ាន ជាកងទ័ពស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់ តាម៉ុក កាលពី តាម៉ុក មិនទាន់ត្រូវចាប់ខ្លួន ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅខែមករាឆ្នាំ១៩៧៩ មន្ទីរសន្តិសុខវត្តមង្គលខាន់ក៏ត្រូវរដ្ឋអំណាចរំលាយចោល ។ រោងតូចធំដែលសង់ឡើងដោយអ្នកទោសត្រូវប្រជាជនរុះរើគ្មានសល់ ។ អគារចាស់ៗដែលនៅសេសសល់ពីការបំផ្លាញរបស់ខ្មែរក្រហម និងទីធ្លាត្រូវបានជួសជុល និងបោសសម្អាតឡើងវិញទាំងអស់ ។ នៅប៉ែកខាងក្រោយវត្តមង្គលខាន់ មានតែរណ្តៅពីរ-បីប៉ុណ្ណោះដែលនៅសល់ស្លាកស្នាមខ្លះៗ ។ ចំណែករណ្តៅដទៃជាច្រើនទៀតត្រូវប្រជាជនលុបដីទៅវិញ បន្ទាប់ពីបានគាស់កកាយដើម្បីរកមាស ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ វត្តមង្គលខាន់ ស្ថិតនៅក្នុងភូមិវត្ត ឃុំទួលខ្ពស់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** ៖ ប្រជាជន១៧មេសា និងកងទ័ពខ្មែរក្រហមខាងភូមិភាគបូព៌ាជាច្រើនពាន់នាក់ ត្រូវខ្មែរក្រហមចាប់បញ្ជូនទៅកាន់បរិវេណវត្តមង្គលខាន់ដើម្បីអប់រំកែប្រែ ហើយក្រោយមកត្រូវបានសម្លាប់ទាំងអស់នៅខាងក្រោយវត្តមង្គលខាន់និងនៅខាងជើងភ្នំកញ្ជើបាយ ។ ឈ្មោះឃាតករពីរនាក់ត្រូវប្រជាជនបង្ហើបឲ្យដឹងតែម្នាក់ប៉ុណ្ណោះគឺឈ្មោះ សេក ប៉ាន ហៅ ង៉ែត ព្រិល ។

**១៨) មន្ទីរសន្តិសុខភ្នំអង្គ**

មន្ទីរសន្តិសុខនិងទីតាំងសម្លាប់មួយ ត្រូវខ្មែរក្រហមបង្កើតឡើងនៅចន្លោះភ្នំអង្គនិងភ្នំតូច ដើម្បីឃុំឃាំងអ្នកទោសកម្រិតធ្ងន់ក្នុងចំណោមមន្ទីរឃុំឃាំងពីរគឺវិទ្យាល័យ ទឹកផុស និងភ្នំកញ្ជាំង ។ នៅឆ្នាំ១៩៧៧ មន្ទីរសន្តិសុខនេះ ល្បីរន្ទឺពេញស្រុកទឹកផុស ថាជាកន្លែងដែលមានវិន័យតឹងរឹងបំផុត ។ អ្នកទោសត្រូវកងឈ្លបដាក់ខ្នោះជាប់ជាជៀងរាល់យប់ ។ ពេលបន្ទោរបង់ម្តងៗទើបកងឈ្លបដោះខ្នោះចេញ ហើយដាក់ខ្នោះដោយខ្លួនឯងវិញ នៅពេលបន្ទោរបង់រួចរាល់ហើយ ។ ហេង យ៉ុន បាននិយាយថា ប្រសិនបើអ្នកទោសណាម្នាក់ហ៊ានរត់ចេញពីគុកអ្នកទោសឯទៀតច្បាស់ជាត្រូវឈ្លបនាំយកទៅសម្លាប់ចោលទាំងអស់មិនខាន ។ ដោយសារតែមនោសញ្ចេតនាអាណិតគ្នាទៅវិញទៅមក យ៉ុន បញ្ជាក់ថា គ្មានអ្នកទោសណាម្នាក់ហ៊ានធ្វើដូច្នេះឡើយ ។ ក្នុងការសម្រាកពេលយប់អ្នកទោសជាបុរស និងស្ត្រីត្រូវបានបែងចែកដោយឡែកពីគ្នា ។ នៅពេលថ្ងៃអ្នកទោសត្រូវកងឈ្លបបណ្តើរទៅធ្វើការដោយពុំមានដាក់ខ្នោះឡើយ ។ ការងាររបស់អ្នកទោស គឺធ្វើស្រែ ដាំដំឡូង និងកាប់ឆ្ការព្រៃនៅខាងជើងភ្នំអង្គ ។ យ៉ុន ជាអ្នកទោសម្នាក់ដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំអង្គអស់រយៈពេល៩ខែ ។ យ៉ុន ជាប់គុកដោយសារតែប្តីរបស់គាត់ជាកម្មាភិបាលខ្មែរក្រហមដែលក្បត់នឹងអង្គការ ។ ប្តីរបស់ យ៉ុន ឈ្មោះ ណុន ជាអតីតប្រធានឃុំខ្នងពពក ស្រុកទឹកផុសក្នុងអំឡុងឆ្នាំ១៩៧៥-៧៦ ។ ណុន ត្រូវសមាជិកកងឈ្លបឃុំខ្នងពពកចាប់ខ្លួនយកទៅដាក់គុកកាលពីឆ្នាំ១៩៧៧ នៅពេលដែលប្រពន្ធរបស់គាត់(យ៉ុន)កំពុងឆ្លងទន្លេនៅមន្ទីរពេទ្យឃុំ ។ យ៉ុន មិនបានដឹងពីការចាប់ខ្លួនប្តីរបស់គាត់ឡើយ ។ ក្រោយឆ្លងទន្លេរួចបាន ១០ថ្ងៃ យ៉ុន ក៏ត្រូវចាប់ខ្លួនដែរ ហើយនាំយកទៅដាក់នៅមន្ទីរសន្តិសុខភ្នំកញ្ជាំងអស់រយៈពេលមួយខែរួចបញ្ជូនបន្តទៅដាក់នៅមន្ទីរសន្តិសុខវិទ្យាល័យទឹកផុសអស់រយៈពេលជាង៦ខែទៀត ទើបនៅចុងបញ្ចប់គាត់ត្រូវផ្ទេរមកដាក់មន្ទីរឃុំឃាំងនៅភ្នំអង្គវិញ ។ កូនរបស់ យ៉ុន ត្រូវពេទ្យឃុំយកទៅចិញ្ចឹមហើយនៅមានជីវិតរហូតដល់សព្វថ្ងៃ ។ នៅក្នុងមន្ទីរសន្តិសុខភ្នំអង្គ យ៉ុន បានទទួលរងទារុណកម្មយ៉ាងសាហាវជាមួយនឹងអ្នកទោសដទៃជាង១០០នាក់ទៀត ។ អ្នកទោសទាំងនេះ ត្រូវកងសន្តិសុខដាក់ឃុំឃាំងនៅក្នុងរោងជាច្រើនដែលសាងសង់ជាប់ៗគ្នា ។ យ៉ុន បានជាប់ឃុំឃាំងនៅភ្នំអង្គអស់រយៈពេលជាង៩ខែ ។ អ្នកទោសថ្មីៗជាច្រើនត្រូវបានបញ្ជូនចូលមកជាហូរហែ ។ យ៉ុន ធ្លាប់ឮសូរសំឡេងស្រែកគំហកខ្លាំងៗនៅពេលកងឈ្លបសួរចម្លើយម្តងៗ ។ យ៉ុន បានបន្ថែមទៀតថា នៅខាងជើងភ្នំអង្គ មានរណ្តៅច្រើនរាប់មិនអស់ ប៉ុន្តែសព្វថ្ងៃត្រូវរលាយអស់ហើយ ដោយសារតែការរានដីធ្វើស្រែរបស់ប្រជាជន ។ ជនរងគ្រោះជាច្រើននាក់ត្រូវខ្មែរក្រហមសម្លាប់ ហើយខ្លះទៀតស្លាប់ដោយជំងឺហើម និងការធ្វើទារុណកម្ម ។ យ៉ុន បាននិយាយថា មន្ទីរសន្តិសុខភ្នំអង្គជាកន្លែងលត់ដំធ្ងន់ធ្ងរបំផុតក្នុងទូទាំងស្រុកទឹកផុស ។ អ្នកទោសភាគច្រើនជាកម្មាភិបាលខ្មែរក្រហមនៅភូមិភាគបូព៌ា ។ គន់ គឺជាជនដៃដល់ម្នាក់ក្នុងចំណោមជនដៃដល់ផ្សេងៗទៀតនៅមន្ទីរសន្តិសុខភ្នំអង្គ ។ យ៉ុន ត្រូវ គន់ វាយធ្វើបាបដោយសារតែបានលួចលាក់សណ្តែកលីងមួយកំប៉ុង ។ រហូតមកដល់សព្វថ្ងៃនេះ គន់ នៅមានជីវិតនៅឡើយ និងមានទីលំនៅខាងក្រោយវត្តខ្នងពពក ។ នៅចុងឆ្នាំ១៩៧៨ យ៉ុន និងនារីៗជាង២០នាក់ទៀតត្រូវបានដោះលែងឲ្យចេញពីមន្ទីរសន្តិសុខភ្នំអង្គ ។ ចំណែកអ្នកទោសប្រុសៗត្រូវកងឈ្លបនាំទៅសម្លាប់ទាំងអស់ ។

មន្ទីរសន្តិសុខភ្នំអង្គទាំងមូលត្រូវអ្នកស្រុកដុតបំផ្លាញ និងរុះរើខ្ទេចខ្ទី ហើយគ្មាននៅសេសសល់អ្វីជាវត្ថុតាងឡើយនៅក្រោយឆ្នាំ១៩៧៩ ។ ប៉ុន្តែ យ៉ុន ឧស្សាហ៍និយាយរឿងរ៉ាវនេះប្រាប់កូនរបស់គាត់ណាស់ តាំងពីកូនគាត់នៅរៀនសាលាបឋម

សិក្សារហូតមកដល់សព្វថ្ងៃ ។ ប្តីទីពីររបស់ យ៉ុន ជាអតីតកងទ័ពខ្មែរក្រហមម្នាក់ ។ កំពូលភ្នំអង្គ ជាកំពូលភ្នំដែល យ៉ុន មើលឃើញព្រឹកល្ងាចនាពេលបច្ចុប្បន្ននេះ ។ យ៉ុន និយាយថា ពេលក្រឡេកមើលកំពូលភ្នំនេះម្តងៗ ធ្វើឲ្យគាត់នឹកឃើញរឿងរ៉ាវទាំងអស់ដែលកើតឡើងចំពោះគាត់ កាលពីសម័យខ្មែរក្រហម ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ ភ្នំអង្គ ស្ថិតនៅក្នុងភូមិស្វាយចេក ឃុំចោងម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** ៖ ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខធំជាងគេមួយនៅស្រុកទឹកផុសចន្លោះភ្នំអង្គ និងភ្នំតូច ដើម្បីឃុំឃាំងអ្នកទោសកម្រិតធ្ងន់បំផុត ដូចជាអតីតកម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ាជាដើម ។ មន្ទីរសន្តិសុខនេះត្រូវរលាយបាត់រូបនៅឆ្នាំ១៩៧៩ ជាមួយនឹងជីវិតអ្នកទោសរាប់រយនាក់ ។



ការចង្អុលបង្ហាញទីតាំងគុកចុងជ្រោយ ក្នុងភូមិឈើគ្រាច ឃុំកោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

## ១៩) មន្ទីរសន្តិសុខវិទ្យាល័យទឹកផុស

វិទ្យាល័យទឹកផុស ត្រូវខ្មែរក្រហមបង្កើតឲ្យទៅជាមន្ទីរសន្តិសុខនៅឆ្នាំ១៩៧៥ ដើម្បីឃុំឃាំងអ្នកទោសកម្រិតធ្ងន់ទី២ នៅស្រុកទឹកផុស ។ អ្នកទោសត្រូវកងឈ្លបបណ្តើរទាំងខ្សែៗ ទៅដាក់ឃុំឃាំងនៅក្នុងបរិវេណវិទ្យាល័យនេះ ហើយក្រោយមកត្រូវកងឈ្លបសម្លាប់ចោលគ្មានសល់ ។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ឈប់ការសម្លាប់អ្នកទោសនៅមន្ទីរសន្តិសុខនេះ ដោយអ្នកទោសទាំងអស់ត្រូវផ្ទេរទៅកាន់មន្ទីរសន្តិសុខភ្នំអង្គវិញ ។ យ៉ុន ជាអ្នកដាំបាយ និងជាអ្នកទោសនៅមន្ទីរសន្តិសុខវិទ្យាល័យទឹកផុស ។ នៅឆ្នាំដដែលនេះ ប្តីរបស់ យ៉ុន ត្រូវបានចាប់ខ្លួនពីបទក្បត់នឹងអង្គការ ហើយឪពុកម្តាយក្មេករបស់ យ៉ុន ក៏ត្រូវកងឈ្លបចាប់ខ្លួនមកដាក់ឃុំឃាំងនៅវិទ្យាល័យទឹកផុសដែរ ។ ក្រោយមក ឪពុកម្តាយក្មេករបស់គាត់ត្រូវកងឈ្លបសម្លាប់នៅក្នុងវិទ្យាល័យទឹកផុស ។

ក្រោយឆ្នាំ១៩៧៧ វិទ្យាល័យទឹកផុសនៅតែមានឈ្មោះ ជាមន្ទីរឃុំឃាំងដដែលបន្ទាប់ពីផ្ទេរទៅភ្នំអង្គក៏ដោយ ។

ក្រោយឆ្នាំ១៩៧៩ អគារទាំងអស់ត្រូវបានជួសជុលឡើងវិញ និងប្រែក្លាយទៅជាវិទ្យាល័យប្រចាំស្រុកទឹកផុសដូចដើម ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ វិទ្យាល័យទឹកផុសស្ថិតនៅក្នុងភូមិរមាស ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** ៖ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជ្រើសយក វិទ្យាល័យទឹកផុសធ្វើជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងអ្នកទោស ។ នៅក្នុងឆ្នាំដដែលនេះ អ្នកទោសរាប់រយនាក់ត្រូវកងឈ្លបសម្លាប់ ។ នៅឆ្នាំ១៩៧៧ មន្ទីរសន្តិសុខនេះ ត្រូវបានរំលាយចោលបន្ទាប់ពីអ្នកទោសទាំងអស់ត្រូវកងឈ្លបបញ្ជូនទៅកាន់មន្ទីរសន្តិសុខភ្នំអង្គ ។

**ផេង ពង្សរ៉ាស៊ី**

# ទីតាំងសោកនាដកម្ម

ក្នុងឆ្នាំ១៩៧៧ ប៉ូ ដែលកាលនោះមានអាយុ៥៨ឆ្នាំ ត្រូវបានកម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ ខុន ហៅទៅធ្វើការនៅខាងតំបន់ខាងលិចក្នុងខណៈពេលដែលគាត់កំពុងតែបរទេះគោ ។ ប៉ូ មិនមានការភ្ញាក់ផ្អើលទេនៅពេលឮថាគាត់ត្រូវបានអង្គការខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការនៅតំបន់ផ្សេងក្រៅពីសហករណ៍របស់គាត់ ពីព្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជនរងគ្រោះគ្រប់រូបតែងត្រូវអង្គការបញ្ជូនទៅធ្វើការកន្លែងផ្សេងៗពីគ្នាជាញឹកញាប់ ។ ក្រោយពេលចេញផុតពីសហករណ៍បានបន្តិច ប៉ូ បានឃើញមនុស្សទាំងហ្វូងមកពីសហករណ៍ផ្សេងៗក្នុងស្រុកកណ្តាលស្ទឹង ធ្វើដំណើរទៅជាមួយគ្នាសំដៅទៅទីតាំងតែមួយ ។

ប៉ូ ធ្វើដំណើរទៅតំបន់ខាងលិចជាមួយមនុស្សជាច្រើនទៀត ដោយមានបង់កក្រមានិងសម្លៀកបំពាក់មួយកំប្លេង ។ មនុស្សជាច្រើនបានធ្វើដំណើរទៅមុខដោយមិនដឹងថាតំបន់ខាងលិចនោះមានទីតាំងនៅត្រង់ណាពិតប្រាកដឡើយ ។


ប៉ុក ប៉ូ ក្នុងឆ្នាំ២០០៥

ប៉ូ ធ្វើដំណើរកាត់តាមផ្លូវជាតិលេខ២ឆ្ពោះទៅភូមិត្រពាំងស្វាយ ដែលជាទីតាំងគុកខ្មែរក្រហមមួយឈ្មោះថា គុកសង់ ។ ប៉ូ មិនដឹងថាគាត់នឹងត្រូវបញ្ជូនទៅគុកសង់ទេ ។ ពេលទៅដល់ប្រហែលពាក់កណ្តាលផ្លូវ សន្តិសុខបានប្រាប់អ្នកដំណើរទាំងអស់ឲ្យឈប់មួយកន្លែងដើម្បីរៀបចំឲ្យពួកគេដើរជាជួរដោយមានសន្តិសុខនៅយាមទាំងសងខាងនិងមុខក្រោយ ។ នៅចម្ងាយប្រហែល៥០០ម៉ែត្រពីគុក ប៉ូ បានឃើញកងសន្តិសុខខ្មែរក្រហមជាច្រើននាក់បំពាក់ដោយអាវុធគ្រប់ដៃរង់ចាំនៅទីនោះរួចជាស្រេច ហើយដកកាំភ្លើងភ្ជង់ បន្ទាប់មកកងសន្តិសុខខ្មែរក្រហមប្រាប់ឲ្យអ្នកដំណើរទាំងអស់ក្រាបផ្ទាល់ដីហើយស្រែកព្រមគ្នាថា“អាខ្មាំងក្រាបៗ” ។

សន្តិសុខខ្មែរក្រហមបានលើកកាំភ្លើងភ្ជង់តម្រង់ ធ្វើឲ្យអ្នកធ្វើដំណើរទាំងអស់ភ័យខ្លាចយ៉ាងខ្លាំង ហើយនាំគ្នាក្រាបទៅលើដីទាំងអស់គ្នា ។ ពេលនោះសន្តិសុខខ្មែរក្រហមម្នាក់បានមកជាន់ជើងរបស់ ប៉ូ ហើយបានទាញក្រមាចេញពីករបស់គាត់ដើម្បីយកមកចងដៃរបស់ ប៉ូ ទៅក្រោយ ចំណែកអ្នកផ្សេងទៀតក៏ត្រូវខ្មែរក្រហមចងដៃដែរ ។ ចំពោះអ្នកដែលគ្មានក្រមា សន្តិសុខបានយកក្រមាពីករបស់ខ្លួនមកចងជំនួស ។ ប៉ូ និយាយថា សន្តិសុខខ្មែរក្រហមចងស្លាបសេកគាត់យ៉ាងណែនស្ទើរតែងើបក្រោកឈរមិនរួច ។ ក្រោយពេលចងរួច សន្តិសុខបានភ្ជង់កាំភ្លើងនិងបណ្តើរគាត់និងអ្នកផ្សេងទៀតឆ្ពោះទៅកាន់គុកសង់ ។ គាត់ត្រូវសន្តិសុខនាំយកទៅដាក់ក្នុងបន្ទប់ធំមួយដែលកន្លែងនោះគាត់បានឃើញខ្នោះជើងជាច្រើនមានទំហំផ្សេងៗពីគ្នាដែលគេទុកនៅក្នុងបន្ទប់ធំនោះ ។ សន្តិសុខខ្មែរក្រហមបានបញ្ជាឲ្យ ប៉ូ រើសខ្នោះជើងនោះមកពាក់ខ្លួនឯងដោយមិនឲ្យរលុងពេកឬចង្អៀតពេក ។ ប៉ូ ត្រូវបានដាក់ខ្នោះក្នុងបន្ទប់រួមមួយដែលក្នុងមួយជួរៗមានអ្នកទោសដេកតម្រៀបគ្នាប្រហែលជា៣០នាក់ ។

នៅព្រលប់ថ្ងៃនោះ សន្តិសុខគុកបានយកបបររាវៗមកចែកឲ្យគាត់និងអ្នកទោសដទៃទៀត ។ ប៉ូ បានរៀបរាប់ទិដ្ឋភាពកាលពីពេលនោះថាគាត់ឃ្លានខ្លាំងណាស់ ពោះរបស់គាត់កូរគ្រុកៗ តែ គាត់មិនហ៊ានស្នើសុំបបរថែមទេ ។ មកដល់ទីនោះ ប៉ូ នៅតែមិនដឹងថា ហេតុអ្វីបានជាគាត់ត្រូវខ្មែរក្រហមបញ្ជូនមកទីនោះ?

បីបួនថ្ងៃក្រោយមក ប៉ូ ត្រូវសន្តិសុខគុកបញ្ជូនទៅដាក់ក្នុងបន្ទប់តូចមួយ ដែលនៅក្នុងនោះគាត់បានឃើញតុមួយនិងកៅអីមួយ ។ សន្តិសុខនោះបានឲ្យ ប៉ូ អង្គុយលើកៅអី បន្ទាប់មកដាក់ខ្នោះជើងទាំងពីរនិងចងដៃទាំងពីរទៅក្រោយ រួចដើរចេញទៅក្រៅបាត់ ។ មួយសន្ទុះក្រោយមក សន្តិសុខនោះត្រឡប់មកវិញហើយស្រាយចំណងចេញ រួចចាប់ផ្តើមសួរនាំគាត់ ។ ប៉ូ បានរំឭកថា សន្តិសុខនោះចងដៃគាត់ទៅក្រោយយ៉ាងតឹង គាត់សឹងតែផុតដង្ហើមទៅហើយ ។ សន្តិសុខនោះបានសួរគាត់ថា “មុននិងពេលគេយកមកហ្នឹង មានដឹងកំហុសរបស់ខ្លួនទេ?” ប៉ូ ឆ្លើយថា

គាត់ធ្លាប់ធ្វើទាហាន លន់ នល់ ដោយសុីឈ្មោះទាហានដែលស្លាប់ ។ ចម្លើយនេះ មិនធ្វើឲ្យអ្នកសួរចម្លើយពេញចិត្តទេ ។ អ្នកសួរចម្លើយនោះសួរទៀតថា ធ្លាប់មានការពាក់ព័ន្ធជាមួយខ្មែរសឬអត់? ប៉ូ ឆ្លើយថា គាត់ធ្លាប់ឮពីបញ្ហាខ្មែរសដែរ ប៉ុន្តែគាត់មិនជឿថាមានខ្មែរសទេ ។ សន្តិសុខនោះបានបង្ហាញចម្លើយសារភាពរបស់ ផាត ។ ផាត បានរៀបរាប់ឈ្មោះមិត្តភក្តិរបស់គាត់ដែលគាត់និយាយអំពីខ្មែរសឲ្យស្តាប់ក្នុងនោះមាន ប៉ូ ម្នាក់ដែរ ។

ប៉ូ រំឭកថា ផាត បានឃើញទង់សមួយនៅសហករណ៍ ហើយក៏យកដំណឹងនេះមកប្រាប់គាត់ថាមានខ្មែរស ។ ផាត ក៏ត្រូវបញ្ជូនមកដាក់នៅគុកសង់ក្រោយពីដំណឹងនេះលេចឮដល់កម្មាភិបាលខ្មែរក្រហម ហើយ ប៉ូ ក៏ត្រូវបញ្ជូនទៅគុកសង់ដោយសារតែចម្លើយសារភាពរបស់ ផាត ដែរ ។

ក្រោយៗមកទៀត ប៉ូ ត្រូវបានចាត់តាំងឲ្យធ្វើការងារជាច្រើនដូចជា ធ្វើស្រែ វែកដី កាប់ឈើ និងគាស់គល់ជាដើម ។ ប៉ូ បានរៀបរាប់ថា រាល់ថ្ងៃពេលធ្វើការអ្នកទោសទាំងអស់ត្រូវដាក់ខ្នោះជាប់គ្នាពីរៗនាក់ ដោយឃ្លាតពីគ្នាប្រមាណជាមួយម៉ែត្រ ។ ប៉ូ នៅចាំអ្នកទោសម្នាក់ដែលជាប់គុកជាមួយគាត់ឈ្មោះ ប៉ុន ។ ប៉ុន មានជំងឺប្រមេះនោមចេញមកតិចៗ ហើយគាត់តែងសុំការអនុញ្ញាតពីសន្តិសុខទៅនោមជាញឹកញាប់ ។ ប៉ុន ត្រូវសន្តិសុខធ្វើទារុណកម្មជាច្រើនលើកដោយចោទថាធ្វើពុត ហើយ ប៉ូ ក៏ត្រូវខ្មែរក្រហមធ្វើទារុណកម្មដូច ប៉ុន ដែរ ដោយចោទថា សមគំនិតគ្នា ។ ក្រោយមកទើបសន្តិសុខនោះដឹងថា ប៉ុន មានជំងឺប្រមេះ ។

ប៉ូ ឲ្យដឹងទៀតថា ខ្មែរក្រហមបានវាយគាត់ខ្លាំងនៅពេលអ្នកទោសដែលដេកក្បែរគាត់បានលួចរបស់របរពីថ្ងៃទៅហូបនៅពេលយប់ ។ ជួនពេលដែលសន្តិសុខគុកទៅឃើញអ្នកទោសដែលនៅក្បែរគ្នានោះហូបគាត់ក៏ត្រូវទទួលទារុណកម្មទាំងអស់គ្នា ។ ប៉ូ ត្រូវខ្មែរក្រហមវាយនឹងដងចបចំឆ្អឹងជំនីរ ហើយមានរបួសយ៉ាងធ្ងន់ធ្ងរ ។

ជួនយប់ខ្លះ សន្តិសុខគុកបានដុតកៅស៊ូកង់ដើម្បីបំភ្លឺស្ថានភាពនៅក្នុងគុកក្រែងមានអ្នកទោសណាម្នាក់លួចដោះខ្នោះចេញពីជើង ។ សន្តិសុខខ្មែរក្រហមបានសម្រក់កៅស៊ូដែលឆេះនោះទៅលើជើងអ្នកទោសធ្វើឲ្យមានការឈឺចាប់យ៉ាងខ្លាំង ។ ជើងរបស់ ប៉ូ មានស្លាកស្នាមជាច្រើនដោយការសម្រក់ជ័រកៅស៊ូនេះ ។

អស់រយៈពេលជាងមួយឆ្នាំនៅតំបន់ខាងលិច ប៉ូ បានទទួលនូវការឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្តស្ទើរតែមិនអាចបរិយាយបាន ។ ប៉ូ បង្ហាញជើងទាំងគូរបស់គាត់ដែលពោពេញទៅដោយស្លាកស្នាមបណ្តាលមកពីការសម្រក់កៅស៊ូរបស់សន្តិសុខខ្មែរក្រហមនៅគុកសង់ ហើយស្លាកស្នាមនៅលើឆ្អឹងជំនីរដែលខ្មែរក្រហមធ្វើទារុណកម្មគាត់ បានធ្វើឲ្យគាត់គ្រាំគ្រារហូតដល់សព្វថ្ងៃនេះ ។

ទោះជាយ៉ាងណា ប៉ូ នៅតែមិនមានអារម្មណ៍ចង់សងសឹងចំពោះអតីតសន្តិសុខខ្មែរក្រហមដែលធ្លាប់ធ្វើបាបគាត់ទេ ។ ប៉ូ បានបន្ទោសទៅលើខ្មែរក្រហមថ្នាក់ក្រោមដែលល្ងិតល្ងង់ ហើយធ្វើតាមតែតាមបញ្ជាគេ ។ ប៉ូ និយាយថា “មកពីគេ [ថ្នាក់ដឹកនាំខ្មែរក្រហម] បញ្ជាគាត់ពីលើមក ម៉្លោះហើយគាត់ [កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម] អត់សូវយល់ដឹងហើយធ្វើតែតាមបញ្ជា ។ ខ្ញុំមិនចង់សងសឹកទេ ដោយខ្ញុំយល់ថា គាត់ [កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម] និងខ្ញុំជាខ្មែរដូចគ្នា តែគាត់អត់យល់ ម៉្លោះហើយខ្ញុំមិនខឹងនឹងគាត់ទេ ។ គាត់អត់សូវចេះ អត់សូវយល់ ម៉្លោះហើយគាត់ចេះតែធ្វើតាមអ្វីដែលគេបង្គាប់” ។

**ញាណ សុជាតិ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

## ជា សឿន និងប្តីឈ្មោះ ថោង គឿន
## អតីតជាធាហាន លន់ នល់

ខ្ញុំជាមនុស្សអត់បានរៀនសូត្រទេ ពីព្រោះឪពុកម្តាយខ្ញុំជាអ្នកក្រ ។ ខ្ញុំត្រូវជួយធ្វើស្រែចម្ការគាត់ ។ ស្រុកកំណើតខ្ញុំនៅរការកោង នៅភូមិដើមជ្រៃ ឃុំរការកោង៧ ស្រុកមុខកំពូល ខេត្តកណ្តាល ។ ពេលខ្ញុំអាយុ១៨ឆ្នាំ មានបុរសម្នាក់ចូលស្តីដណ្តឹងខ្ញុំរៀបការ ហើយឪពុកម្តាយខ្ញុំក៏យល់ព្រមលើកខ្ញុំឲ្យទៅបុរសនោះដោយសារគាត់ជាអ្នកភូមិជាមួយខ្ញុំ ។


ជា សឿន

ប្តីរបស់ខ្ញុំឃើញខ្ញុំដំបូងនៅពេលខ្ញុំដើរទៅមុជទឹកនៅមាត់ទន្លេ ។ ពេលនោះជាពេលល្ងាច គាត់សម្រាកពីការងារ ។ គាត់អង្គុយលំហែកាយនៅមាត់ទន្លេ ហើយក៏ឃើញខ្ញុំ ។ គាត់ចេះតែលួចមើលនិងតាមដាននូវរាល់សកម្មភាពរបស់ខ្ញុំទាំងនៅផ្ទះនិងពេលចេញពីផ្ទះ ។ ខ្ញុំមិនដឹងថាគាត់លួចមើលខ្ញុំតាំងពីពេលណាទេ ។ ដោយការពេញចិត្ត គាត់បានចូលមកជួបឪពុកម្តាយរបស់ខ្ញុំ សុំស្តីដណ្តឹងខ្ញុំរៀបការតាមប្រពៃណី ។ ដំបូងឪពុកខ្ញុំមិនយល់ព្រមទេ ពីព្រោះគាត់មកដណ្តឹងខ្ញុំតែម្នាក់ឯង ។ ប្តីខ្ញុំបានហៅបងប្អូនរបស់គាត់ និងពឹងពាក់ចាស់ទុំនៅក្បែរផ្ទះរបស់គាត់ធ្វើជាមេបាដើម្បីចូលស្តីដណ្តឹងខ្ញុំម្តងទៀត ។ ឪពុកខ្ញុំក៏យល់ព្រមលើកខ្ញុំឲ្យគាត់ ។

ក្នុងថ្ងៃរៀបការ ខ្ញុំពាក់អាវដែលខ្ញុំបានកាត់នៅក្នុងពិធីកាត់សក់ ។ ចំណែកសំពត់ចងក្បិននិងរបស់របរប្រើប្រាស់ផ្សេងៗទៀតគឺជារបស់អ្នកជួង ។ មុនពេលរៀបការ ខ្ញុំអ៊ុតសក់ ពីព្រោះសម័យនោះអត់មានសក់ពាក់ទេ ។ ផ្កាដែលសៀតនៅលើក្បាលជាតំណាងឲ្យភាពស្រស់ស្អាត ។ ដោយសារសក់ខ្ញុំខ្លីប្អូនមិនកើតអ្នកជួងជជុះៗសក់ខ្ញុំ ហើយលើកសក់ឡើងទៅលើដោយសៀតផ្កាពីចំហៀង ។ ខ្ញុំត្រូវប្តូរសម្លៀកបំពាក់ជាច្រើនម៉ូតទៅតាមពណ៌សម្បុររបស់ខ្ញុំ ។

រូបថតឈរមួយនេះថតនៅពេលយើងទទួលភ្ញៀវនៅផ្ទះការ ។ ភ្ញៀវខាងប្រុសមកសុំយើងថត ហើយអ្នកទាំងនោះជាអ្នកធ្វើការជាមួយប្តីរបស់ខ្ញុំ ។

រូបថតមួយទៀតថតនៅក្នុងពិធិកាត់សក់ ។ ខ្ញុំថតជាមួយឪពុកម្តាយរបស់ខ្ញុំ និងកូនកំលោះ ប៉ុន្តែរូបនោះរលុបអស់ខ្លះហើយ ។ ពេលបានរូបថតមក ខ្ញុំចែកឲ្យបងប្អូនខាងប្តីនិងបងប្អូនខាងខ្ញុំ ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំមិនបានយករូបថតទាំងនោះទៅតាមខ្ញុំទេ ។ រូបថតនេះខ្ញុំបានពីបងប្រុសរបស់ខ្ញុំដែលជាអ្នករក្សាទុក ។ រូបថតខ្លះមានស្នាមកណ្តុរកកេរ ។

ប្តីខ្ញុំរៀនបានដល់ថ្នាក់ឌីប្លូម ។ ក្រោយពេលរៀនចប់គាត់ចូលធ្វើជាទាហានលន់ នល់ ប៉ុន្តែគាត់ធ្វើការតែនៅក្នុងបន្ទាយជាគណនេយ្យករ ។ ក្រុមគ្រួសារគាត់មានជីវភាពធូរធារ ។ គាត់ជាកូនពៅក្នុងចំណោមបងប្អូន៤នាក់ ។ បងស្រីទី១ ស្លាប់ក្នុងរបបប៉ុលពត ប្តីរបស់គាត់អតីតជាទាហានលន់ នល់ នៅស្វាយដូនកែវ ។ បងស្រីទី២ រស់នៅថ្មគោលក្នុងខេត្តបាត់ដំបង ប្តីរបស់គាត់ជាអ្នកធ្វើស្រែ ។ បងទី៣ ជាបងប្រុសនៅលីវ ធ្វើទាហាននៅខេត្តព្រៃវែង ។ គាត់ស្លាប់នៅក្នុងរបបសង្គមរាស្ត្រនិយម ។ ឪពុកម្តាយរបស់គាត់ស្លាប់បាត់បង់ជីវិតតាំងពីគាត់នៅកុមារភាព ។ ប្តីខ្ញុំអាយុច្រើនជាងខ្ញុំប្រហែលជាង១០ឆ្នាំ ហើយគាត់មានមាឌល្អិត ប៉ុន្តែគាត់នៅក្មេង ។

ក្រោយពេលរៀបការ ខ្ញុំលក់ផ្លែឈើនិងបន្លែនៅផ្សាររការកោង ។ មួយរយៈក្រោយមក ខ្ញុំឈប់លក់ដូរ ហើយមកធ្វើជាមេផ្ទះវិញ ។ប្តីខ្ញុំពូកែសន្សំលុយណាស់ ។ គាត់ជិះកង់ទៅធ្វើការរាល់ថ្ងៃ ។

នៅក្នុងរបបលន់ នល់ ស្រុកកំណើតរបស់យើងមានការច្បាំងគ្នារវាងកងទ័ពរំដោះ និងទាហានលន់ នល់ ។ ប្តីខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅតាខ្មៅ ។ នៅទីនោះមានកន្លែងឲ្យយើងស្នាក់នៅ ហើយគាត់ធ្វើការនៅកន្លែងគេអូធំ និងមានយុវនារីម្នាក់ទៀតជាប្រធានគេអូ ។ គាត់ដឹងថានៅក្នុងស្រុកយើង កន្លែង

ណាក៏មានការច្បាំងគ្នាដែរ ព្រោះគាត់ឮព័ត៌មានតាមគេអូមកពីតាមបណ្តាខេត្តនានា ។ នៅតាខ្មៅខ្ញុំមានកូនពីរនាក់នៅក្នុងបន្ទុក ។ ផ្ទះនៅតាខ្មៅដែលយើងរស់នៅ គឺជាផ្ទះដែលរដ្ឋចែកឲ្យ ហើយផ្ទះនោះសង់នៅក្នុងបន្ទាយទាហាន ។

នៅឆ្នាំ១៩៧៤ យើងផ្លាស់ទៅរស់នៅបន្ទាយទាហាននៅទួលទំពូង ពីព្រោះសភាពការណ៍នៅតាខ្មៅកាន់តែតានតឹងឡើងៗ ។ ខ្មែរក្រហមផ្លោងចូលបន្ទាយតាខ្មៅ ។ យើងក៏បានផ្លាស់ទៅរស់នៅទួលទំពូងជាមួយពីរគ្រួសារផ្សេងទៀត ជាទាហានដែលមានឋានៈខ្ពង់ខ្ពស់ដែរ ។ យើងរស់នៅទួលទំពូងរហូតដល់ទីក្រុងភ្នំពេញត្រូវបានកាន់កាប់ដោយខ្មែរក្រហម ។ មុនពេលបែកភ្នំពេញ ប្តីខ្ញុំប្រាប់ថា រៀបចំរបស់របរឲ្យហើយទៅ ព្រោះសភាពការណ៍មិនស្រួលទេ ។ ប្តីខ្ញុំមានកាំភ្លើងខ្លីមួយដើមទុកគ្រាន់តែការពារខ្លួនប៉ុណ្ណោះ ។ ពេលខ្ញុំឮប្តីខ្ញុំនិយាយអំពីសភាព-ការណ៍ក្នុងប្រទេស ខ្ញុំភ័យណាស់ ។ ខ្ញុំគិតថាខ្ញុំប្រហែលជាមិនបានជួបមុខឪពុកម្តាយនិងសាច់ញាតិខ្ញុំនៅឯស្រុកកំណើតទៀតទេ ។ ខ្ញុំដាច់ការទាក់ទងជាមួយអ្នកទាំងនោះតាំងពីខ្ញុំចាកចេញមកជាមួយប្តីខ្ញុំម្ល៉េះ ។

នៅថ្ងៃទី១៧ខែមេសាឆ្នាំ១៩៧៥ ខ្មែរក្រហមប្រកាសប្រាប់ប្រជាជនថា ក្នុងរយៈពេល៣ថ្ងៃត្រូវចេញឲ្យផុតពីទីក្រុង ព្រោះយន្តហោះអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក ។ ខ្មែរក្រហមបញ្ជាក់ថា ការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ពីព្រោះអង្គការត្រូវការបោសសម្អាតខ្មាំង ។ ពេលនោះខ្ញុំមិនជឿថាយើងត្រូវចេញទៅតែ៣ថ្ងៃនោះទេ ខ្ញុំដឹងថាយើងប្រាកដជាស្លាប់ ។ ខ្មែរក្រហមប្រាប់ទៀតថា មិនបាច់យកអាហារទៅទេ ព្រោះនៅទីនោះមិនខ្វះហូបឡើយ ។ ខ្ញុំដាក់ទឹកស៊ីអ៊ីវបីដប ឆ្នាំងមួយ អង្ករខ្លះ


ជា សឿន ក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍

និងចានពីរបី ។ ខ្ញុំដុតរបស់របរនិងឯកសារផ្សេងៗដែលពាក់ព័ន្ធជាមួយប្តីខ្ញុំនៅពេលដែលខ្ញុំជម្លៀសចេញពីភ្នំពេញ ព្រោះខ្ញុំខ្លាចរបស់ទាំងនោះបង្កបញ្ហាដល់យើង ។

នៅតាមផ្លូវ ខ្មែរក្រហមសួរយើងថាគ្រួសារខ្ញុំធ្វើអី? ខ្ញុំប្រាប់ថាប្តីខ្ញុំធាក់ស៊ីក្លូ ។ យើងពកូនដើរអស់រយៈពេលជាច្រើនខែទម្រាំតែទៅដល់ស្រុកកំណើតរហូតដល់ជើងរបស់ខ្ញុំដំបៅរលួយ ។ កូនរបស់ខ្ញុំម្នាក់ស្លាប់នៅតាមផ្លូវដោយសារអាកាសធាតុក្តៅពេកនិងគ្មានអាហារហូបគ្រប់គ្រាន់ ។ ពេលចេញពីភ្នំពេញ ប្តីរបស់ខ្ញុំស្លៀកពាក់ជាស៊ីវិលដើម្បីកុំឲ្យខ្មែរក្រហមដឹងថាគាត់ជាទាហាន ។

ពេលមកដល់ស្រុកកំណើតដំបូង ខ្ញុំស្ទូងស្រូវ ដាំពោត ប៉ុន្តែផលដែលប្រមូលបានអង្គការមិនឲ្យយើងហូបទេ ។ ប្តីរបស់ខ្ញុំធ្វើការងារដូចខ្ញុំដែរ ។ ទោះបីជាយើងមិនចេះក៏ដោយយើងត្រូវតែធ្វើ។ យើងអត់មានអាហារហូបគ្រប់គ្រាន់ទេ ។ ខ្ញុំយកគល់ចេកហាន់ស្តើងៗស្ងោរឲ្យផុយសម្រាប់ហូប ។ ពេលហូបហើយយើងក្អួតចេញមកវិញទាំងអស់ ។ ខ្ញុំអាណិតប្តីនិងកូនខ្ញុំណាស់ តែមិនដឹងធ្វើយ៉ាងម៉េចបើយើងអត់មានអីហូបទាំងអស់គ្នា ។

នៅភូមិរបស់ខ្ញុំ ខ្មែរក្រហមបានដឹងអំពីប្រវត្តិរូបគ្រួសារយើង ។ គ្មានអ្នកណាមករករឿងឪពុករបស់ខ្ញុំទេ ។ ខ្ញុំរស់នៅជុំគ្នាជាមួយបងប្អូនទាំងអស់ ។ នៅពេលអង្គការចុះឈ្មោះម្តងៗអ្នកភូមិតែងជួយលាក់ប្រវត្តិរូបរបស់ខ្ញុំ ។ ក្រោយមក អង្គការជម្លៀសយើងចេញពីទីនោះ ព្រោះយើងជាប្រជាជន១៧មេសា ដូច្នេះយើងត្រូវរស់នៅជាមួយអ្នក១៧ដូចគ្នា ។

ខ្មែរក្រហមជម្លៀសគ្រួសាខ្ញុំទៅតាមទន្លេប្អូនមុខ ។ ពេលយើងឡើងកាណូតចេញពីផ្ទះខ្ញុំអត់មានបាយហូបទេ ។ ខ្ញុំកាប់

ចេកអំបូងស្ងោរទុកហូបតាមផ្លូវ ។ យើងធ្វើដំណើរទៅតាមផ្លូវព្រៃកក្តាម ។ ទៅដល់ព្រៃកក្តាមយើងសម្រាកនៅទីនោះសិន ។ យើងធ្វើដំណើរបន្តតាមរទេះភ្លើងឆ្ពោះទៅខេត្តពោធិសាត់ទៀត ។ យើងបានរបបអង្ករម្នាក់១កំប៉ុង ។ នៅតាមផ្លូវយើងមិនដឹងថាអង្គការឲ្យយើងទៅទីណាទេ ។

ពេលយើងធ្វើដំណើរទៅដល់ភូមិពោធិ ស្រុកបាកាន ខេត្តពោធិសាត់ ខ្ញុំនិងប្រជាជន៤០០គ្រួសារដែលជាអ្នកមកពីភ្នំពេញ ខេត្តកណ្តាល និងស្វាយរៀងត្រូវខ្មែរក្រហមយកទៅដាក់នៅក្នុងព្រៃដែលសំបូរដោយឆ្កែចចក ។ ខ្ទមរបស់យើងគឺក្រាលដោយដើមព្រិច ជញ្ជាំងក៏ដើមព្រិចនិងដំបូលប្រក់ស្លឹកត្នោត ។ ប្រជាជនទាំងនោះចេះតែបាត់ខ្លួនជាបន្តបន្ទាប់ ។ យប់ឡើងអង្គការមកហៅប្រជាជនទៅទន្លេសាប ។ ឈ្លបបានយកប្រជាជនទៅដាក់នៅក្នុងបន្ទប់មួយរួចចាក់សាំងដុត ។ យើងលបមើលឃើញផ្ទាល់ភ្នែក ។ កន្លែងនោះមានមនុស្សស្លាប់ច្រើនណាស់ ។ អ្នកខ្លះមានកូន៣នាក់ឱបជាប់ខ្លួន ។ អ្នកខ្លះទៀតស្រែករកម្តាយឲ្យជួយ ហើយអ្នកខ្លះទៀតស្រែករកប្រពន្ធរកកូន ។ ប្រជាជនដែលទៅពីខេត្តស្វាយរៀងភាគច្រើនស្លាប់ដោយសារអង្គការចោទប្រកាន់ថាជាជនជាតិវៀតណាម ។ ការសម្លាប់នេះធ្វើឡើងនៅប្រហែលជាម៉ោង៣រសៀល ។


ជា សឿន ក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍

នៅពេលប្រជុំម្តងៗ អង្គការបានសួរប្រវត្តិរូបយើងជាញឹកញាប់អំពីការងារពីមុនមក ។ យើងឆ្លើយថាធ្វើកសិករ ។ អង្គការពិសោធន៍យើងដោយឲ្យយើងចុះអនុវត្តការងារផ្ទាល់ ។ យើងចេះតែធ្វើការទៅទោះបីចេះឬមិនចេះក៏ត្រូវធ្វើដែរ ។

គ្រួសារខ្ញុំរស់នៅជុំគ្នា ។ បីថ្ងៃយើងមានប្រជុំម្តង ហើយនៅក្នុងអង្គប្រជុំ អង្គការនិយាយតែពីរឿងការងារធ្វើស្រែ ។ បើអ្នកណាធ្វើការងារសកម្មនឹងបានទទួលកាកបបរពីរវែក ។ បើអ្នកណាធ្វើការមិនសកម្ម បានតែកាកបបរមួយវែកនិងទឹកពីរវែកប៉ុណ្ណោះ ។ មួយថ្ងៃ យើងបានរបបពីរពេលគឺ ពេលថ្ងៃត្រង់ និងពេលល្ងាច តែយើងហូបមិនឆ្អែតទេ យើងបេះស្លឹកដំឡូងមកស្ងោរលាយជាមួយបបរហូប ។ ពេលខ្លះយើងបេះកញ្ឆែត ឬស្លឹកល្ងៀងយកមកស្លម្ល ។

អង្គការចាត់តាំងឲ្យខ្ញុំបេះបន្លែ ។ ខ្ញុំដើរក្នុងទឹកត្រឹមៗជង្គង់ ហើយឈ្លើងតាមខ្ញុំ ។ ចំណែកប្តីខ្ញុំ ត្រូវចាត់តាំងឲ្យទៅរកខស និងមើលគោនៅភូមិក្បែរៗកន្លែងខ្ញុំរស់នៅ ។ មិត្តភក្តិរបស់ប្តីខ្ញុំម្នាក់ឈ្មោះ ម៉េន ដែលធ្វើការជាមួយគាត់ដែរ ត្រូវអង្គការចាប់ខ្លួន ។ ម៉េន បានប្រាប់អង្គការថា ប្តីខ្ញុំធ្វើទាហានស័ក្តិ៥ ហើយ ម៉េន សួរអង្គការថា ហេតុអ្វីបានជាមិនចាប់ប្តីខ្ញុំដែរ?

ក្រោយពី ម៉េន រាយការណ៍ អង្គការបានមកចាប់ខ្លួនប្តីខ្ញុំតែម្តង ។ ម៉ោងប្រហែល៥ល្ងាច ឈ្លបបានមកហៅប្តីខ្ញុំ ឈ្លបនោះប្រាប់ថាមិត្តឯងចុះពីលើផ្ទះមកមិនបាច់យកមុងយកភួយទេ ព្រោះទៅកន្លែងនោះស៊ីក៏ស្រួល ដេកក៏ស្រួលដែរ ។ ចេញផុតពីផ្ទះបានបន្តិចឈ្លបក៏ចងបណ្តើរគាត់ទៅ ។ ខ្ញុំឃើញឈ្លបបណ្តើរប្តីខ្ញុំទៅដោយផ្ទាល់ភ្នែកពេលនោះគាត់មិនទាន់បានហូបបាយផង ។ ខ្ញុំប្រាប់គាត់ថាកុំទៅខ្លួនទទេ យកក្រមាទៅទុកគ្រាន់ដណ្តប់ពេលយប់ ។ ឈ្លបនោះប្រាប់ថា មិនបាច់យកក្រមាទៅទេ នៅទីនោះមានមុងដេកហើយ ។ ឈ្លបសម្តុតខ្ញុំថាបីបួនថ្ងៃទៀតនឹងមកយកខ្ញុំឲ្យទៅនៅជុំគ្នាហើយ ។ យប់ឡើងប្តីខ្ញុំរត់មករកខ្ញុំវិញ ។ គាត់ប្រាប់ខ្ញុំថាអង្គការឲ្យមកផ្ទះសិន ។ ខ្ញុំថាបើគេឲ្យមក បើមានបំណងចង់រត់ទៅខាងណាទៀតក៏វាមិនរួចដែរ ។ គាត់ថាអាណិតខ្ញុំពេក ព្រោះខ្ញុំពោះធំជិតឆ្លងទន្លេហើយ ។ ខ្ញុំប្រាប់គាត់ថា

កុំគិតពីខ្ញុំច្រើនពេកគិតពីខ្លួនឯងផង ។ ប្តីខ្ញុំត្រូវឈ្លបវាយឡើងជាំមុខ ។ ខ្ញុំនិយាយជាមួយគាត់ថា បើសិនអង្គការចាប់បានម្តងទៀតពិតជាស្លាប់ហើយ ។ តាមពិតឈ្លបមកលបស្តាប់យើងជជែកគ្នានៅក្រោមផ្ទះ ។ ខ្ញុំអត់ហ៊ានយំទេ ។ នៅពាក់កណ្តាលអធ្រាត្រ ឈ្លបចាប់គាត់យកទៅវិញ ហើយក៏មិនឃើញគាត់ត្រឡប់មកវិញរហូត ។ ស្អែកឡើងអង្គការហៅខ្ញុំទៅប្រជុំ ដោយយកនាឡិកា ដែកកេះ ស្បែកជើង ក្រមា មកបោះដាក់លើតុប្រជុំ ។ ខ្ញុំស្គាល់ច្បាស់ថា របស់ទាំងអស់នេះជារបស់ប្តីខ្ញុំ ពេលនោះទើបខ្ញុំដឹងថា ប្តីរបស់ខ្ញុំត្រូវអង្គការសម្លាប់ហើយ ។ ប្រធានកងស្ត្រីលួចខ្សឹបប្រាប់ខ្ញុំថា អង្គការសម្លាប់ប្តីខ្ញុំហើយ ហើយកប់នៅតាមផ្លូវដែលខ្ញុំដើរទៅធ្វើការរាល់ថ្ងៃ ។ ប្រធានកងនោះលួងលោមខ្ញុំកុំឲ្យគិតច្រើនពេក ប្រឹងតែធ្វើការឲ្យល្អទៅ ព្រោះខ្លាចអង្គការយកទៅសម្លាប់ចោលទាំងអស់គ្នា ។

ក្រោយពេលអង្គការយកប្តីខ្ញុំទៅបានកន្លះខែ ខ្ញុំកើតបានកូនស្រីម្នាក់ ។ ខ្ញុំបានបងស្រីម្នាក់ ដែលចេញពីព្រែកតាទែនជាមួយជួយបង្កើតកូនឲ្យខ្ញុំ ព្រោះគាត់ធ្លាប់ធ្វើពេទ្យកាលពីសង្គមចាស់ ។ ខ្ញុំឆ្លងទន្លេបាន១០ថ្ងៃ អង្គការឲ្យខ្ញុំទៅដាក់បាយជ្រូកនិងធ្វើការងារតាមការកំណត់របស់អង្គការ ។ ក្រោយមកខ្ញុំឈឺទាស់ឡើងស្គមខ្លួន ដោយសារជ្រូកធ្វើឲ្យខ្ញុំដួលក្នុងពេលដាក់បាយ ។ ទោះបីជាខ្ញុំកូនខ្ចីឈឺទាស់យ៉ាងម៉េចក៏ដោយក៏ខ្ញុំនៅតែប្រឹងធ្វើការងារដែរ ។ ប្រធានកងបានជួយរកថ្នាំឲ្យខ្ញុំផឹក ហើយខ្ញុំក៏បានជាឡើងវិញ ។ កូនខ្ញុំកើតបានតែ៣ខែប៉ុណ្ណោះ វាក៏ស្លាប់ដោយសារកង្វះជីវជាតិ ។

កូនរបស់ខ្ញុំទាំងអស់៣នាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ កូនខ្ញុំម្នាក់ស្លាប់នៅតាមផ្លូវ និងម្នាក់ទៀតស្លាប់ពេលធ្វើការនៅកងកុមារកើបអាចម៍គោ (ប្រធានកងកុមារប្រាប់ថា កូនខ្ញុំស្លាប់ដោយសារក្អួត កើតរោគខ្យល់) ។

នៅខេត្តពោធិ៍សាត់ មានអ្នកមូលដ្ឋានមួយគ្រួសារ នៅចាំមើលការខុសត្រូវលើយើងដែលជាប្រជាជន១៧ ហើយអ្នកធ្វើការនៅរោងបាយក៏ជាអ្នកមូលដ្ឋានដែរ ។ អ្នកមូលដ្ឋានខ្លះស្រលាញ់រាប់អានខ្ញុំ ។ ក្រោយពេលអង្គការយកប្តីខ្ញុំទៅអង្គការមានបំណងយកខ្ញុំទៅសម្លាប់ដែរ ប៉ុន្តែខ្ញុំបានរួចខ្លួនរហូត ដោយសារបានអ្នកមូលដ្ឋានជួយ ។ ពេលយប់ឡើងឈ្លបមកហៅខ្ញុំទៅ ប៉ុន្តែអ្នកមូលដ្ឋានពីរនាក់ប្តីប្រពន្ធដែលស្រលាញ់រាប់អានខ្ញុំប្រាប់ឈ្លបនោះថា ខ្ញុំមិនទាន់មកពីការដ្ឋានវិញទេ ។ ក្រោយមកពីនាក់ប្តីប្រពន្ធនោះបានប្រាប់ឲ្យខ្ញុំរត់ទៅកន្លែងផ្សេង ។ ពេលខ្ញុំរត់ចេញផុតពីភូមិ អង្គការបានយកបុរសដែលជួយខ្ញុំទៅសម្លាប់ចោលដោយចោទប្រកាន់ថា គាត់សមគំនិតជាមួយអ្នក១៧(មេសា) ។

ខ្ញុំធ្វើដំណើរទៅដល់សំសានស្ថិតនៅក្នុងខេត្តពោធិ៍សាត់ដដែល ។ នៅទីនោះខ្ញុំជាអ្នកកាស់ថ្មយកទៅលុបព្រែក ។ អង្គការប្រើកម្លាំងមនុស្សកាស់ថ្មនិងកាយដី ហើយប្រើដីរអូសថ្មទម្លាក់ចូលទៅក្នុងព្រែក ។ ការហូបចុកនៅទីនោះបានគ្រប់គ្រាន់ ។ យើងហូបបាយរាល់ថ្ងៃ ព្រោះនៅទីនោះសម្បូរអង្ករ ។

ខ្ញុំធ្វើការនៅទីនោះបានតែមួយរយៈខ្លី កងទ័ពវៀតណាមវាយរំដោះប្រទេស ។ មុនពេលកងទ័ពវៀតណាមមកដល់ ខ្ញុំឃើញរថយន្តបើកចុះបើកឡើងលើខ្នងទំនប់ ក្នុងពេលដែលខ្ញុំកំពុងធ្វើការនៅខាងក្រោម ។ អ្នកទាំងនោះពាក់អាវខ្មៅបង់កក្រមា និងមានមុខមាត់ដូចជនជាតិចិន ។

ឆ្នាំ១៩៧៩ ខ្ញុំដើរត្រឡប់មកស្រុកកំណើតវិញ ។ បងប្អូននៅទីនេះមិនស្គាល់ខ្ញុំទេ ព្រោះខ្ញុំចេញពីស្រុកតាំងពីជំនាន់ លន់ នល់ ។ ក្រោយមកខ្ញុំទៅរស់នៅភ្នំពេញតែម្នាក់ឯងក្បែររោងកុនសូរិយា ។ កងទ័ពវៀតណាមឲ្យផ្ទះខ្ញុំនៅដែលប្រឡាក់សុទ្ធតែឈាម ។ ក្រោយមក ខ្ញុំក៏ត្រឡប់មករកសាច់ញាតិរបស់ខ្ញុំនៅស្រុកកំណើតវិញ ។

ពេលនឹកឃើញរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមម្តងៗ ខ្ញុំតែងតែពិបាកចិត្ត និងនឹកឃើញដល់ការសម្លាប់មនុស្សនៅនឹងមុខ ។ ខ្មែរក្រហមធ្វើបាបកូននិងប្តីរបស់ខ្ញុំ និងបំបែកបងប្អូនមិនឲ្យរស់នៅជាមួយគ្នា ។ ពេលខ្ញុំមើលខ្សែភាពយន្តដែលបញ្ចាំងអំពីសម័យខ្មែរក្រហមនៅតាមទូរទស្សន៍ម្តងៗ ខ្ញុំខ្លោចផ្សាណាស់ ជាពិសេសនៅពេលខ្ញុំមើលរូបថតនេះធ្វើឲ្យខ្ញុំនឹកឃើញដល់ប្រវត្តិដើមរបស់ខ្ញុំ ។ ចាប់តាំងពីរៀបការមក យើងមិនដែលទាស់គ្នាទេ ។ នៅក្នុងជំនាន់ខ្មែរក្រហមយើងតស៊ូរស់នៅជាមួយគ្នា ពេលអត់អីហូបក៏យើងមិនដែលទាស់គ្នា «សូម្បីតែស្ពៃមួយធាងក៏ យើងចែកគ្នាហូបដែរ» ។ ពេលបានរបបបរមក ខ្ញុំរំលែកឲ្យប្តីខ្ញុំ ឲ្យតែគាត់បានរស់ ប៉ុន្តែគាត់នៅតែមិនរស់ ។ ប្រសិនបើប្តីខ្ញុំមិនស្លាប់ខ្ញុំក៏

មិនពិបាកដែរ ។

## ឡោ អ៊ុំ
## អតីតគ្រូបង្រៀនអក្ខរកម្ម

អ៊ុំ សំអាត មានស្រុកកំណើតនៅភូមិប្រការ សង្កាត់ព្រែសខណ្ឌដង្កោ រាជធានីភ្នំពេញ ។ សំអាត មានបងប្អូនទាំងអស់៦នាក់ ប្រុស៤នាក់ ស្រី២នាក់ ។ បងប្រុសទាំងពីររបស់ សំអាត, អ៊ុំ សំអុន និង អ៊ុំ សំអាន ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ម្តាយរបស់សំអាត ឈ្មោះ យា ទូច ស្លាប់តាំងពីជំនាន់លន់ នល់ និងឪពុកឈ្មោះ ឡោ អ៊ុំ ស្លាប់នៅក្នុងជំនាន់ ប៉ុល ពត ។ ខាងក្រោមនេះជាការរៀបរាប់របស់ សំអាត ÷

កាលពីសម័យសង្គមរាស្ត្រនិយម ឪពុកខ្ញុំជាគ្រូបង្រៀនអក្ខរកម្មនៅក្នុងភូមិ ។ ម្តាយខ្ញុំក៏រៀនអក្ខរកម្មជាមួយឪពុកខ្ញុំដែរ នៅនឹងផ្ទះខ្ញុំតែម្តង ។ ម្តាយខ្ញុំថតរូបនេះដើម្បីបិទលើសញ្ញាប័ត្រអក្ខរកម្មរបស់គាត់ក្រោយពីបញ្ចប់ថ្នាក់រៀននេះ ។ នៅសល់មួយសន្លឹក ខ្ញុំក៏យកមករក្សាទុករហូតដល់សព្វថ្ងៃ ។ ខ្ញុំថែរក្សារូបនេះទុកនៅក្នុងបង្វេចខោអាវរហូតដល់ខ្ញុំចូលកងនារីនៅក្នុងជំនាន់ប៉ុល ពត ខ្ញុំក៏ផ្ញើរូបថតនេះទុកនៅបងថ្លៃរបស់ខ្ញុំ(ប្រពន្ធរបស់បង អ៊ុំ សំអុន) ។ ក្រៅពីរូបថតម្តាយខ្ញុំ ខ្ញុំមាននៅសល់រូបថតឪពុកខ្ញុំនិងបងប្រុស សំអុន ទៀត ។

ខ្ញុំមិនដឹងថារូបថតឪពុកខ្ញុំមួយសន្លឹកនេះថតនៅពេលណាទេ ព្រោះរូបថតគាត់មានច្រើន ប៉ុន្តែបានបាត់បង់អស់ទៅហើយនៅសល់តែមួយសន្លឹកប៉ុណ្ណោះ ។ ខ្ញុំក៏មិនដឹងថាគាត់ថតរូបនេះយកទៅបម្រើប្រយោជន៍អ្វីទេ ព្រោះកាលពីសម័យលន់ នល់ គាត់ជាមេហាសិបខ្នង ។ មេហាសិបខ្នងប្រៀបដូចជាអនុប្រធានភូមិ ឯមេ១០០ខ្នងវិញដូចជាប្រធានភូមិ ។ ការបែងចែកបែបនេះមានតែនៅក្នុងសម័យ លន់ នល់ ទេ ដើម្បីធ្វើស្ថិតិទទួលអំណោយពីអាមេរិកាំង និងដើម្បីងាយស្រួលគ្រប់គ្រងចំនួនប្រជាជនចេញចូលនៅក្នុងភូមិ ។ បងថ្លៃខ្ញុំខ្ចប់រូបថតទាំងនេះនឹងក្រដាសចុះឡើងៗធ្វើឲ្យមានស្នាមខ្លះមិនស្អាតដូចកាលពីដើមទេ ។

ឪពុកខ្ញុំមានបងប្អូន៤នាក់ គាត់ជាកូនទីពីរ ។ កាលពីក្មេងឪពុកខ្ញុំធ្លាប់បួសជាសង្ឃរហូតបានក្លាយជាគ្រូសូត្រស្តាំបន្ទាប់ពីចៅអធិការវត្ត ។ គាត់សឹកនៅពេលឪពុកម្តាយរើសគូស្រករឲ្យគាត់ ។ បុរសកាលជំនាន់មុនច្រើនបួសរៀននៅវត្ត ហើយចាស់ៗច្រើនលើកកូនស្រីឲ្យគ្រូសូត្រ ព្រោះជាអ្នកបួសរៀនចេះដឹងជ្រៅជ្រះ ។


ឡោ អ៊ុំ
(ឪពុករបស់ សំអាត)

កាលពីខ្ញុំនៅក្នុងកងចល័តនារីកំពុងជីកប្រឡាយចាស់ៗនៅក្នុងភូមិបានទៅប្រាប់ខ្ញុំថាឪពុកខ្ញុំស្លាប់ តែខ្ញុំមិនដឹងថាឪពុកខ្ញុំស្លាប់ដោយមូលហេតុអ្វីពិតប្រាកដទេ ។ អ្នកភូមិខ្លះមកខ្សឹបប្រាប់ខ្ញុំថាឪពុកខ្ញុំស្លាប់ដោយជំងឺ និងខ្លះប្រាប់ថាឪពុកខ្ញុំត្រូវអង្គការយកទៅសម្លាប់ ។ ពេលខ្ញុំមកពីធ្វើការប្រហែលម៉ោង១រសៀល អ៊ំស្រីរបស់ខ្ញុំដែលរស់នៅស្រែព្រៃបានមកប្រាប់ខ្ញុំថាខ្មែរក្រហមបម្រុងយកបងសំអុន ទៅសម្លាប់នៅគុកសង់ទន្លេបាទី ប៉ុន្តែពេលធ្វើដំណើរលើផ្លូវទៅវត្តសាឡុង គាត់បានតដៃនឹងឈ្លប ហើយឈ្លបនោះក៏សម្លាប់គាត់តែម្តង ។


យា ទូច
(ម្តាយរបស់ សំអាត)

ពេលខ្មែរក្រហមជម្លៀសចេញដំបូងខ្ញុំបានទៅនៅកោងកាកមួយរយៈរួចក៏ផ្លាស់មកនៅស្ពានថ្មវិញ ដោយគិតថានឹងបានមករស់នៅជិតស្រុកកំណើត ។


អ៊ុំ សំអុន
(បងប្រុសរបស់ សំអាត)

បានតែរយៈពេលមួយឆ្នាំ ខ្មែរក្រហមបញ្ជូនខ្ញុំទៅវត្តស្រែព្រៃ ។ ខ្ញុំរស់នៅជួបជុំគ្នាជាមួយបងប្អូន និងឪពុកខ្ញុំនៅស្រែព្រៃរហូតដល់ខ្ញុំរៀបការ ។

នៅក្នុងជំនាន់ ប៉ុល ពត អង្គការបានរៀបចំឲ្យខ្ញុំរៀបការជាមួយប្តីខ្ញុំឈ្មោះ ចាន់ សុខកេង ។ យើងជាប្តីប្រពន្ធមួយគូក្នុងចំណោមប្តីប្រពន្ធ៩០គូដែលអង្គការរៀបចំឲ្យ ។ នៅក្នុងពិធីរៀបការនោះមានប្រជាជនមូលដ្ឋានចំនួន៥គូ ហើយក្នុងចំណោមនោះមានមួយគូត្រូវឡើងប្តេជ្ញាតំណាងឲ្យប្តីប្រពន្ធទាំង៩០គូ ។

តាមការពិតយើងគ្មានអារម្មណ៍អ្វីមួយថានឹងចង់បានគូស្រករទេ ព្រោះយើងគិតធ្វើម៉េចឲ្យតែបានរួចខ្លួនពីការស្លាប់ក្នុងមួយថ្ងៃៗប៉ុណ្ណោះ ។ ក្រោយពីរៀបការរួច អង្គការបានចាត់តាំងឲ្យខ្ញុំនិងប្ដីទៅរស់នៅសហករណ៍ក្រាំងក្រូចក្នុងស្រុកសៀមរាប ។

ខ្ញុំមានបងប្រុសម្នាក់ឈ្មោះ សំអុន ។ គាត់កើតនៅឆ្នាំមមី ។ បងសំអុន ធ្លាប់បួសរៀននៅវត្តព្រៃស្អី ខណ្ឌដង្កោ ជាវត្តដែលឪពុកនិងពូខ្ញុំធ្លាប់បួស ។ គាត់រៀនរហូតដល់ឆ្នាំ១៩៧៥ ក៏ឈប់រៀនហើយរៀបការ ។ បានប្រហែល៤ខែ ខ្មែរក្រហមក៏ចូលកាន់កាប់ក្រុងភ្នំពេញ និងជម្លៀសយើងចេញពីទីក្រុង ។ ពួកយើងចេញទៅជាមួយគ្នា ប៉ុន្តែត្រូវខ្មែរក្រហមបំបែកឲ្យទៅតាមកងផ្សេងៗគ្នា ។

ខ្ញុំចាំបានថា បងសំអុន បានបររទេះដឹកត្រសក់មកជួបខ្ញុំដែលកំពុងធ្វើការនៅកណ្ដាលផ្លូវពីក្រាំងស្នំទៅស្រែព្រៃ ។ គាត់ហៅឲ្យខ្ញុំយកត្រសក់ខ្លះទៅហូបតែខ្ញុំបដិសេធមិនយកត្រសក់នោះទេ ដោយខ្លាចអង្គការយកខ្ញុំទៅសម្លាប់ ។ រយៈពេលពីរ-បីថ្ងៃក្រោយមក អង្គការក៏យកគាត់ទៅសម្លាប់ចោល ។

ពេលខ្ញុំដឹងថា ឪពុកនិងបងប្រុសខ្ញុំស្លាប់ ខ្ញុំលួចយំនិងមិនទៅធ្វើការពីរ-បីថ្ងៃ ។ ទោះបីខ្ញុំធ្វើការនៅឆ្ងាយពីផ្ទះនិងពីគ្រួសារក៏ដោយ ក៏ខ្ញុំមិនដែលហ៊ានលួចស្កាត់ទៅជួបឪពុកម្ដាយខ្ញុំដែរ ពីព្រោះ ខ្ញុំខ្លាចប្រធានក្រុមដាក់ទណ្ឌកម្មឲ្យរែកដីឬបង្អត់បាយ ។ អង្គការក៏មានច្បាប់ឲ្យយើងទៅជួបឪពុកម្ដាយដែរ ប៉ុន្តែអនុញ្ញាតឲ្យទៅជួបបានតែម៉ោងពេលសម្រាកពីធ្វើការប៉ុណ្ណោះ និងត្រូវត្រឡប់មកវិញឲ្យទាន់ពេលវេលាធ្វើការ បើសិនជាមកមិនទាន់ពេលធ្វើការទេ នឹងត្រូវប្រធានក្រុមដាក់ទណ្ឌកម្មហើយ ។

ពេលកងទ័ពវៀតណាមវាយរំដោះទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៩ ខ្មែរក្រហមបានចាកចេញពីភូមិស្រុកទៅរស់នៅក្នុងព្រៃអស់ ។ ខ្ញុំបានត្រឡប់មកស្រុកកំណើតជាមួយប្ដីខ្ញុំវិញ ។

ពេលដែលខ្ញុំមើលរូបថតនេះម្ដងៗ ខ្ញុំនឹកគាត់ណាស់ ។ បងប្អូនខ្ញុំមិនចេះឈ្លោះគ្នាទេ ។ ថ្វីដ្បិតតែខ្ញុំមិនដែលទៅធ្វើបុណ្យនៅគុកសង់ទន្លេបាទីឲ្យបងប្រុសខ្ញុំក៏ដោយ តែខ្ញុំក៏បានទៅធ្វើបុណ្យឧទ្ទិសឲ្យឪពុកនិងបងប្រុសនៅវត្តស្វាយដែរ ព្រោះខ្ញុំឮពាក្យចចាមអារ៉ាមថា គាត់ស្លាប់ក្នុងវត្តនោះ ។

**ប៊ាង ពីច័ន និង ស៊ុី សាវីណា**

# កុមារសន្តិសុខនៅមន្ទីរស-២១

យុវជនជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវអង្គការបដិវត្តន៍ខ្មែរក្រហមបំបែកចេញពីគ្រួសារ យកទៅបំពាក់បំប៉នគោលនយោបាយ ដើម្បីចូលរួមកសាងសង្គមមួយដែលស្អាតស្អំ ។ យុវជនខ្លះទៀតបានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍តាមមិត្តភក្តិណែនាំ ។ យុវជនមួយចំនួនមានឱកាសបានវិលត្រឡប់មកជួបជុំឪពុកម្ដាយវិញក្រោយថ្ងៃ៧មករា ឆ្នាំ១៩៧៩ ខ្លះត្រូវបាត់ខ្លួន និងខ្លះទៀតត្រូវស្លាប់ដោយការសម្លាប់និងកង្វះអាហារ ។ ព្រុំ ឈឿន ជាសន្តិសុខរបស់មន្ទីរស-២១ ដែលបានរត់គេចពីខ្មែរក្រហមមកជួបជុំឪពុកម្ដាយក្រោយពេលរបបនេះដួលរលំ ។


ព្រុំ ឈឿន

បច្ចុប្បន្ន ព្រុំ ឈឿន មានអាយុ៥០ឆ្នាំ រស់នៅក្នុងខេត្តកំពង់ស្ពឺ ប្រកបមុខរបរធ្វើស្រែ ប្រពន្ធឈ្មោះ គុម អ៊ិន និងមានកូន៩នាក់ ស្លាប់អស់ពីរនាក់ ។

ឈឿន ត្រូវបងជីដូនមួយឈ្មោះ មាស ដែលធ្វើការនៅមន្ទីរស-២១នាំទៅនៅទីក្រុងភ្នំពេញបន្ទាប់ពីធ្វើការនៅក្នុងកងចល័តកុមារជីកប្រឡាយនៅចម្ការក្រូចអស់រយៈពេលជិត១ឆ្នាំ ។ ពេលមកដល់ភ្នំពេញដំបូង ឈឿន បានទៅធ្វើទាហានយាមល្បាតនៅស្នាក់ការទីមួយ នៅទួលលាភ (តាមផ្លូវជាតិលេខ៤) ដើម្បីចែកអង្ករឲ្យប្រជាជនដែលជម្លៀសចេញពីទីក្រុង ។ បន្ទាប់ពីនោះមក ឈឿន បានផ្លាស់មកធ្វើការនៅបឹងទំពុនជាមួយកុមារជាង២០នាក់ទៀតដែលមកពីស្រុកអមលាំងខេត្តកំពង់ស្ពឺ ។ ការងារ

នៅទីនោះគឺដាំបន្លែ ។ ដោយសារតែ ឈឿន ធ្លាប់រៀនសូត្រនិង ចេះអក្សរ ប្រធានកងកុមារឈ្មោះ ភន បានចាត់តាំង ឈឿន ឲ្យធ្វើជាគ្រូបង្ហាត់កុមារនៅក្នុងកងជាមួយគ្នា ។ ក្រៅពីធ្វើការងារប្រចាំថ្ងៃ ភន បង្ហាត់ក្បាច់ប្រយុទ្ធដល់កុមារទាំងអស់ដើម្បីត្រៀមលក្ខណៈទៅធ្វើការនៅមន្ទីរគុកទួលស្លែង ។

ឆ្នាំ១៩៧៧ មាស បាននាំ ឈឿន ទៅធ្វើជាសន្តិសុខយាមទ្វារនៅមន្ទីរស-២១ ។ ចាប់តាំងពីពេលនោះមក ឈឿន មិនដែលជួប មាស ទៀតឡើយ ។ នៅឆ្នាំ១៩៧៨ ឈឿន បានឮដំណឹងថា មាស បានស្លាប់ដោយសារជំងឺ ។

ពេលទៅដល់មន្ទីរស-២១ដំបូង ឈឿន មិនស្គាល់ថាកន្លែងនោះឈ្មោះអ្វីនិងធ្វើអ្វីឡើយ ក្រោយមក ឈឿន ឮសន្តិសុខនៅទីនោះហៅថាមន្ទីរស-២១ ។ ការងាររបស់ ឈឿន គឺឈរយាមនៅខាងច្រកចូល និងគ្មានសិទ្ធិចូលទៅខាងក្នុងបរិវេណគុកទេ ។ ឈឿន រំឭកថា *«នៅមន្ទីរគុកទួលស្លែងមានរបងការពារយ៉ាងរឹងមាំ ខាងលើដាក់របងបន្លាលួសនិងភ្ជាប់ចរន្តអគ្គិសនីទាំងយប់ទាំងថ្ងៃ»* ។ ឈឿន តែងតែឃើញរថយន្តពណ៌សរបស់ ឌុច ប្រធានមន្ទីរគុកទួលស្លែងចេញចូលជាញឹកញាប់ ហើយនៅពេលឃើញរថយន្តមកម្តងៗ ឈឿន ត្រូវរួសរាន់បើកទ្វារឲ្យទាន់ពេលវេលា ព្រោះដឹងថា ឌុច អង្គុយនៅក្នុងនោះ ។ ឈឿន បានប្រាប់ថាគាត់ស្គាល់ ឌុច តាមមិត្តភក្តិរបស់គាត់ចង្អុលប្រាប់ប៉ុណ្ណោះ ។ រៀងរាល់សប្តាហ៍ ប្រធានកងតែងប្រជុំរំឭកដល់កុមារសន្តិសុខថា *«បើឃើញឡានដឹកមនុស្សអី... អ្នកណាក៏ដោយត្រូវតែឆាប់បើកទ្វារ»* ។

ឈឿន អះអាងថា នៅក្នុងអំឡុងពេលយាមទ្វារ គាត់ឃើញរថយន្តដឹកមនុស្សចូលក្នុងមន្ទីររាល់ថ្ងៃ ក៏ប៉ុន្តែកម្រឃើញរថយន្តដឹកមនុស្សចេញតាមច្រកដែលគាត់យាមណាស់ ។ ពេលណាមានរថយន្តដឹកមនុស្សចូលមន្ទីរ សើ ដែលជាអ្នកបើកឡានដឹកអ្នកទោស តែងផ្តល់ដំណឹងតាមវិទ្យុទាក់ទងឲ្យអ្នកយាមទ្វារដឹងមុនដើម្បីត្រៀមខ្លួនចាំបើកទ្វារដោយប្រុងប្រយ័ត្នបំផុត ។ ឈឿន ក៏បានឲ្យដឹងថា គាត់មិនសូវស្គាល់មនុស្សនៅក្នុងមន្ទីរនេះច្រើនទេ ហើយក្តាប់សភាពការណ៍ក្នុងមន្ទីរក៏មិនបានច្បាស់ដែរ ព្រោះគាត់មិនហ៊ានដើរផ្តេសផ្តាសដូចមិត្តភក្តិរបស់គាត់ឈ្មោះ សឿង ទេ ។ ឈឿន ដឹងរឿងរ៉ាវដែលកើតឡើងនៅក្នុងមន្ទីរតាមតែ សឿង ប្រាប់ប៉ុណ្ណោះ ។ *«ខ្ញុំអត់ដែលឃើញគេវ៉ៃមនុស្សទេ តែបើនិយាយពីឮគេនិយាយថាយកទៅវ៉ៃខ្ញុំបានឮ ។ បើរឿងវ៉ៃគេមិនឲ្យអ្នកយាមដឹងទេ»* ។ ថ្ងៃមួយ សឿង បានមកប្រាប់គាត់ថា គេយកមនុស្សវ៉ៃចោលនៅខាងក្រោយមន្ទីរគុកទួលស្លែង ។ ក្រៅពីនេះ ឈឿន គ្រាន់តែដឹងតាមរយៈមិត្តភក្តិរបស់គាត់ថាប្រជាជនដែលចាប់មកនេះក៏មានវៀតណាមដែរ *«មិនដឹងយកពីណាមកទេ ខ្ញុំអត់ដឹង តែឮមាត់យួន(និយាយភាសាយួន) ពេលវាមកហូបបាយអីហ្នឹង ដូចថាពេលបាយហើយ យើងទៅរកកន្លែងម្ហូបអង្គុយ ហើយឮគេ(វៀតណាម) និយាយគ្នាតិចៗទៅ»* ។

ឈឿន ធ្វើសន្តិសុខយាមទ្វាររហូតដល់ចុងឆ្នាំ១៩៧៨ ។ នៅពេលកងទ័ពវៀតណាមចូលមករំដោះទីក្រុងភ្នំពេញ សមមិត្ត ឌុច ប្រធានគុកស-២១, កម្មាភិបាលនិងយុទ្ធជន យុទ្ធនារីចំនួនជាង១០០នាក់ រួមទាំង ឈឿន ផង បាននាំគ្នារត់ភៀសខ្លួនទៅទិសខាងលិច ។ កម្មាភិបាលខ្មែរក្រហមធំៗបាននាំគ្នាធ្វើដំណើរតាមរថយន្តទៅមុន ចំណែកក្រុមរបស់ ឈឿន ធ្វើដំណើរដោយថ្មើរជើង ។ ធ្វើដំណើរទៅដល់ផ្សារលាចក្នុងខេត្តពោធិ៍សាត់ ឈឿន សម្រេចចិត្តគេចខ្លួនត្រឡប់មកក្រោយវិញដោយស្ពាយកាំភ្លើងមួយដើមមកជាមួយផង ។ *«ខ្ញុំទៅនោះខ្លាចស្លាប់ អីចឹងខ្ញុំមកផ្ទះវិញជាមួយប្រជាជន ។ ខ្ញុំរស់នៅក្នុងមន្ទីរបានពីរឆ្នាំ បានយួនចូលទីក្រុង ហើយខ្ញុំនាំគ្នារត់ចេញមកទាំងអស់គ្នា១៥០នាក់ តែខ្ញុំអត់ចាំឈ្មោះអ្នកមកជាមួយគ្នាទេព្រោះច្រើនណាស់ ។ រត់មកទាំងអស់គ្នា ហើយចប់មួយវគ្គហ្នឹងគេបញ្ជូនឲ្យទៅរហូតដល់ថៃ តែខ្ញុំបកមកវិញ ខ្ញុំអត់ទៅតាមគេ ខ្ញុំនឹកម៉ែពេក! ខ្ញុំបែកម៉ែតាំងពីតូច ។ ខ្ញុំក៏មកដល់ស្រុកក្នុងឆ្នាំ៧៩»* ។

ពេលត្រឡប់មកដល់ស្រុកកំណើតបានមួយខែ ឈឿន បានរៀបការជាមួយនារីម្នាក់ឈ្មោះ អុន ហើយមានកូនប្រាំបួននាក់ ។ នៅឆ្នាំ១៩៨៣ ឈឿន បានស្ម័គ្រចិត្តចូលបម្រើកងទ័ពម្តងទៀត និងលាឈប់វិញនៅឆ្នាំ១៩៨៧ ។ ឈឿន តែងតែនិយាយប្រាប់អំពីការលំបាករបស់គាត់ឲ្យកូនៗស្តាប់ជារឿយៗ *«កូនៗឥឡូវនេះសំណាងហើយ មួយស្រករពុកឃើញតែសង្គ្រាមទេ គ្រាន់តែកើតមកគឺមានសង្គ្រាមហើយ ។ ក្មេងឥឡូវស្រួល*

ណាស់កើតមកសប្បាយតែម្តង តែខ្វះហួសសប្បាយទៀតទៅជាប្រើគ្រឿងញៀនវិញ» ។

ឈឿន សប្បាយចិត្តកាលដែលបានឮពត៌មានតាមវិទ្យុថារដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ សហការគ្នាបង្កើតតុលាការមួយសម្រាប់នាំមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់មកកាត់ទោស ។ ពេលនោះខ្លួនគាត់ក៏ដូចជាជនរងគ្រោះជាច្រើននាក់ទៀតនឹងដឹងការពិតថាមូលហេតុអ្វីទើបបង្កឲ្យមានការសម្លាប់ប្រជាជនកម្ពុជាច្រើនយ៉ាងនេះ ។ ជាពិសេសទៅទៀត តុលាការនេះមានផលប្រយោជន៍ច្រើនក្នុងការការពារកុំឲ្យរបបនេះវិលមកវិញ ។

***លី សុផល***

# ប៉េង ជី : សម្របខ្លួនក្នុងបដិវត្តន៍

ក្នុងវ័យ៧៥ឆ្នាំ ប៉េង ជី ជាប្រជាជនសាមញ្ញរស់នៅក្នុងស្រុកពញាឮ ខេត្តកណ្តាល ។ ថ្វីត្បិតតែគាត់មានវ័យចំណាស់ ជី មានរឿងរ៉ាវជាច្រើនដែលដក់ជាប់នៅក្នុងអារម្មណ៍រហូតដល់សព្វថ្ងៃ ។ ជី បានឆ្លងកាត់នូវព្រឹត្តិការណ៍ជាច្រើនដំណាក់កាលតាំងពីសម័យអាណានិគមបារាំង ជំនាន់ជប៉ុនចូលគ្រប់គ្រងខេត្តបាត់ដំបង និងថៃចូលកាន់កាប់ខេត្តទាំងបីដែលមានខេត្តសៀមរាប ខេត្តបាត់ដំបងនិងខេត្តពោធិ៍សាត់នៅដើមទសវត្សរ៍ឆ្នាំ១៩៤០ ។

ប៉េង ជី កើតនៅឆ្នាំ១៩៣២ នៅក្នុងគ្រួសារក្រីក្រមួយ មានឪពុកឈ្មោះ ជាន់ និងម្តាយឈ្មោះ ស៊ឹម នៅភូមិព្រៃកខ្ពប ឃុំព្រៃកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ ជី មានបងប្អូនប្រុស៣នាក់ និងស្រីម្នាក់ ។

នៅឆ្នាំ១៩៤៥ ពេលប្រទេសកម្ពុជាស្ថិតក្រោមអាណានិគមនិយមបារាំង ខេត្តបាត់ដំបងស្ថិតនៅក្រោមការកាន់កាប់របស់ប្រទេសជប៉ុន ។ ក៏ប៉ុន្តែ ក្រោយពីចាញ់សង្គ្រាមលោកលើកទីពីរ ជប៉ុនបានដកទ័ពចេញពីប្រទេសកម្ពុជា ហើយ ថៃបានចូលមកកាន់កាប់ខេត្តបាត់ដំបងជំនួស និងខេត្តចំនួនពីរទៀតគឺខេត្តពោធិ៍សាត់ និងខេត្តសៀមរាប ។ ថៃបានផ្សព្វផ្សាយវប្បធម៌របស់ខ្លួនដោយបង្កើតជាក្រុមតន្ត្រីនៅគ្រប់ទីកន្លែងនិងប្រមូលទិញបេតិកភណ្ឌពីប្រទេសកម្ពុជាទៅវិញ ដូចជាវត្ថុបុរាណនិងទិញសំណយកទៅធ្វើប្រាក់កាក់ថៃ រួចយកមកឲ្យប្រជាជនខ្មែរចាយវិញ ។ ក្រៅពីនេះ ថៃបានបង្ខំឲ្យប្រជាជនខ្មែររៀនអក្សរនិងភាសាថៃទៀតផង ។ ជី មិនចូលចិត្តវប្បធម៌របស់ថៃទេ ហេតុដូច្នេះហើយក្នុងវ័យ១៨ឆ្នាំ ជី បានបួសរៀននៅវត្តព្រៃកហួងដើម្បីគេចពីការចាប់បង្ខំរបស់ថៃ ។

នៅឆ្នាំ១៩៥០ ជី បានឈប់រៀន ហើយបានទៅធ្វើជាអ្នកបម្រើជំនិតរបស់ព្រះអង្គម្ចាស់ចន្ទរង្សី (ជាឧត្តមសេនីយ៍ក្នុងសម័យសាធារណរដ្ឋខ្មែរ) នៅក្នុងអំឡុងពេលដែលព្រះអង្គបានយាងទៅកែនទ័ពខ្មែរឥស្សរៈនៅភូមិព្រៃកហួងដើម្បីវាយពួកអាណានិគមបារាំង ។ ជី មានតួនាទីរៀបចំនិងថែសេះថ្វាយព្រះអង្គម្ចាស់ចន្ទរង្សី ។ ក្រៅពីនេះ ជី មាននាទីសម្រួចបុស្សីពីងពង់ធ្វើជាអាវុធនិងរៀបចំបាយកាតាកឲ្យទ័ពខ្មែរឥស្សរៈនៅសមរភូមិវាយប្រយុទ្ធជាមួយបារាំងនៅផ្ទះសំណាក់នៅខេត្តសៀមរាប ។ បន្ទាប់ពីបានទទួលជ័យជម្នះពីកងទ័ពបារាំង ព្រះអង្គ ចន្ទរង្សី បានដឹកនាំទ័ពត្រឡប់មកទីក្រុងភ្នំពេញវិញ ប៉ុន្តែ ជី មិនបានធ្វើដំណើរតាមព្រះអង្គទេ ។

ជី បានទៅប្រកបមុខរបរលក់អីវ៉ាន់ដូចជា អង្ករនិងគ្រឿងបរិភោគនៅភូមិព្រៃកទាល់តាមដងទន្លេសាប ប៉ុន្តែជាអកុសលទូកផ្ទុកអីវ៉ាន់របស់ ជី បានលិច ។ ជី ក៏បាន លក់ទូកនិងអីវ៉ាន់ដែលនៅសេសសល់ពីការខូចខាត ហើយផ្លាស់ទៅរស់នៅជាមួយគ្រូរបស់គាត់នៅឯខេត្តសៀមរាប ។ ជី បានទិញកង់មួយគ្រឿងសម្រាប់ដឹកគ្រឿងទេសយកទៅលក់នៅក្នុងឃុំដំដែក ស្រុកសូទ្រនិគម ។ នៅរដូវប្រមូលផលស្រូវ ជី បានដឹកទំនិញទៅដោះដូរយកស្រូវជំនួសប្រាក់ ។ ក្នុងអាយុ៣២ឆ្នាំ ជី បានរៀបការប្រពន្ធឈ្មោះ សាយ សុត និងរស់នៅក្នុងឃុំដំដែកខេត្តសៀមរាប ។

ក្រោយមក ជី បានទៅបម្រើ ព្រះអង្គម្ចាស់ ចន្ទរង្សី ម្តងទៀត នៅព្រះរាជដំណាក់នៅព្រែកតាទែនក្នុងស្រុកពញាឮ

ខេត្តកណ្តាល តាមរយៈអ្នកម្នាង សុគិន ដែលជាសាច់ញាតិរបស់ ជី ចំណែកប្រពន្ធគាត់នៅលក់ដូរឯខេត្តសៀមរាប ។ ជី មាននាទីមើលការខុសត្រូវកម្មករ ថែរក្សាសួនសត្វនិងសួនច្បារ ។ ជី ឧស្សាហ៍ឃើញ ព្រះអង្គម្ចាស់នរទីប៉ូ (ព្រះរាជបុត្ររបស់សម្តេចព្រះនរោត្តម សីហនុ) យាងមកលេងនិងពិភាក្សាការងារជាមួយព្រះអង្គម្ចាស់ ចន្ទរង្សី ហើយ ជី ក៏ធ្លាប់មានទំនាក់ទំនងជាមួយទ្រង់ដែរ ។ ព្រះអង្គម្ចាស់ ចន្ទរង្សី បានរៀបចំឲ្យ ជី មានគូស្រករ ប៉ុន្តែ ជី បានប្រាប់ព្រះអង្គថា ខ្លួនមានប្រពន្ធនិងមានកូនមួយហើយ ។ ព្រះអង្គក៏អនុញ្ញាតឲ្យ ជី យកប្រពន្ធនិងកូនមករស់នៅជាមួយ ។

នៅខែមេសា ឆ្នាំ១៩៧៥ ជី នៅថែទាំដំណាក់នៅឡើយ ចំណែកព្រះអង្គម្ចាស់ ចន្ទរង្សី និងអ្នកម្នាង វរសាម៉ន គង់នៅព្រះរាជដំណាក់ចម្ការមននា ទីក្រុងភ្នំពេញ ។ កងទ័ពខ្មែរក្រហមស្លៀកពាក់ខ្មៅប្រមាណ១០នាក់ បានចូលក្នុងភូមិដេញ ជី និងប្រជាជនដទៃទៀតឲ្យចាកចេញពីផ្ទះ ។ ជី និងគ្រួសារនាំគ្នាចេញពីផ្ទះដោយមិនបានយករបស់របរអ្វីច្រើនទៅតាមខ្លួនទេ ។ កងទ័ពខ្មែរក្រហម ដែលចូលមកភូមិបានបញ្ជាឲ្យ ជី និងប្រជាជនដទៃទៀតជម្លៀសខ្លួនឆ្លងទូកទៅត្រើយម្ខាងទន្លេដើម្បីគេចពីការបាញ់ផ្លោងរបស់កងទ័ពម៉ារីនសាធារណរដ្ឋខ្មែរ ។ ជី និងគ្រួសារបានស្នាក់នៅភូមិអន្លង់ស្វែងមួយរយៈ ។


ប៉េង ជី និងប្រពន្ធ សាយ សុត

នៅភូមិអន្លង់ស្វែង អង្គការចាប់ផ្តើមស៊ើបប្រវត្តិរូបប្រជាជនដែលទើបជម្លៀសមកថ្មីៗ ។ ជី ព្យាយាមលាក់ប្រវត្តិរបស់ខ្លួនមិនឲ្យអង្គការដឹងថាខ្លួនជាអ្នកបម្រើជំនិតរបស់ព្រះអង្គម្ចាស់ ចន្ទរង្សីទេ ប៉ុន្តែអង្គការនៅតែស៊ើបដឹង ។ ជី បានរួចពីការចោទប្រកាន់ជាច្រើនលើក ដោយសារអ្នកជិតខាងរបស់គាត់តែងជួយនិងប្រាប់អង្គការថា គាត់គ្រាន់តែជាអ្នកថែសួនតូចតាចក្នុងដំណាក់ប៉ុណ្ណោះ ។

ការរស់នៅដំបូងនៅក្នុងភូមិអន្លង់ស្វែងមិនសូវជាតានតឹងប៉ុន្មានទេ ។ អង្គការបានប្រកាសមិនឲ្យមានផ្សារនិងចាយលុយ ក៏ប៉ុន្តែប្រជាជនជម្លៀសអាចមានឱកាសដោះដូរម្ហូបអាហារជាមួយអ្នកភូមិបាន ។ ជី បានប្រមូលលុយដែលយកមកតាមខ្លួនទិញបានកង់មួយពីប្រជាជនមូលដ្ឋាន ដើម្បីជិះទៅដូរស្បៀងមកផ្គត់ផ្គង់គ្រួសារ ។

ក្រោយពីស៊ើបប្រវត្តិរូបរបស់អ្នកទើបមកដល់ថ្មីហើយ អង្គការបានបញ្ជូន ជី និងគ្រួសារទៅភូមិស្វាយរំពា ។ ក្នុងនាមជាប្រជាជនថ្មី ជី បានសុំសំបុត្រអនុញ្ញាតពីមេភូមិឈ្មោះ ឆុន ដើរដូរអំបិល ដំឡូងជ្វា និងទៅនេសាទត្រីដើម្បីយកមកដូរអង្ករដោះស្រាយជីវភាព ។

មួយឆ្នាំក្រោយមក គ្រួសាររបស់ ជី ត្រូវបានបញ្ជូនមកនៅភូមិថ្មស ឃុំភ្នំបាត ស្រុកពញាឮ ។ នៅទីនោះមានប្រជាជនមកពីកន្លែងផ្សេងគ្នាប្រហែល១០០គ្រួសារ ។ អង្គការបានឲ្យប្រជាជនទាំងអស់រស់នៅនិងហូបរួមគ្នាជាសហករណ៍ធំមួយ ។ ម្នាក់ៗទទួលបានបបរពីរពេលក្នុងមួយថ្ងៃ ។ យូរៗទើបអង្គការឲ្យរបបបាយម្តង ។ អង្គការចាត់តាំង ជី ឲ្យធ្វើការក្នុងក្រុមកងចល័តទៅភូមិអង្គសេរី ចំណែក ស៊ុត ធ្វើការនៅក្នុងកងចល័តដើរស្ទូងស្រូវ ហើយកូនទាំង៣ធ្វើការក្នុងកងចល័តកុមារទាំងអស់ ។ ជី មិនបានរស់នៅជុំគ្នាជាមួយប្រពន្ធនិងកូនរបស់គាត់ទេ យូរៗទើបបានជួបជុំគ្រួសារម្តង ។

នៅភូមិអង្គសេរី ជី ឧស្សាហ៍ឃើញឈ្លបខ្មែរក្រហមបណ្តើរមនុស្សយកទៅសម្លាប់នៅពេលយប់ ជួនកាលនៅពេលថ្ងៃក៏មានដែរ ។ នៅយប់មួយ ជី បានឮសម្រែកអ្នកជិតខាងរបស់គាត់ម្នាក់

ឈ្មោះ ស៊ុំ ត្រូវឈ្លបខ្មែរក្រហមក្មេងៗពីរនាក់បណ្តើរយកទៅសម្លាប់នៅចម្ងាយ៥០ទៅ៦០ម៉ែត្រពីផ្ទះនៅម៉ោងប្រហែល ៨ ។ ស៊ុំ ជាមនុស្សនិយាយស្តីមិនសូវខ្លាចអ្នកណាទេ ។ មុនពេលចាប់ខ្លួន ស៊ុំ រអ៊ូរទាំថាអង្គការប្រើគាត់ឲ្យធ្វើការងារធ្ងន់ ប៉ុន្តែអង្គការមិនដែលឲ្យហូបឆ្អែតទេ ។ សាច់ញាតិរបស់ ស៊ុំ មិនហ៊ានតមាត់ឬប្រឆាំងអ្វីទេនៅពេលឃើញឈ្លបខ្មែរក្រហមចូលមកចាប់ស៊ុំ ។ លុះស្អែកឡើងឈ្លបវ័យក្មេងម្នាក់ឈ្មោះ ហឿង បានប្រាប់ ជី ថាខ្លួនបានសម្លាប់ ស៊ុំ នៅតាវល្ល៍ហើយ ។

ក្នុងរយៈកាលនៅឃុំភ្នំបាត ជី មានសុខភាពមិនសូវមាំទាំទេ ព្រោះមានជំងឺឬសដូងបាត ។ គណៈស្រុកឈ្មោះ ឡុង ក៏មិនសូវប្រើ ជី ឲ្យធ្វើការងារធ្ងន់ដែរ ។ ឡុង ជាមនុស្សកាចសាហាវ ប៉ុន្តែចូលចិត្ត ជី ព្រោះ ជី ធ្វើការងារបានល្អមិនឲ្យខ្លួនទាស់ចិត្តឡើយ ។ ឡុង បានឲ្យ ជី មកបោសសម្អាតផ្ទះសម្បែងនិងឃ្វាលក្របីនៅផ្ទះរបស់ខ្លួន ។ ពេលខ្លះ ជី បានទទួលបាយនិងម្ហូបដែលសេសសល់ពីឡុង គ្រាន់យកមកដោះស្រាយជីវភាពប្រចាំថ្ងៃដែរ ។ ពេលដឹងថា ជី មានជំងឺឬសដូងបាត ឡុង បានបញ្ជូន ជី ឲ្យទៅសម្រាកនៅមន្ទីរពេទ្យខេត្តកំពង់ស្ពឺ រហូតបានធូរស្រាលពីជំងឺទៀតផង ។

ក្រោយពេលចេញពីពេទ្យវិញ អង្គការបានផ្លាស់ ជី ឲ្យមកធ្វើការនៅភូមិប្រាសាទ ឃុំឈ្រាំង ។ ការរស់នៅក្នុងភូមិប្រាសាទមានភាពតានតឹងជាងភូមិមុនៗ ។ ប្រជាជននៅក្នុងសហករណ៍ស្លាប់កាន់តែច្រើនឡើងៗដោយសារការងារធ្ងន់និងរបបអាហារហូបមិនគ្រប់គ្រាន់ ។

ក្នុងឆ្នាំ១៩៧៨ ជី បានជួប សោ ជាមិត្តភក្តិចាស់នៅវត្តកំពង់ប្រាសាទ ។ សោ ជាអង្គរក្សនិងអ្នកបើកឡានឲ្យព្រះអង្គម្ចាស់ចន្ទរង្សី ដែលប្រាប់ ជី ថាព្រះអង្គត្រូវពួកខ្មែរក្រហមយកទៅសម្លាប់នៅពេលព្រះអង្គយាងដំណើរទៅព្រះរាជដំណាក់នៅស្រុកច្បារមនខេត្តកំពង់ស្ពឺ ។ កងទ័ពខ្មែរក្រហមបានស្ទាក់ក្បួនរថយន្តរបស់ព្រះអង្គ ពេលព្រះអង្គធ្វើដំណើរដល់ត្រឹមស្រុកអង្គស្នួល ហើយបានដេញព្រះអង្គនិងអ្នកម្នាង វរសាម៉ន ឲ្យចេញពីរថយន្ត ។ តាំងពីបានជួបម្តងនោះមក ជី មិនដែលបានជួបឬទទួលដំណឹងអំពី សោ ទៀតឡើយ ។

មានថ្ងៃមួយប្រធានសហករណ៍ចង់ធ្វើបាប ជី ហើយបានចាត់តាំង ជី ឲ្យទៅដឹកដែកនិងលត់កាំបិតនៅមន្ទីរស្រុកនៅភូមិកោះចិន ដើម្បីចាប់កំហុស ។ ជី បានរួចរស់ពីការប៉ុនប៉ងនេះវិញ ដោយសារគាត់ខំប្រឹងធ្វើការដោយមិនហ៊ានតមាត់រហូតសម្រេចតាមផែនការ ។

ដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយឈ្នះកងទ័ពខ្មែរក្រហម ។ អង្គការបានជម្លៀសប្រជាជនទៅទិសខាងលិច ដើម្បីគេចពីវៀតណាម ក៏ប៉ុន្តែ ជី និងក្រុមគ្រួសារបានសម្ងំលាក់ខ្លួននៅក្នុងព្រៃក្បែរៗភូមិ រហូតដល់ខ្មែរក្រហមដកចេញអស់ពីភូមិ ទើបគាត់ធ្វើដំណើរទៅភូមិកំណើតវិញ ។

ជី បញ្ជាក់ថាគាត់អាចរួចជីវិតពីរបបខ្មែរក្រហម មិនមែនមកពីគាត់ធ្វើការងារល្អទេ គឺមកពីគាត់ចេះសម្របខ្លួនតាមនយោបាយរបស់ខ្មែរក្រហម ហើយគាត់មិនដែលនិយាយអ្វីដែលប្រឆាំងនឹងបដិវត្តន៍ឡើយ ។ ទោះបីជាទ្រឹស្តីរបស់អង្គការខុសពីឧត្តមគតិរបស់ខ្លួនក៏ដោយ ជី តែងតែដាក់ខ្លួននៅចំពោះមុខកម្មាភិបាលខ្មែរក្រហមរហូត ។

ជី ខស្បាហ៍និយាយរឿងរ៉ាវរបស់ខ្លួនប្រាប់សាច់ញាតិនិងអ្នកជិតខាង ជាពិសេសក្មេងៗដែលកើតមិនទាន់របបកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យក្មេងៗទាំងនោះបានយល់ដឹងពីប្រវត្តិរបបកម្ពុជាប្រជាធិបតេយ្យ ព្រោះ ជី យល់ថាការដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួនអាចការពារមិនឲ្យរបបនោះកើតមានឡើងម្តងទៀត ។

**ណាយ សុផារី**

## ពាក្យស្លោកខ្មែរក្រហម

- **ស្លាប់ជាការធម្មតារបស់អ្នកតស៊ូ**
- **ត្រូវមានស្មារតីរក្សាការសម្ងាត់ខ្ពស់**
- **ស្លាប់ក្នុងសង្គ្រាមប្រសើរថ្លៃថ្លា**
- **រក្សាការពារនិងពង្រឹងសាមគ្គីភាព ឯកភាពផ្ទៃក្នុង «សម្ព័ន្ធយុវកក តាមគោលជំហរ លក្ខន្តិកៈ និងកម្មវិធីនយោបាយរបស់សម្ព័ន្ធយុវកក»**

*(សៀវភៅកំណត់ហេតុលេខ១០ ៧/៧)*

# ចំណោទឧក្រិដ្ឋកម្ម
# មន្ទីរសន្តិសុខភូមិភាគនិរតី
# ការកកើត ប្រតិបត្តិការ និង ទំនាក់ទំនង

***(តពីលេខមុន)***

***របបអាហារ***

របបអាហាររបស់អ្នកទោសក្នុងមន្ទីរអប់រំស្រុកមានពីរពេលក្នុងមួយថ្ងៃ គឺពេលថ្ងៃត្រង់នៅម៉ោង១១និងពេលរសៀលនៅម៉ោង៦ ។ រីឯចំណីរអាហារវិញមានតែបបរាវកក្កុកពីរ-បីស្លាបព្រាលាយជាមួយត្រកួននិងដើមចេកប៉ុណ្ណោះ ។ អ្នកទោស១០០នាក់ទទួលបានអង្ករចំនួន៦-៧កំប៉ុង និងអំបិលពីរ-បីក្ដាប់ក្នុងមួយពេល ។ កង្វះខាតកើនឡើងកាន់តែខ្លាំងនៅពេលដែលចំនួនអ្នកទោសនៅក្នុងមន្ទីរអប់រំស្រុកកើនឡើង ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ អ្នកទោសមន្ទីរអប់រំស្រុកត្រាំកក់ចំនួន១៨៤នាក់ ទទួលបានរបបអង្ករចំនួន១៦កំប៉ុង និងអំបិល៣កំប៉ុងក្នុងមួយថ្ងៃ ។ ការកំណត់របបអង្ករនិងអំបិលខាងលើគឺការកំណត់អង្កកន្លះកំប៉ុងសម្រាប់អ្នកទោស១២នាក់ក្នុងមួយពេលអំបិលកន្លះកំប៉ុងសម្រាប់អ្នកទោសចំនួន៦២នាក់ ។ ញ៉ អតីតអ្នកដាំស្លក្នុងមន្ទីរអប់រំស្រុកត្រាំកក់បញ្ជាក់ថា នៅពេលចំនួនអ្នកទោសកើនឡើងលើសពី ២០០ រហូតដល់៣០០នាក់ ឬ ៤០០នាក់ ក៏របបអាហាររបស់អ្នកទោសនៅតែកន្លះកំប៉ុងសម្រាប់១២នាក់ដដែល ។

របបអាហាររបស់អ្នកទោសក្នុងមន្ទីរអប់រំស្រុកកណ្ដាលស្ទឹង និងស្រុកដទៃទៀត ក៏មានលក្ខណៈខ្វះខាតដូចរបបអាហាររបស់អ្នកទោសក្នុងមន្ទីរអប់រំស្រុកត្រាំកក់ដែរ ។ អ្នកទោសចំនួន១០០នាក់ ប្រធានមន្ទីរអប់រំស្រុកកណ្ដាលស្ទឹង ចែករបបឲ្យទឹកមួយខ្ទះនិងអង្ករ៤-៥ក្ដាប់ក្នុងមួយពេល ។ ពេលចំនួនអ្នកទោសកើនឡើងពី១០០ទៅ៥០០នាក់ របបទឹកកើនឡើង ប៉ុន្តែរបបអង្ករនិងអំបិលមិនកើនតាមចំនួនអ្នកទោសទេ ។ តាំ និង ឈន់ ជាអ្នកដាំស្ល និងរៀបចំបាយទឹកឲ្យអ្នកទោសបានឲ្យដឹងថា អ្នកទោសចំនួនជាង៥០០នាក់ គាត់ដាក់អង្ករតែប៉ុន្មាន ក្ដាប់ចូលក្នុងខ្ទះហើយតម្រូវឲ្យហូបទាំងអស់គ្នា ។ នៅមន្ទីរអប់រំស្រុកលើកដែកវិញ អ្នកទោសទទួលបានតែទឹកមួយខ្ទះ ពោត២គីឡូក្រាមនិងអំបិលមួយក្ដាប់ ជួនកាលបបរលាយដើមចេកក៏មាន ។ អ្នកទោសម្នាក់ៗទទួលរបបអាហារមួយចានដែលនៅក្នុងនោះពោត១០-២០គ្រាប់ និងរសជាតិប្រៃរបស់អំបិលក្រួស ។ ម្នាក់ៗហេវហត់សល់តែស្បែកដណ្ដប់ឆ្អឹង ។ ហ៊ុម ឡេស និង ម៉ាត់ ទូល័ស អតីតអ្នកទោសមន្ទីរអប់រំស្រុកកោះធំបានឲ្យដឹងថា របបអាហាររបស់អ្នកទោសមន្ទីរអប់រំស្រុកកោះធំមានតែកន្ទក់ គល់ល្ហុង គល់ចេកចិតហាន់ស្ដើងៗលាយជាមួយបបរដែលមានលក្ខណៈដូចអាហាររបស់ជ្រូក ។ អ្នកទោសត្រូវដាច់ចិត្តបរិភោគសូម្បីតែជីងចក់ និងសត្វល្អិតផ្សេងទៀតដើម្បីបានរស់ ។

អតីតអ្នកដាំស្លនិងអ្នកទោសមន្ទីរអប់រំស្រុកអះអាងថា ការខ្វះខាតរបបហូបចុករបស់អ្នកទោសមានទំហំធំធេងណាស់រហូតដល់អ្នកទោសមួយចំនួនស្លាប់ ។ ញ៉ លើកដៃទាំងពីររបស់គាត់ប្រណម្យឡើងលើ ហើយនិយាយថា “ព្រះអើយអ្នកខ្លះស្លាប់ទៅអត់បាយអត់ទឹក កុំខឹងខ្ញុំគេកំណត់ឲ្យអីចឹង ។ ជួយនរណាក៏មិនបានសូម្បីតែកូនខ្ញុំ ក៏ខ្ញុំជួយមិនបានដែរ” ។ ញ៉ ពន្យល់ថា គាត់មិនអាចធ្វើអ្វីហួសពីការផ្ដល់ដែលសមមិត្ត អាន់ ប្រធានមន្ទីរអប់រំស្រុកត្រាំកក់កំណត់ឲ្យគាត់ធ្វើឡើយ ។ ការផ្ដល់ប្រចាំថ្ងៃរបស់ ញ៉ គឺយកអង្ករនិងអំបិលពីសមមិត្ត អាន់ ទៅចែកឲ្យអ្នកទោស និងដើររកត្រកួនត្រកៀតមកស្លឲ្យអ្នកទោសហូប ។ ញ៉ ប្រាប់ឲ្យដឹងថា ចំពោះអាន់ អ្នកទោសដែល “មិនបានការស៊ីច្រើនគ្មានប្រយោជន៍” ។ សំណាង ទទួលស្គាល់ថា អ្នកទោសពេលនោះពិត ជាគ្មានប្រយោជន៍មែន ដូច្នេះរបស់របរដែលអ្នកទោសទទួលបានអំពីប្រធានមន្ទីរមកបរិភោគ ក៏សុទ្ធតែជារបស់គ្មានប្រយោជន៍ដែរ ។ ពេលនោះ

សំណាង កូនរបស់ ញ៉ ហូបទាំងអស់នូវអ្វីដែលគាត់អាចរកបាន ។ សំណាង បញ្ជាក់ថា «កណ្ដុរ ថ្លែន ឲ្យតែរត់កាត់ គឺចាប់ដុតហូបភ្លាម» ។ សែន និងអ្នកទោសដែលជាប់នៅក្នុងបន្ទប់ឃុំឃាំងទទួលបានបបរពីរពេលក្នុងមួយថ្ងៃ ។ មួយពេលទទួលបានរបបអាហារមួយកូនចានចង្កឹះប៉ុណ្ណោះ ។ ម៉ៅ ជាប់ឃុំឃាំងជាមួយ សែន ដែរ បានឲ្យដឹងថា ថ្ងៃណាក៏ដូចថ្ងៃណា បបររាវលាយជាមួយអំបិល និងសម្លព្រលិតលាយត្រកួនម្តងម្កាល ។ ម៉ៅ សង្កេតឃើញរបបខុសគ្នារវាងអ្នកទោសធ្ងន់និងអ្នកទោសស្រាល «អ្នកទោសស្រាលអាចមានឱកាសរកបានកង្កែប ខ្យងដុត មកហូបបានចំពោះអ្នកទោសធ្ងន់មានតែហេវដល់ស្លាប់ប៉ុណ្ណោះ» ។

បន្ទាប់ពីមានបញ្ជាឲ្យប្រហារជីវិតអ្នកជាំបាយម្នាក់ អាន់ បានតែងតាំង តា ញ៉ ជំនួសវិញ ។ ពេលនោះ ញ៉ អាចមានឱកាសរកកង្កែប ខ្យងខ្ចៅ ផ្លែឈើលាក់ទុកសម្រាប់បរិភោគ ។ ថ្ងៃមួយនៅពេល ញ៉ ដើរកខស គាត់ប្រទះឃើញសត្វឆ្កែពាំព្រ័ត្រគោប្រវែងប្រហែល១ម៉ែត្រ ។ ញ៉ បានដេញឆ្កែនោះ ហើយដណ្ដើមបានព្រ័ត្រពីវា ។ ញ៉ បានយកព្រ័ត្រទៅលាក់ទុកនៅគុម្ពោតព្រៃក្បែរមន្ទីរអប់រំ ។ នៅពេលទៅរកខសម្តងៗ ញ៉ បានកាប់ព្រ័ត្រជាកង់ៗដុតយកមកចែកកូនគាត់ហូប ។ សំណាង នៅចងចាំគ្រាដែលគាត់ទទួលបានអាហារពិសេសដែលម្ដាយរបស់គាត់លាក់ទុកនិងចែកឲ្យគាត់ ។ សំណាង រំឭកថា «ខ្ញុំបានរស់ដោយសារព្រ័ត្រគោនិងកណ្ដុរថ្លែនហ្នឹងហើយ» ។

គេង មានឱកាសរើសនិងបេះផ្លែឈើបរិភោគនៅពេលគាត់ចេញទៅកាប់ខសនិងធ្វើការងារនៅខាងក្រោមន្ទីរអប់រំ ប៉ុន្តែគាត់មិនអាចរើសផ្លែឈើទុកដើម្បីយកមកហូបឬចែកអ្នកទោសក្នុងមន្ទីរអប់រំបានឡើយ ។ គេង បញ្ជាក់ថា «ផ្លែស្វាយ ផ្លែល្ហុង ទុំជ្រុះ បើឃើញរើសហូបមិនអីទេ តែបើរើសច្រកហោប៉ៅ គឺមិនបានតែម្តងមិនដឹងយ៉ាងម៉េច» ។ ការរើសបេះបោចបន្លែបង្ការផ្លែឈើ ជាទោសមួយកំណត់ដោយកម្មាភិបាលមន្ទីរអប់រំស្រុកទ្រាំង ។ ហួយ បានឲ្យដឹងថា ទោសនៃការបេះបោចបន្លែបង្ការនៅពេលចេញទៅធ្វើការនៅខាងក្រៅ គឺត្រូវក្បាលនឹងដំបង និងទាត់ធាក់ឥតប្រណី ។

របបអាហារសម្រាប់អ្នកទោសមានលក្ខណៈខ្វះខាតខ្លាំង មិនយូរប៉ុន្មានអ្នកទោសមួយចំនួនចាប់ផ្ដើមស្រកទម្ងន់និងកើតជំងឺរាករូស ហើមស្លេក និងរោគសើស្បែកជាច្រើនទៀត ។ អ្នកទោសមួយចំនួន ត្រូវស្លាប់បាត់បង់ជីវិតមុនពេលយកទៅសួរចម្លើយ ហើយខ្លះទៀតស្លាប់ដោយការធ្វើទារុណកម្ម ។ ប្រសិនបើអ្នកទោសស្លាប់នៅពេលយប់ យុទ្ធជនខ្មែរក្រហមមិនយកសាកសពទៅណាភ្លាមឡើយ សាកសពនឹងត្រូវទុករហូតដល់ពេលព្រឹក ឬដល់ពេលល្ងាចទម្រាំអ្នកទោសស្រាលសម្រាកពីការងារទើបសែងសាកសពទៅកប់ ។ គេង ប្រាប់ឲ្យដឹងថា អ្នកទោសដែលស្លាប់ដោយសារការអត់អាហារក្នុងមន្ទីរអប់រំស្រុកលើកដែកក្នុងមួយយប់ៗមានពី៥-៦នាក់ ។ អ្នកទោសមន្ទីរអប់រំស្រុកត្រាំកក់ ក៏មានឈឺស្លាប់ដូចករណីនៅក្នុងមន្ទីរអប់រំស្រុកលើកដែកដែរ ។ សាំង កម្មាភិបាលមន្ទីរអប់រំស្រុកត្រាំកក់ ពន្យល់ហេតុផលនៃការស្លាប់របស់អ្នកទោសដោយជំងឺថា «សំខាន់គឺ ឈឺគ្រាំគ្រា ខ្វះអាហារ និងការព្យាបាល» ។

ញ៉ និង សំណាង បានចាត់ទុកវិធីផ្ដល់របបអាហាររបស់ សមមិត្ត អាន់ ដល់អ្នកទោសថាជាវិធីប្រហារជីវិតដោយប្រយោល ។ សំណាង ពន្យល់ថា ប្រជាជននៅតាមសហករណ៍ធ្វើការងារទទួលបានរបបហូបចុកខ្វះខាត ចុះទម្រាំអ្នកទោសធ្វើ ការមិនកើតគ្មានប្រយោជន៍មានហេតុផលអ្វីនឹងទទួលរបបគ្រប់គ្រាន់ ។

អ្នកឯកទេសម្នាក់ឈ្មោះ ខូហ្វល បានសិក្សាអំពីមូលហេតុផ្ដល់របបអាហារខ្វះខាតដល់អ្នកទោសនៅក្នុងមន្ទីរសន្តិសុខ ។ ការផ្ដល់អាហារមិនគ្រប់គ្រាន់សម្រាប់អ្នកទោស គឺជាវិធីធ្វើឲ្យអ្នកទោសធ្លាក់ក្នុងសភាពអត់ឃ្លាននិងឯកោ និងជាវិធីវាយបំបាក់ស្មារតីអ្នកទោសឲ្យទន់ខ្សោយ ទាំងស្មារតី និងអារម្មណ៍ ។ នៅពេលដែលអ្នកទោសត្រូវបានវាយបំបាក់រួចហើយ អ្នកទោសងាយនឹងយល់ព្រមតាមការលួងលោមសួរចម្លើយរបស់កម្មាភិបាលសួរចម្លើយបំផុត ។

## ការសួរចម្លើយនិងការធ្វើទារុណកម្ម

វិធីសាស្ត្រសួរចម្លើយ នៅមន្ទីរអប់រំស្រុកក្នុងភូមិភាគនិរតី មានលក្ខណៈតាមលំដាប់លំដោយ និងបន្តបន្ទាប់ប្រហាក់ប្រហែលនឹងការសួរចម្លើយក្នុងមន្ទីរស-២១ដែរ ។ លក្ខណៈដូចគ្នានោះរួមមានការបំពាក់បំប៉នគោលជំហរមិនឲ្យមានការស្ទាក់ស្ទើរ មន្ទិលសង្ស័យ និងដាច់ខាតចំពោះខ្មាំង ។ ខ្មាំងដែលបក្សចាប់មកដាច់ខាត

ត្រូវតែឃុំឃាំង បង្អត់អាហារ លួងលោម សួរសំណួរដោយគំរោះគំរើយ ជេរស្តី និងធ្វើទារុណកម្ម ដើម្បីយកចម្លើយសារភាពជូនបក្ស ។ ជ័យជម្នះក្នុងការយកចម្លើយសារភាពអំពីខ្មាំង គឺដើម្បីធ្វើឲ្យអ្នកទោសឆ្លើយសារភាព ពន្យល់ហេតុផលនៃការចាប់ខ្លួន រៀបរាប់អំពី ខ្សែសង្វាក់ចាត់តាំងនិងបក្សពួករបស់ខ្លួនជូនបក្សឲ្យអស់ ។

នៅក្នុងសៀវភៅបញ្ជីស្ថិតិសន្តិបាលមន្ទីរស-២១ សរសេរថា "មនុស្សដែលបក្សចាប់មកមានពីរប្រភេទ ១) ប្រភេទប្រឆាំងខ្លាំងនៅតាមមូលដ្ឋាន និង២) ប្រភេទដែលបក្សបានពិនិត្យតាមដានច្បាស់លាស់តាមការរាយការណ៍របស់កម្មាភិបាលមន្ទីរសន្តិសុខ" ។ ការបំពាក់បំប៉នអំពីភាពមានទោសរបស់អ្នកទោសធ្វើឲ្យកម្មាភិបាលសួរចម្លើយដឹងថា ប្រជាជនដែលមកដល់មន្ទីរសន្តិសុខសុទ្ធតែជាខ្មាំងរបស់អង្គការ ។ គ្មានការលើកលែង គ្មានការសង្ស័យ ទោះបីជាជននោះត្រូវជាបងប្អូនញាតិញាតិរបស់កម្មាភិបាលមន្ទីរសន្តិសុខក៏ដោយ ។ ការណ៍នេះអាចរកឃើញតាមរយៈកំណត់ហេតុរបស់កម្មាភិបាលសួរចម្លើយដែលសរសេរអំពីការងារសួរចម្លើយក្នុងសៀវភៅកំណត់ហេតុរបស់ខ្លួនថា "កម្មាភិបាលសួរចម្លើយ ត្រូវតែមានគោលជំហរជឿជាក់លើបក្សដាច់ខាត មិនត្រូវស្ទាក់ស្ទើរមន្ទិលសង្ស័យក្នុងសតិអារម្មណ៍ ទោះជាអ្នកទោសនោះជាសាច់ញាតិ បងប្អូនរបស់ខ្លួនក៏ដោយ" ។ នៅពេលដែលកម្មាភិបាលសួរចម្លើយមានអារម្មណ៍ជ្រះថ្លា មានគោលជំហរច្បាស់លាស់ថាខ្មាំងដែលបក្សចាប់មកគឺជា "គិញ" ពេលនោះកម្មាភិបាលសួរចម្លើយនឹងអាចអនុវត្តការងារសន្តិបាលបានយ៉ាងជោគជ័យ ដោយសារបានឆ្កឹះកកាយរកឃើញអាថ៌កំបាំងដែលខ្មាំងខំលាក់ទុក និងបង្ហាញបក្សអំពី "ជនជំពាក់ជំពិនជាមួយខ្មាំង" ។

វិធីនៃការឆ្កឹះកកាយរកអាថ៌កំបាំងអំពីខ្មាំងមានច្រើន ។ វិធីដែលសំខាន់គឺ "ឃោសនាលួងលោមធ្វើឲ្យអ្នកទោសស្រពេចស្រពិលអំពីបញ្ហាស្លាប់រស់ ។ ការសង្កត់អំពីភាពច្បាស់លាស់របស់បក្សក្នុងការចាប់ខ្មាំង ។ ការបំបែកបំបាក់អ្នកទោសឲ្យលែងទុកចិត្តគ្នាវា មេវា និងការរក្សាទុកអ្នកទោសឲ្យរស់បានយូរគឺដើម្បីយកចម្លើយជូនបក្ស" ។ លទ្ធផលនេះគឺជាជ័យជម្នះដ៏ធំធេងដែលធ្វើឲ្យមហាជនរីករាយ និងធ្វើឲ្យបក្សបានរីកលូតលាស់មហាលោតផ្លោះ និងមហាអស្ចារ្យ មិនមែនធ្វើឲ្យមហាជន "ស្រពាប់ស្រពោន ចលនាចុះថយនោះឡើយ" ។

វិធីសាស្ត្រជាក់ស្តែងក្នុងការសួរចម្លើយ គឺដាច់ខាតត្រូវតែ "ធ្វើនយោបាយលួងលោម និងធ្វើទារុណកម្ម" ។ វិធីសាស្ត្រធ្វើនយោបាយលួងលោមមាន៩ចំណុច ៈ ការឲ្យចំណី ការអូសទាញឲ្យវិលវល់ក្នុងវង្វង់គ្រួសារ ប្រពន្ធកូន ការបញ្ជាក់ថាអ្នកទោសមានកំហុសតូចតាចមិនមែនជាមេក្បត់ ការសន្យាឲ្យឋានៈ ការងារ និងការមិនប្រកាន់ទោសពៃរ៍ ។ ឧទាហរណ៍មួយនៃដំណើរការលួងលោមយកចម្លើយរបស់សមមិត្ត ប៉ុន លើអ្នកទោសឈ្មោះ សែន គឺ "បង បើបងរាយការណ៍អំពីអាថ៌កំបាំងរបស់បក្សបង បានន័យថា បងក្បត់បក្សបង ហើយចូលរួមដៃ ជាមួយបក្សយើងសព្វថ្ងៃវិញ ។ ដូចនេះបក្សក៏មិនខ្វាចប្រើបងដែរ ។ តែបើបងពុំរាយការណ៍វិញ បានន័យថា បងរឹងរូសរក្សាកម្លាំងក្បត់របស់បង រក្សាផែនការបំផ្លាញបក្សយើងទៀត ។ ដូចនេះ ក្នុងន័យរក្សារដ្ឋអំណាចការពារបក្សយើងសព្វថ្ងៃ បក្សក៏មិនអនុគ្រោះបងដែលមាននះបែបនេះជាដាច់ខាត" ។

វិធីសាស្ត្រលួងលោមធ្វើនយោបាយ និងធ្វើទារុណកម្មរបស់កម្មាភិបាលសួរចម្លើយលើអ្នកទោស ទំនងធ្វើឲ្យអ្នកទោសមួយចំនួនឆ្លើយសារភាពអំពីទោសកំហុសរបស់ខ្លួន ក្នុងក្តីសង្ឃឹមទទួលបានការប្រោសប្រណី ។ ផ្ទុយទៅវិញ បន្ទាប់ពីឆ្លើយសារភាពរួច អ្នកទោសត្រូវបក្សចារសម្រេចឲ្យយកទៅប្រហារជីវិត ។ សែន ព្រមឆ្លើយសារភាពតាមវិធីសាស្ត្រលួងលោមរបស់សមមិត្តប៉ុន ប៉ុន្តែ នៅទីបំផុត សែន ត្រូវបានបក្សសម្រេចប្រហារជីវិតនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៧ ។ អ្នកទោសម្នាក់ទៀតឈ្មោះ ប្រាហ៊ីម ខិតខំច្នៃប្រឌិតចម្លើយសារភាពប្រាប់កម្មាភិបាលសួរចម្លើយអំពីទោសកំហុសរបស់ខ្លួន ក្នុងក្តីសង្ឃឹមថាបានការប្រណីអំពីបក្ស ។ ប្រាហ៊ីម សរសេរសារភាពថា "ទើបតែពេលនេះដែលខ្ញុំបាទជឿដោយស្មោះថា អង្គការបដិវត្តត្រូវការភាពស្មោះត្រង់ដើម្បីងាយស្រួលសហការគ្នាទៅថ្ងៃក្រោយ" ។ ផ្ទុយស្រឡះពីការសង្ឃឹមទុក ប្រាហ៊ីម ត្រូវបានបក្សសម្រេចចារឲ្យប្រហារជីវិតនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៦ ។

អ្នកទោសមន្ទីរស-២១ ត្រូវសួរចម្លើយជាច្រើនលើក

ច្រើនសា ។ សួរលើកទីមួយ មិនបានសម្រេចត្រូវសួរលើកទីពីរ និងលើកទីបីទៀត ។ ការសួរចម្លើយជាបន្តបន្ទាប់ គឺដើម្បីប្រមូលយកចម្លើយសារភាពឲ្យអស់ ។ បានសេចក្តីថា រកខ្សែសន្ទាក់ក្បត់ទាំងអស់ដូចពាក្យស្លោកខ្មែរក្រហមនិយមមៅមួយពោលថា "ជីកស្មៅត្រូវជីកទាំងឫស" ។ ចំពោះដំណាក់កាលសួរចម្លើយបន្តបន្ទាប់ទៀតនោះ វិធីសាស្ត្រនៃការសួរចម្លើយក៏ត្រូវផ្លាស់ប្តូរដែរ ។ ការផ្លាស់ប្តូរមានដូចខាងក្រោម ៖

១) ដំបូងត្រូវស្រង់ព័ត៌មានពីវា ២) បន្ទាប់មកគឺត្រូវប្រមូលចំណុចឲ្យច្រើនសម្រាប់សង្កត់វាកុំឲ្យវារើរួច ៣) ឃោសនាកៀបវាខាងនយោបាយ ៤) សង្កត់សួរដោយជេរ ៥) ទារុណកម្ម ៦) ពិនិត្យ វិភាគចម្លើយ ដើម្បីសួរតទៅទៀត ៧) ពិនិត្យ វិភាគចម្លើយដើម្បីធ្វើឯកសារ ៨) ការពារវាឲ្យជាប់ ការពាក្រុមឲ្យជាប់កុំឲ្យពួក្លា និង៩) រក្សាការសម្ងាត់ ។

វិធីសួរដោយគំរោះគំរើយ ការជេរ ការកៀបសង្កត់ខាងនយោបាយ និងការធ្វើទារុណកម្មប្រើចំពោះអ្នកទោសណាដែលឆ្លើយថា អត់ដឹង នេះគឺជាមូលដ្ឋានគ្រឹះជួយឲ្យអ្នកសួរចម្លើយអាចទទួលបានចម្លើយសារភាពអំពីអ្នកទោស ។ រហូតដល់សព្វថ្ងៃ វ៉ាន់ ណាត អតីតអ្នកទោសមន្ទីរស-២១ នៅតែមិនទាន់ដឹងច្បាស់អំពីមូលហេតុនៃការចាប់ខ្លួននៅឡើយ ហើយកម្មាភិបាលសួរចម្លើយគាត់នៅពេលនោះក៏មិនបានដឹងអំពីមូលហេតុនៃការចាប់ខ្លួនរបស់គាត់ដែរ ។ វ៉ាន់ ណាត រៀបរាប់សំណួរដែលកម្មាភិបាលសួរចម្លើយមន្ទីរស-២១ សួរគាត់ "ហេតុអីបានជាអ្នកឯងត្រូវចាប់ខ្លួនមក" ខ្ញុំអត់ដឹងដែរ ។ "អង្គការមិនដែលចាប់មនុស្ស ដែលគ្មានកំហុសទេ ។ ឆ្លើយសារភាពពីកំហុសរបស់ឯងទៅ" ។

បន្ទប់សួរចម្លើយអ្នកទោសមន្ទីរអប់រំស្រុកសង់ជារោងដាច់ចេញពីបន្ទប់ឃុំឃាំង ។ បន្ទប់សួរចម្លើយត្រូវបាំងជិតដោយក្តារបន្ទះ និងស្លឹក ងាយស្រួលធ្វើទារុណកម្មយកចម្លើយនិងលាក់ការណ៍សម្រែករបស់អ្នកទោស ។ នៅក្នុងបន្ទប់សួរចម្លើយមានតុមួយសម្រាប់កត់ត្រា និងកៅអី១ សម្រាប់អ្នកទោសអង្គុយ ។ ការងារសួរចម្លើយ ជាការងារសម្ងាត់របស់បក្ស ជាការងារដោះស្រាយទំនាស់ ជាការងាររបស់អ្នកបដិវត្តន៍និងខ្មាំង ។ បន្ទប់សួរចម្លើយអ្នកទោសនៅមន្ទីរអប់រំស្រុកសំរោង សង់ឡើងពីឈើប្រក់ស្លឹកនៅជ្រុងខាងជើងនៃបន្ទប់ឃុំឃាំង មានចម្ងាយ១០ម៉ែត្រនៅខាងជើងវិហារ ។ យ៉ាន អតីតកម្មាភិបាលមន្ទីរអប់រំស្រុកសំរោងបានឲ្យដឹងថា អ្នកទោស នៅមន្ទីរអប់រំស្រុកសំរោងដែលត្រូវសួរចម្លើយ ដំបូងត្រូវនាំចេញពីបន្ទប់ឃុំឃាំង ហើយបណ្តើរទៅសួរក្នុងបន្ទប់បាំងជិតនៅក្នុងព្រះវិហារជ្រុងខាងជើង ។ កម្មាភិបាលសួរចម្លើយបញ្ជាឲ្យអ្នកទោសអង្គុយលើកៅអី ហើយចាប់ផ្តើមនិយាយសួរនាំអ្នកទោសឲ្យឆ្លើយធម្មតា ប៉ុន្តែប្រសិនបើអ្នកទោសមិនព្រមឆ្លើយ នោះនឹងត្រូវរងការធ្វើទារុណកម្មមិនខាន ។

៣) ការប្រែក្លាយដំណើរបង្ខូចយុត្តិធម៌ ជាបទឧក្រិដ្ឋ ឧទាហរណ៍ ដូចជាការគំរាមកំហែងចៅក្រម និងការគាបសង្កត់ឬការជះឥទ្ធិពលមិនសមរម្យ ។ បទបញ្ញត្តិដែលពាក់ព័ន្ធនឹងដំណើរប្រែក្លាយយុត្តិធម៌ ជាបទឧក្រិដ្ឋនេះគឺមានចែងនៅក្នុងមាត្រា ៩៥ និង៩៦នៃច្បាប់អ៊ុនតាក់ (ការគំរាមសាក្សីនិងសក្ខីភាពក្លែងក្លាយ តែប៉ុណ្ណោះដែលជាបទឧក្រិដ្ឋ ហើយមិនមែនដំណើរបង្ខូចយុត្តិធម៌ ដូចជាអំពើសូកប៉ាន់ ឬគំរាមចៅក្រម ឬតួអង្គច្បាប់ផ្សេងទៀត) ។

## ៣) ចន្លោះប្រហោងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ

មានចន្លោះប្រហោងជាច្រើននៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជះឥទ្ធិពលមិនល្អដល់ប្រព័ន្ធច្បាប់នៅកម្ពុជា ។ ចន្លោះប្រហោងមួយក្នុងចំណោមចន្លោះប្រហោងនេះ គឺសិទ្ធិដែលត្រូវបានផ្តល់ជូនមិនត្រឹមតែអង្គជំនុំជម្រះ តែថែមទាំងសហចៅក្រមស៊ើបអង្កេតនិងសហព្រះរាជអាជ្ញាក្នុងការជ្រើសរើសនូវអ្វីដែលអង្គជំនុំជម្រះ ចៅក្រម និងសហព្រះរាជអាជ្ញាត្រូវការចេញពីនីតិវិធីកម្រិតអន្តរជាតិដើម្បីបំពេញនូវចន្លោះប្រហោងនៅក្នុងច្បាប់ជាតិ

ដែលឥទ្ធិពលនេះមិនត្រឹមតែបន្តនូវភាពរីករវរទេថែមទាំងបន្តឲ្យមានការរំលោភបំពានធ្ងន់ធ្ងរ ។ បទបញ្ញត្តិពីរទៀតដែលអនុញ្ញាតឲ្យមានការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជា គឺមាត្រា២០ និងមាត្រា២៣ ដែលចែងថាសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា "ប្រសិនបើការជួយឧបត្ថម្ភនេះពិតជាមានប្រយោជន៍ចំពោះការជំនុំជម្រះ" ។ ឱកាសដែលនាំឲ្យមានការរំលោភច្បាប់អាចដោះស្រាយបានតាមរយៈនីតិវិធីផ្ទៃក្នុង និងភ័ស្តុតាង ឬអនុស្សរណៈយោគយល់ ។

## ក) បញ្ហាអនុវត្តជាក់ស្តែង

### ១) អំពើពុករលួយនិងការសូកប៉ាន់

មាត្រា៣៨នៃច្បាប់អ៊ុនតាក់ចែងអំពីបញ្ហាអំពើពុករលួយ និងការចោទប្រកាន់និងការដកហូតមុខតំណែងមន្ត្រីដែលមានជាប់ពាក់ព័ន្ធនឹងអំពើស៊ីសំណូកឬទទួលយកគ្រឿងលើកទឹកចិត្តផ្សេងៗជាសំណងសម្រាប់ការជួយតបទៅវិញ ។ មាត្រា៥៨ ចែងអំពីអំពើសូកប៉ាន់ដោយចាត់ទុកជនទាំងឡាយដែលសូក ឬប៉ុនប៉ងសូកគ្រប់មន្ត្រីទាំងអស់ដោយសន្យាផ្តល់ឲ្យមន្ត្រីទាំងនោះនូវទ្រព្យសម្បត្តិ ប្រាក់ មុខងារ ឬកម្រៃអ្វីមួយជាថ្នូរដើម្បីសកម្មភាពខ្លះ ។

ដោយសារតែគ្មានច្បាប់ប្រឆាំងអំពើពុករលួយច្បាស់លាស់ និងការធ្វើវិសោធនកម្មច្បាប់គ្រប់គ្រងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្នុងពេលដែលការចាប់ផ្តើមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាខិតចូលមកជិតនោះ ការសូកប៉ាន់ និងអំពើពុករលួយរបស់តុលាការនឹងត្រូវដាក់ទោសទាំងស្រុងនៅក្រោមបទបញ្ញត្តិទាំងនេះ ។

### ២) អនុស្សរណៈយោគយល់

តុលាការត្រូវបង្កើតនូវអនុស្សរណៈយោគយល់ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាទាក់ទិននឹងបញ្ហាដែលតុលាការនិងរាជរដ្ឋាភិបាលកម្ពុជានឹងត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នា ។ ការដោះស្រាយសមាជិកភាពរវាងសមាជិកនៃអង្គជំនុំជម្រះនិងរាជរដ្ឋាភិបាលកម្ពុជាទៅលើបញ្ហារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែកំណត់ចំពោះបញ្ហាដែលមាននៅក្នុងអនុស្សរណៈយោគយល់នេះ ។ អនុស្សរណៈយោគយល់ក៏ត្រូវតែរាប់បញ្ចូលនូវបទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់ភាគីកម្ពុជាក្នុងការធានាសន្តិសុខដល់ចៅក្រមជាតិ ចៅក្រមអន្តរជាតិ និងក្រុមគ្រួសាររបស់ចៅក្រម ព្រមទាំងចាត់វិធានការការពារអ្នកទាំងនេះពីឥទ្ធិពលឬវិធានការដែលផ្ទុយពីវិធានការការពារអ្នកទាំងនេះទាក់ទិននឹងការអនុវត្តនូវមុខនាទីជាចៅក្រមរបស់ខ្លួន ។

### ៣) បុគ្គលិក

#### ក) ចៅក្រមអន្តរជាតិ

លក្ខខណ្ឌពិសេសរបស់ភាគីកម្ពុជាបានដាក់បន្ទុកខុសពីធម្មតាទៅលើចៅក្រមអន្តរជាតិ ។ ចរិតសំខាន់របស់ចៅក្រមអន្តរជាតិគឺជាអ្នកដែលមានវិជ្ជាជីវៈនិងសមត្ថភាពខ្ពស់ ហើយលក្ខណៈ សម្បត្តិរបស់ចៅក្រមអន្តរជាតិគឺឆ្លើយតបទៅនឹងតម្រូវការដែលចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ចៅក្រមអន្តរជាតិត្រូវបំពេញកាតព្វកិច្ចជាតំណាងសហគមន៍អន្តរជាតិនិងតម្លៃរបស់សហគមន៍ ។ ចៅក្រមអន្តរជាតិ ត្រូវតែមានសមត្ថភាពបំពេញកិច្ចការនៅក្នុងប្រព័ន្ធនេះដើម្បីលើកកំពស់គុណភាពនៃដំណើរការកាត់សេចក្តីដែលទទួលស្គាល់តាមកម្រិតស្តង់ដា ។ ភាពមិនលម្អៀងនិងឯករាជ្យភាពរបស់តុលាការនឹងធ្លាក់បន្ទុកទៅលើចៅក្រមអន្តរជាតិ ។ ការរំពឹងទុកជាមុននូវការចូលរួមពីសហគមន៍អន្តរជាតិនិងសាធារណជនចំពោះការជំនុំជម្រះក្តីដោយយុត្តិធម៌និងដំណើរការកាត់ក្តីត្រឹមត្រូវតាមផ្លូវច្បាប់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក៏នឹងធ្លាក់បន្ទុកទៅលើចៅក្រមអន្តរជាតិដែរ ។ ក្នុងនាមជាអគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ លោក ហាន កូរែល សរសេរថា "ចៅក្រមអន្តរជាតិបំពេញការងារនៅក្រោមក្រសែភ្នែករបស់ពិភពលោកទាំងមូល ហើយការចាប់អារម្មណ៍និងការបំពេញកាតព្វកិច្ចរបស់ចៅក្រមអន្តរជាតិនឹងឆ្លុះបញ្ចាំងដោយផ្ទាល់ពីគោលជំហរស្ថាប័នដែលចៅក្រមអន្តរជាតិបម្រើការងារជូន" ។

តាមរយៈការកំណត់សម្គាល់នូវការអនុវត្ត វាមិនមែនជាការត្រឹមត្រូវឡើយក្នុងការប្រើប្រាស់នូវនីតិវិធីជ្រើសរើសនិងគ្រប់គ្រងបុគ្គលិកតាមកម្រិតស្តង់ដារបស់អង្គការសហប្រជាជាតិ

ពីព្រោះថាបទពិសោធន៍ជាក់ស្តែងកន្លងមក ដូចជានៅប្រទេស ទីម័រខាងកើតនិងកូសូវ៉ូ មើលឃើញថាអង្គការសហប្រជាជាតិបាន បំពេញតួនាទីមិនត្រឹមត្រូវក្នុងការគ្រប់គ្រងចៅក្រម ឧទាហរណ៍ ការចាត់ចែងចៅក្រមឲ្យដោះស្រាយរឿងក្តីទាំងឡាយ និងកិច្ចសន្យារយៈពេលខ្លីរបស់ចៅក្រមទាក់ទិននឹងការពិនិត្យឡើងវិញនូវការងាររបស់ខ្លួន ។

### ១) ចៅក្រមជាតិ

ទិន្នន័យរបស់ធនាគារពិភពលោកឆ្នាំ២០០៤ បង្ហាញថា មួយភាគប្រាំមួយនៃចៅក្រមកម្ពុជា១១៧រូប មួយភាគប្រាំបួននៃចៅក្រមតុលាការកំពូល និងមួយភាគដប់នៃព្រះរាជអាជ្ញា មានសញ្ញាប័ត្រផ្នែកច្បាប់ ។ ជាក់ស្តែង វគ្គបណ្តុះបណ្តាលអំពីសារសំខាន់ច្បាប់គឺមានសារសំខាន់ខ្លាំងណាស់ ។ តាមការពិត ដំណើរការកាត់សេចក្តីបានចាប់ផ្តើមដំណើរការរួចទៅហើយ ស្របពេលជាមួយគ្នានោះដែរ វគ្គបណ្តុះបណ្តាលចៅក្រម អង្គជំនុំជម្រះលើកទីពីរដែលឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ទើបតែបញ្ចប់ ។ ម្យ៉ាងវិញទៀត ជំនាញផ្សេងៗក៏មានសារសំខាន់ផងដែរក្នុងស្ថានភាពដែលចៅក្រមជាតិចូលរួមក្នុងវគ្គបណ្តុះបណ្តាលមិនពេញលេញ ហើយចៅក្រមអង្គជំនុំជម្រះវិសាមញ្ញត្រូវការជាចាំបាច់នូវវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រផ្លូវច្បាប់ ការវាយតម្លៃភ័ស្តុតាង និងថាតើសម្រេចកំណត់និរទោសឬពិរុទ្ធភាពតាមគោលការណ៍និងសមហេតុសមផលដោយផ្អែកទៅលើភ័ស្តុតាងនៅក្នុងពេលជំនុំជម្រះក្តីដោយរបៀបណា ។

ក៏ប៉ុន្តែបញ្ហាចៅក្រមជាតិមិនមែនមានត្រឹមតែបញ្ហាសមត្ថភាពប៉ុណ្ណោះទេ តែថែមទាំងបញ្ហាឥរិយាបថរបស់ចៅក្រមចំពោះភាពមិនលម្អៀងនិងឯករាជ្យភាពរបស់តុលាការ ។ ដំណោះស្រាយបញ្ហានេះ គឺ"គម្រោងពហុជំនាន់" ។ កេរដំណែលនៃអំណាចផ្តាច់ការនៅកម្ពុជាបង្កើតនូវប្រព័ន្ធមួយដែលភាគីរដ្ឋប្រើប្រាស់តុលាការជាឧបករណ៍បម្រើឲ្យអ្នកដឹកនាំនយោបាយ និងសម្រាប់បម្រើផែនការផ្ទាល់ខ្លួន នយោបាយនិងមនោគមវិជ្ជា ។ មធ្យោបាយមួយដើម្បីបង្ហាញពីសារសំខាន់នៃអព្យាក្រឹតភាពរបស់តុលាការនិងតម្លៃនៃអព្យាក្រឹតនេះជាមូលដ្ឋានគ្រឹះសម្រាប់នីតិរដ្ឋនោះ គឺតាមរយៈការផ្សព្វផ្សាយយ៉ាងប្រុងប្រយ័ត្នទៅដល់ចៅក្រមអន្តរជាតិថ្នាក់កំពូលៗដែលមានសមត្ថភាពខ្ពស់ព្រមទាំងអង្កេតជាលើកដំបូងថាតើការជំនុំជម្រះក្តីដោយយុត្តិធម៌និងដំណើរការកាត់សេចក្តីត្រឹមត្រូវតាមផ្លូវច្បាប់នឹងដំណើរការយ៉ាងពិតប្រាកដនៅតុលាការអន្តរជាតិដោយរបៀបណា ។

តាមការគិតទុកជាមុន បញ្ហាមួយទៀតរបស់ចៅក្រមគឺការរើសអើងរបស់ចៅក្រមនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ តុលាការដែលបង្ហាញពីនយោបាយជាសាធារណៈត្រូវបានធ្វើឡើងនៅឆ្នាំ១៩៧៩ ដែលបានដាក់ទោសប្រហារជីវិតដល់ ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខៗ អស់ពេលជាច្រើនឆ្នាំ ប្រជាជនកម្ពុជាដក់ជាប់នឹងការឃោសនានយោបាយដែលប្រកាសថាអំពើទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជាជាផ្នែកមួយនៃអំពើប្រល័យពូជសាសន៍ ។ បន ប៉ុល ពត-អៀង សារី គឺជាអ្នកទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍នេះ ។ ថ្ងៃទី២០ ខែឧសភា ជាថ្ងៃតវ៉ាប្រឆាំងរបបកម្ពុជាប្រជាធិបតេយ្យនិងមេដឹកនាំខ្មែរក្រហម ដែលត្រូវបានស្គាល់ថា «ទិវាចងកំហឹង» ។ បញ្ហាទាំងនេះមានផលប៉ះពាល់យ៉ាងខ្លាំងថាតើប្រជាពលរដ្ឋកម្ពុជាមានទស្សនៈយល់ឃើញយ៉ាងដូចម្តេចអំពីប្រវត្តិសាស្ត្ររបស់ខ្លួនព្រមទាំងមានផលប៉ះពាល់ដល់សមត្ថភាពរបស់ចៅក្រមជាតិដែលនឹងត្រូវតែមានភាពអព្យាក្រឹត ។ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលរងនូវការឈឺចាប់ដោយផ្ទាល់ឬប្រយោលពីឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសន្មតជាមុនថា គ្មានទោស និងការរក្សាភាពមិនលម្អៀង នឹងបង្កជាបញ្ហាលំបាកសម្រាប់ចៅក្រមកម្ពុជា ។

បញ្ហាចុងក្រោយ បើទោះបីជាភាពមិនលម្អៀងនិងឯករាជ្យភាពរបស់តុលាការចាប់ផ្តើមឡើងដោយចៅក្រមដែលមានវិជ្ជាជីវៈ និងក្រមសីលធម៌ខ្ពស់ក៏ដោយ យើងមិនត្រូវទាមទារអ្វីច្រើនពេកពីចៅក្រមកម្ពុជានោះទេ ពីព្រោះចៅក្រមកម្ពុជាក៏ជាជនរងគ្រោះនៃសោកនាដកម្មនោះដែរ ។ ចៅក្រមកម្ពុជារស់នៅក្នុងបរិយាកាសគ្រោះថ្នាក់ជាងចៅក្រមបរទេស និងបន្ទាប់ពីចៅក្រមបរទេសចប់ភារកិច្ចរបស់ខ្លួននៅកម្ពុជា ចៅក្រមកម្ពុជានឹងត្រូវមានកាតព្វកិច្ចដោះស្រាយបទបញ្ញានិងលទ្ធផលក្រោយការ

វិនិច្ឆ័យរបស់ខ្លួនដែលជាផ្នែកមួយនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

### ឃ) ការគាបសង្កត់ខាងក្រៅ

កិច្ចព្រមព្រៀងរួមរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាគឺជាសន្ធិសញ្ញាអន្តរជាតិមួយដែលត្រូវបានបកស្រាយនៅក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញារវាងរដ្ឋជាភាគី និងអង្គការអន្តរជាតិតាមគោលការណ៍ *ប៉ាក់តា ស៊ុន សឺវវ៉ាន់ដា (Pacta Sunt Senvanda)*។ ជាការពិតណាស់មានភស្តុតាងជាច្រើន ដោយរាប់បញ្ចូលភស្តុតាងដែលបានមកពីសន្ធិសញ្ញាអង្គការពិនិត្យមើលការគោរពដែលថា ភាគីកម្ពុជារំលោភ និងបន្តរំលោភបំពានកាតព្វកិច្ចអន្តរជាតិជាច្រើន និងបំពេញកាតព្វកិច្ចរបស់ខ្លួនតិចបំផុតក្នុងការដោះស្រាយស្ថានភាពនេះ ។ កម្ពុជាមិនទាន់ត្រូវបានដាក់ឲ្យទទួលខុសត្រូវលើការរំលោភបំពានសន្ធិសញ្ញានិងកាតព្វកិច្ចច្បាប់អន្តរជាតិនៅឡើយទេ ។

មានការពិភាក្សាគ្នាជាមួយនឹងអ្នកត្រួតពិនិត្យពិសេសសម្រាប់ការជំនុំជម្រះក្តីរបស់អង្គការសហប្រជាជាតិដែលអាចផ្តល់ប្រឹក្សាឲ្យអង្គការសហប្រជាជាតិដកខ្លួនចេញពីការជំនុំជម្រះក្តីនេះ ប្រសិនបើមានការរំលោភបំពានធ្ងន់ធ្ងរលើដំណើរការជំនុំជម្រះក្តីដោយយុត្តិធម៌និងដំណើរការកាត់ក្តីត្រឹមត្រូវតាមផ្លូវច្បាប់នោះ ។ ក៏ប៉ុន្តែការពិត គឺមហាសន្និបាតអង្គការសហប្រជាជាតិពន្យល់រួចទៅហើយថាអង្គការសហប្រជាជាតិចង់បញ្ចប់ការជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមនេះឲ្យបានស្រេច ។ ការដែលដំណើរការកាត់សេចក្តីនេះមិនអាចឆ្លើយតបទៅនឹងតម្រូវការអន្តរជាតិនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ និងដំណើរការកាត់ក្តីត្រឹមត្រូវតាមផ្លូវច្បាប់ត្រូវបានលើកយកមកពិភាក្សាដដែល ដោយក្រុមប្រឹក្សាច្បាប់ផ្ទាល់របស់អង្គការសហប្រជាជាតិ និងលោកអគ្គលេខាធិការផ្ទាល់ ។ ថវិកាច្រើនខ្លាំងណាស់ត្រូវចំណាយសម្រាប់អង្គការសហប្រជាជាតិ ពីព្រោះអង្គការសហប្រជាជាតិត្រូវបង្ខំឲ្យចូលរួមនៅក្នុងដំណើរការកាត់ក្តីនេះដែលជះឥទ្ធិពលអាក្រក់ដល់គំនិតសំខាន់មួយចំនួនដែលចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងមានភារកិច្ចជំរុញ និងលើកកម្ពស់ដំណើរការនេះនៅលើពិភពលោក ។

ក៏ប៉ុន្តែបើទោះបីជាមហាសន្និបាតអង្គការសហប្រជាជាតិទំនងជាមិនអនុញ្ញាតឲ្យអង្គការសហប្រជាជាតិដកខ្លួនចេញពីដំណើរការនេះក៏ដោយ អ្នកពាក់ព័ន្ធទាំងឡាយត្រូវទទួលខុសត្រូវក្នុងការដោះស្រាយនូវរាល់បញ្ហាដែលទាក់ទងនឹងភាពមិនលម្អៀងនិងឯករាជ្យភាពរបស់តុលាការក្នុងបរិបទលក្ខណៈដ៏រឹងមាំ ។ ដូច្នេះប្រសិនបើកម្ពុជាមិនឆ្លើយតបទៅនឹងកាតព្វកិច្ចរបស់ខ្លួនដូចជាការធានាការពារភាពមិនលម្អៀងនិងឯករាជ្យភាពរបស់តុលាការជាដើមនោះនឹងមានសញ្ញាសុំដកខ្លួនចេញរបស់អង្គការសហប្រជាជាតិពីដំណើរការកាត់សេចក្តីនេះជាមិនខាន ។

### ៤) សន្និដ្ឋាន

កម្ពុជារក្សាអធិបតេយ្យភាពរបស់ខ្លួនជានិច្ចក្នុងអំឡុងពេលដំណើរការជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាប់តាំងពីប្រព័ន្ធអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាក់ឫសចូលទៅក្នុងហេដ្ឋារចនាសម្ព័ន្ធ នីតិវិធី និងច្បាប់កម្ពុជា ។ មិនថាក្នុងលក្ខខណ្ឌនយោបាយឬរចនាសម្ព័ន្ធជាក់ស្តែង គម្រោងនេះមិនអាចដំណើរការទៅបាន ប្រសិនបើគ្មានការអនុម័តយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជាដោយផ្ទាល់ ឬតាមរយៈមន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងដំណើរការកាត់ក្តីនេះ ។ ជាឧទាហរណ៍ មាត្រា ១៤នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញ ចែងថាគ្រប់សេចក្តីសម្រេចទាំងអស់របស់ចៅក្រមត្រូវតែព្រមព្រៀងគ្នាជាឯកច្ឆន្ទ ។ ប្រសិនបើចៅក្រមមិនអាចសម្រេចជាឯកច្ឆន្ទសេចក្តីសម្រេចនោះបន្តអនុម័តយកតាមសម្លេងភាគច្រើនលើសលុប ។ នេះមានន័យថាសូម្បីតែការខិតខំប្រឹងប្រែងពង្រឹងភាពមិនលម្អៀងនិងឯករាជ្យភាពរបស់តុលាការដោយចៅក្រមផ្ទាល់នឹងត្រូវតែមានការអនុម័តយល់ព្រមពីភាគីកម្ពុជាដែរ ។

វាមានសារសំខាន់ខ្លាំងណាស់ក្នុងការឈានទៅដល់អង្គជំនុំជម្រះវិសាមញ្ញ ដោយភ្ជាប់ជាមួយនឹងហេតុការណ៍ពិត ។ ហេតុការណ៍ពិតទាំងនេះមិនត្រឹមត្រូវ ហើយការខិតខំតស៊ូដើម្បីការជំនុំជម្រះក្តីដោយយុត្តិធម៌និងដំណើរការកាត់សេចក្តីត្រឹមត្រូវតាមផ្លូវច្បាប់នោះនឹងជួបការលំបាក ។ ការខិតខំប្រឹងប្រែងក្នុងការធានាដំណើរការកាត់ក្តីនេះឲ្យមានភាពសុចរិតដូចចែងនៅក្នុង

មាត្រា១៨នេះនិងដូចដែលបានពិភាក្សានូវផ្នែកខ្លះក្នុងសន្និសីទអន្តរជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្រោមប្រធានបទ "នៅចុងបញ្ចប់ យុត្តិធម៌ពិតជាមានមែនឬ?" នឹងពន្យារពេលដំណើរការកាត់សេចក្តីនេះច្បាស់ជាមិនខាន ។ ក៏ប៉ុន្តែនេះមិនមែនជាហេតុផលដែលបដិសេធមិនចូលរួមនោះទេ ។ ជាការពិតណាស់ កម្ពុជាសមនឹងទទួលនូវអ្វីល្អប្រសើរជាងនេះ ក៏ប៉ុន្តែអ្វីដែលអាចសម្រេចតិចបំផុតគឺជាការធានាកិច្ចខិតខំប្រឹងប្រែងល្អប្រសើរបំផុតក្នុងការជំរុញការខិតខំប្រឹងប្រែងនេះឲ្យទទួលខុសត្រូវបានល្អដូចនឹងអ្វីដែលអាចសម្រេចក្នុងស្ថានភាពនេះដែរ ។ តាមការពិត ដែលគួរឲ្យរន្ធត់នោះ គឺថា ប្រជាពលរដ្ឋកម្ពុជានឹងពុំមានឱកាសជាលើកទីពីរទៀតឡើយ ។

**ស៊ុហ្សាណា លីនគុន**



# ចម្រៀងខ្មែរក្រហម

## រដូវវស្សាហើយយើងប្រមូលកម្លាំងសម្រុកធ្វើស្រែ

ផ្គរលាន់ដើមឆ្នាំ រណ្តំមេឃា ជាសញ្ញាថា វស្សាដល់ហើយ ប្រញាប់ប្រញាល់
ឱបងប្អូនអើយ ធ្វើពីដើមដៃ ស្រូវយើងហុចផល ។
ផ្គរលាន់គ្រឹមៗ រលឹមតក់ៗ ភ្លៀងធ្លាក់ទឹកដក់ នៅសព្វមណ្ឌល យើងខ្ញុំយុវ័ន
ស្រវាននង្គ័ល រនាស់ខ្វាយខ្វល់ ភ្ជួររាស់ទាន់ពេល ។
រដូវវស្សាហើយ មិត្តអើយខំប្រឹង យើងផ្តុំកម្លាំង ឥតបីទំនេរ សម្រុកធ្វើស្រែ
ឲ្យបានផលទ្វេ ក្នុង១ហិកតា លើសពី៣ដង ។
យើងខ្ញុំនារី មូលមីរញ្ញាប់ដៃ កញ្ឆើនិងល្អី សាបផងបាចផង ទាំងពូជទាំងជី
រឹករាយកន្ទង សំណាបបំព្រង លាស់ឡើងខៀវខ្ចី ។
យើងខ្ញុំយុវ័ន ដៃកាន់នង្គ័ល ប្តេជ្ញាយកផល ឲ្យច្រើនក្រាស់ក្រៃ ភ្ជួររាស់ឲ្យសព្វ
សស្រុសអស់ដី ប្រព័ន្ធភ្លឺថ្មី ចាំងចែងពីកើត ។
ស្រែយើងអស់ទឹក បញ្ចឹកដោះស្រាយ យើងមានប្រឡាយ ភ្លឺត្រង់ខ្វែងខ្វាត់
មានស្ទឹងមានបឹង ទន្លេហូរកាត់ យើងជាន់រហាត់ បញ្ចូលទឹកស្រែ ។
យើងបន្តភ្ជួរ រាស់អស់ដីយើង យើងដកស្ទូងផង ជាប់ជាហូរហែ សន្ទូងយើងដុះ
យើងខ្ញុំប្រឹងថែ ជនបទយើងប្រែ ខៀវស្រស់បំព្រង ។
យើងខ្ញុំរើសពូជ បាចជីជាមួយ យើងខ្ញុំលើកស្ទួយ គុណភាពដីយើង ដើម្បីបង្កើន
ផលឲ្យបានច្រើន ផលិតកម្មយើងកើន ជីវភាពធូរធារ ។
ប្តេជ្ញាៗ ប្រមូលកម្លាំង វាយសម្រុកខ្លាំង មហាអស្ចារ្យ ធ្វើស្រែឆ្នាំនេះ
ឲ្យបានផល្លា រួមសាងកម្ពុជា មហាលោតផ្លោះ ។

(សៀវភៅកំណត់ហេតុលេខ១០០៦)

# បាត់បង់ប្អូនពីរនាក់នៅក្នុងរបបខ្មែរក្រហម

នេះគឺជាការរៀបរាប់ទាំងទឹកមុខក្រៀមក្រំរបស់បងប្រុស សួន ស៊ិន នៅភូមិជ្រៃគ្នោត ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ។ ថ្វីដ្បិតតែភាពសោកសៅនេះបានកន្លងផុតទៅ៣០ឆ្នាំ ហើយក្តី ក៏រូបគាត់នៅតែនឹកស្រណោះអាឡោះអាល័យប្អូនសម្លាញ់ ទាំងពីរដែលបានស្លាប់បាត់បង់ជីវិតក្នុងសម័យខ្មែរក្រហមដែរ ។

ស៊ិន បាត់បង់ឪពុកម្តាយ និងប្អូនពីរនាក់ទៀតដោយភាពចាស់ជរានិងរោគផ្សេងៗ ។ ទុក្ខសោកបែបនេះហាក់ដូចជាធាប់រសាយ ក៏ប៉ុន្តែចំពោះប្អូនពីរនាក់ដែលត្រូវចាប់យកទៅសម្លាប់ក្នុងរបបខ្មែរក្រហម ក្នុងអារម្មណ៍របស់ ស៊ិន ចេះតែនឹកឃើញ និងស្រមៃថា តើគេធ្វើទារុណកម្មព្រៃផ្សៃរបៀបណា? តើត្រូវសម្លាប់តាមរបៀបណា? តើវាមានការភិតភ័យតក់ស្លុតយ៉ាងណា? ទុក្ខនេះខុសប្លែកពីមរណទុក្ខធម្មតា ។

មនុស្សស្លាប់បាត់អស់ពិតមែន ប៉ុន្តែ ស៊ិន និងប្អូនស្រីឈ្មោះ សួន ធួន ជាភរិយាជនរងគ្រោះ និងកូនស្រីទាំងពីរ បានលាក់រូបថត បានរហូតមកដល់សព្វថ្ងៃ ។

ក្រោយពីរបបខ្មែរក្រហមរលំរលាយ សេរីភាពខាងជំនឿសាសនាបានកើតមានឡើងវិញ ។ យើងបានរៀបចំធ្វើបុណ្យអភិសេក ឧទ្ទិសបុញ្ញកុសលជូនដល់ដួងព្រលឹងនៃបុព្វការីជនរបស់យើង និងបានយករូបថតដង្ហែប្រទក្សិណដាក់តាំងក្នុងសាលាបុណ្យ ។ នេះជាវិធីតែមួយគត់ដើម្បីកាត់បន្ថយទុកក្រៀមក្រំសមតាមទំហំនៃការសោកស្តាយ ។

ដើម្បីថែរក្សាប្រវត្តិសាស្រ្តមហាខ្លោចផ្សានៃប្រជាជនកម្ពុជា រួមជាមួយបងប្អូនពីរលាននាក់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យកុំឲ្យបាត់បង់ យើងខ្ញុំសូមផ្តល់រូបថតមកមជ្ឈមណ្ឌលឯកសារកម្ពុជានិងជីវប្រវត្តិគ្រួសាររងគ្រោះមួយក្នុងចំណោមជនរងគ្រោះជិតពីរលាននាក់ ដើម្បីឲ្យមជ្ឈមណ្ឌលថែរក្សាទុកជាឯកសារភ័ស្តុតាង និងដើម្បីចុះផ្សាយក្នុងទំព័រទស្សនាវដ្តីស្វែងរកការពិតផង ។ នេះជាដំណើររឿងរបស់គ្រួសាររបស់ ស៊ិន ដែលមានជាហូរហែដូចតទៅ ៖

លោក អ៊ិន សួត មានស្រុកកំណើតនៅភូមិជ្រៃគ្នោត ឃុំត្រាំកក់ ស្រុកត្រាំកក់ (១០៥) ខេត្តតាកែវ (តំបន់១៣) មានប្រពន្ធ ឈ្មោះ សេង យ៉ាង មានស្រុកកំណើតនៅភូមិត្រពាំងធំ ឃុំនាម ស្រុកទ្រាំង (១០៧) ខេត្តតាកែវ ស្លាប់នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ។ គ្រួសារនេះមានកូនប្រាំនាក់ ប្រុស៤ ស្រី១ ៖ ១) សួន ស៊ិន (ប្រុស) កើតឆ្នាំ១៩៤០ ២) សួន សំអុល (ប្រុស) កើតឆ្នាំ១៩៤៥ ៣) សួន ធួន (ស្រី) កើតឆ្នាំ១៩៥៤ ៤) សួន សំអឿន (ប្រុស) កើតឆ្នាំ១៩៥៧ ៥) សួន ច័ន្ទ (ប្រុស) កើតឆ្នាំ១៩៦១ ហើយកូនទាំងអស់កើតនៅភូមិត្រពាំងធំ ឃុំនាម ស្រុកទ្រាំង ខេត្តតាកែវ ។

១) បងស៊ិន ៖ កាលនៅវ័យកុមារ ស៊ិន រៀននៅសាលាបឋមសិក្សាជាមួយព្រះសង្ឃនៅវត្តត្រពាំងធំ និងបួសនៅទីនោះ ។ ឆ្នាំ១៩៦៩ ស៊ិន ចូលធ្វើទាហានក្នុងកងយោធពលខេមរភូមិន្ទនៅបន្ទាយស្ទឹករាជធានីភ្នំពេញ ។ ក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ស៊ិន ផ្លាស់មកនៅបន្ទាយព្រៃសណ្តែកទីរួមស្រុកទ្រាំង ដែលមានលោក គឹម គូ ជាអភិបាលស្រុកថ្មី (អតីតគ្រូបង្រៀន) ។

សង្រ្គាមបានផ្ទុះឆេះពាសពេញផ្ទៃប្រទេស ការវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម យួនវៀតកុង និងទាហានលន់ នល់កាន់តែមានសភាពសាហាវនិងធ្ងន់ធ្ងរឡើងជារៀងរាល់ថ្ងៃ ។ ប្រជាជនដែលមានភូមិដ្ឋាននៅជុំវិញទីតាំងបន្ទាយទាហានគ្រប់ទិកន្លែង ក៏ដូចជាទីប្រជុំជននៅព្រៃសណ្តែកបាននាំគ្នារត់ភៀសខ្លួនចោលផ្ទះសម្បែង ភូមិឋាន ទ្រព្យសម្បត្តិទៅកាន់តំបន់ចុងកាត់មាត់ញក ។ កិច្ចការពារមាតុភូមិជាភារកិច្ចរបស់កងឈ្លប និងកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជាក្នុងសីលធម៌ខ្ពង់ខ្ពស់ធ្វើឲ្យប្រជាជនមានជំនឿទុកចិត្តនឹងមានភាពកក់ក្តៅក្នុងបទវិន័យខ្ពស់ខុសពីពលទាហានលោក លន់ នល់ ។

ប្រជាជនខ្មែរភាគច្រើនមានសមានចិត្តនិងភក្តីភាពចំពោះសម្តេចព្រះនរោត្តម សីហនុ ហើយមានកំហឹងឆាបឆេះចំពោះ

លោកសេនាប្រមុខ លន់ នល់ និងទ្រង់ សិរិមតៈ ដោយចាត់ទុកថា ជាជនក្បត់ជាតិ ដែលដាក់ប្រទេសឲ្យនៅក្រោមនឹមអាណានិគម ចក្រពត្តិអាមេរិក ។ អាណានិគមបារាំងបន្សល់ទុកកេរ្តិ៍អាស្រូវយ៉ាងច្រើនមហិមាក្នុងបេះដូងកូនខ្មែរ ដូច្នេះពាក្យថាអាណានិគមបានបំផុសឧត្តមគតិស្នេហាជាតិមាតុភូមិក្នុងមជ្ឈដ្ឋានប្រជាជនខ្មែរជាស្វ័យប្រវត្តិ ។ ម្យ៉ាងទៀតរបប លន់ នល់ បង្ខំឲ្យទិញអាវុធបង្កើតជាភូមិយុទ្ធសាស្ត្រស្វ័យការពារផងចាប់បង្ខំយុវជនយុវនារីឲ្យធ្វើទាហាន និងកងកុម្មង់ដូ និងបង្ខំឲ្យចាកចេញឲ្យឆ្ងាយពីសមរភូមិប្រយុទ្ធតាមពាក្យបុរាណពោលថា "កុំរាមុខដីង កុំទទឹងមុខសឹក" នេះជាមូលហេតុធ្វើឲ្យប្រជាជនត្រូវតែរត់ភៀសខ្លួន ។

តាសួត និង យាយយ៉ាង បានរត់មកជ្រកកោននៅភូមិជ្រៃត្នោត ឃុំត្រាកក់ដែលជាស្រុកកំណើតរបស់គាត់ ។ អ្នកខ្លះទៅនៅភូមិ ឃុំផ្សេងៗតាមរយៈបងប្អូនបុព្វញាតិមិត្តរៀងៗខ្លួន ។

នេះជាស្ថានការណ៍អំណោយផលផ្តល់ភាពងាយស្រួលមួយដល់ខ្មែរក្រហមនិងយួនយៀកកុងក្នុងនាមជាកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជាដែលមានសម្តេចនរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋ ហើយទ្រង់បានអំពាវនាវឲ្យប្រជារាស្ត្រជាកូនចៅនាំគ្នាក្រោកឡើងតស៊ូ ។

យួន-ខ្មែរក្រហមយកចិត្តទុកដាក់រៀបចំរដ្ឋអំណាចភូមិឃុំស្រុកតំបន់យ៉ាងឆាប់រហ័ស ។ បើកវគ្គរៀនសូត្រផង ធ្វើមិទ្ទីងឃោសនាអប់រំនយោបាយរណសិរ្សទាំងយប់ទាំងថ្ងៃ ជារួមផងជាបុគ្គលផង ។

សូម្បីតែយួនយៀកកុងក៏តាំងខ្លួនជាកងទ័ព សីហនុ ដែរ ដោយមានពាក់រូបសញ្ញាព្រះឆាយាលក្ខណ៍លើហោប៉ៅអាវរបស់ខ្លួនគ្រប់ៗគ្នា ។ កងទ័ពទាំងអស់ទទួលបាននូវការស្វាគមន៍ស្រឡាញ់រាប់អានពីសំណាក់ប្រជាជនគ្រប់គ្នា ។ យួនយៀកកុងមានអាវុធទំនើបជាងខ្មែរក្រហម ហើយអង់អាចក្លាហានក្នុងការប្រយុទ្ធជាងទាហានលន់ នល់ ។ ក៏ប៉ុន្តែពួកនេះមានរាងស្គមនិងមានសភាពស្លេកស្លាំងដោយសារស៊ីចុកមិនរើសអើង ។

គោលនយោបាយរណសិរ្សរួមផ្សំនឹងឆន្ទៈឧត្តមគតិដែលមានស្រាប់ យុវជនយុវនារីវ័យជំទង់នាំគ្នាសម្រុកចូលបម្រើរណសិរ្សរួបរួមជាតិកម្ពុជាយ៉ាងផុសផុលនិងគគ្រឹកគគ្រេង ។ ចាស់ៗនាំគ្នានិយាយថា ពេលនេះព្រ័ត្រ៩ធ្នុងចងមិនជាប់ គ្មានប្រាក់ខែ គ្មានឯកសណ្ឋានឲ្យតែមានអាវុធវាប្រសើរណាស់ទៅហើយ ។

ចំណែកទីប្រជុំជនព្រៃសណ្តែកជាទីរួមស្រុកទ្រាំងរបស់លោកអភិបាលស្រុក គឹម គូ បានក្លាយទៅជាដែនកោះឯកោមួយ ។ ភូមិឃុំជុំវិញនោះមានសភាពស្ងាត់ជ្រងំ មានតែកងឈ្លបកងទ័ពយាមការពារភូមិ ឃុំ របស់គេតាមឃ្លាំមើលចលនាស៊ើបការណ៍ពីសត្រូវ ។ ពេលនោះពួកខ្មែរក្រហមដែលដឹកនាំរណសិរ្សផ្ទាល់ បានបង្កើតទ្រឹស្តីមួយថា "មានប្រជាជនមានអ្វីៗទាំងអស់ កម្លាំងប្រជាជនជាប្រភពមិនចេះរីងស្ងួត" ។

បន្ទាប់ពីបានទទួលដំណឹងថា ឪពុកម្តាយបងប្អូនរត់ភៀសខ្លួនមកនៅភូមិជ្រៃត្នោតអស់ហើយ បងស៊ិន ឆ្លៀតឱកាសពេលចេញ ប្រតិបត្តិការនៅដើមឆ្នាំ១៩៧១ ក៏ទម្លាក់កាំភ្លើងចោលរត់មករួមរស់ជាមួយឪពុកម្តាយវិញ ហើយចូលរួមក្នុងចលនារណសិរ្សក្នុងអង្គភាពសិល្បៈដោយលាក់ប្រវត្តិមិនឲ្យនរណាដឹងថាគាត់ធ្លាប់ធ្វើទាហានឡើយ ។

២) សួន សំអុល ជាប្អូនប្រុសបន្ទាប់ ជាសិស្សរៀននៅវិទ្យាល័យព្រះខ័យ ក្រុងតាកែវ ។ ឆ្នាំ១៩៦៦ សំអុល ប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងប្រឡងចូលធ្វើទាហានរង ។



សួន សំអុល

ក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សំអុល រៀបការប្រពន្ធ ។ នាងជាកូនស្រីរបស់លោកវរសេនីយ៍ត្រីនិងជាមេបញ្ជាការ ហើយបានឡើងឋានៈជានាយទាហានខ្មែរក្រវាត់ការពារអាកាសយានដ្ឋានពោធិ៍ចិនតុងក្រោមកិច្ចបញ្ជាផ្ទាល់របស់ឧត្តមសេនីយ៍ សូ ខាំខូយ ។ ពេលនោះយន្តហោះ មកដឹកជញ្ជូនមន្ត្រីការទូតអាមេរិក សំអុល

ក៏បានឡើងយន្តហោះ ដែរ ប៉ុន្តែ សំអុល មិនដាច់ចិត្តចោលប្រពន្ធកូន ក៏លោតចុះមកដីវិញ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សំអុល កំពុងស្ថិតនៅពោធិ៍ចិនតុង ។ ពេលកងទ័ពខ្មែរក្រហមចូលមកដល់ សំអុល គ្មានឱកាសវិលត្រឡប់ទៅរកប្រពន្ធកូនដូចពេលមុនឡើយ ។ គាត់ត្រូវចាកចេញពីទីក្រុងតាមបញ្ជាដាច់ខាតរបស់កងទ័ពខ្មែរក្រហម ។ សំអុល ធ្វើដំណើរម្នាក់ឯងតាមផ្លូវជាតិលេខ៣ ។ សំអុល នៅសល់ក្ដីសង្ឃឹមតែមួយគត់ គឺរួចពីក្ដីបារម្ភ ការភ័យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួនផង ។

ពេលមកដល់ភូមិជ្រៃគ្រោត តើ សំអុល នឹងបានជួបមុខឪពុកម្ដាយដែរឬទេ?

មកដល់ភូមិជ្រៃគ្រោត សំអុល ខកចិត្តម្ដងទៀត ព្រោះមិនបានជួបមុខឪពុកម្ដាយដូចក្ដីប្រាថ្នា ។ សំអុល បានជួបតែបងប្អូនសាច់ញាតិនិងប្អូនស្រី សួន ធួន និងស្វាមីព្រមទាំងក្មួយៗដែលទើបតែចេញពីទីក្រុងទៅដូចគ្នា ។ ចំណែក តាសួត និងយាយយ៉ាងបានវិលត្រឡប់ទៅរស់នៅភូមិកំណើតនៅភូមិត្រពាំងធំ ឃុំរនាមវិញ តាំងពីពេលដែលកងទ័ពរណសិរ្សដណ្ដើមយកបានផ្សារព្រៃសណ្ដែក និងស្រុកទ្រាំងទាំងមូលតាំងពីឆ្នាំ១៩៧៤ ម្ល៉េះ ។ ប៉ុន្តែគាត់ ទាំងពីរក៏បានស្គាត់មកជួបកូនចៅទាំងក្ដីនឹករលឹក និងក្ដីព្រួយបារម្ភនៅភូមិជ្រៃគ្រោតដែរ ក្រោយពីដឹងថាកូននិងចៅៗរបស់គាត់ទៅដល់ទីនោះ ។

នេះជាជោគជ័យនៃថ្ងៃ១៧ មេសា ១៩៧៥ ជាការបញ្ចប់សង្គ្រាមបង្ហូរឈាមរយៈពេល៥ឆ្នាំ ដែលស័ក្ដិសមសម្រាប់ប្រជាជនកម្ពុជាមានមោទនភាពរីករាយសប្បាយនឹងទទួលបាននូវសន្តិភាព ។ ផ្ទុយទៅវិញ ស្នាមញញឹមក្លាយជាទឹកភ្នែកនិងទឹកមុខស្រពាប់ស្រពោនស្ទើរតែគ្រប់គ្នា ។ មានមនុស្សតិចណាស់ដែលគ្មានសាច់ញាតិបងប្អូនជាប្រជាជន១៧មេសា ។

សំខាន់ជាងនេះទៀតគឺជំហានមហាលោតផ្លោះ មហាអស្ចារ្យនៃមហាចលនាបដិវត្តន៍វប្បធម៌ វណ្ណៈអធន ត្រូវបានយកមកអនុវត្តបន្ទាប់ពីថ្ងៃជ័យជម្នះនេះនៅទូទាំងប្រទេស ។ នេះជាស្ពានយោលដ៏តូចមួយសម្រាប់ឆ្លងកាត់អន្លង់ជ្រោះមរណៈដ៏សែនគ្រោះថ្នាក់ ។ ប្រជាជនរាប់លាននាក់បានធ្លាក់ចូលក្នុងអន្លង់នេះ ។ យុទ្ធជនយុទ្ធនារីជាច្រើន ខ្លះត្រូវរបួសសុសសាច់ ខ្លះពិការក៏ទទួលបានរង្វាន់ជាទីគាប់ចិត្តគឺ សម្រិតសម្រាំង ដាក់ក្នុងដំរីកែប្រែលត់ដំ និងសម្លាប់រង្គាល ។ រីឯសម្ដេចព្រះនរោត្តម សីហនុ ព្រះប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ខ្មែរក្រហមបានថ្វាយព្រះបរមរាជវាំងឲ្យព្រះអង្គគង់នៅដោយមិនមានសេរីភាពយាងចេញពីទីនេះបានឡើយបើគ្មានការអនុញ្ញាត ។ ទាំងក្នុងពេលសង្គ្រាម និងពេលបញ្ចប់សង្គ្រាម ទាំងព្រះអង្គ ទាំងយុទ្ធជនយុទ្ធនារីជាកូនចៅមិនដែលបានយល់មុខគ្នាទេ ។

យាយយ៉ាង មានសាច់ញាតិធ្វើជាគណៈឃុំរនាម ។ យាយទទួលបានការអនុញ្ញាតឲ្យមកយកកូនចៅទៅរស់នៅជួបជុំគ្នានៅស្រុកកំណើតវិញនៅចុងឆ្នាំ១៩៧៥ ។ គាត់យល់ឃើញថាទីនោះហាក់ផ្ដល់ក្ដីសង្ឃឹមនិងមានភាពកក់ក្ដៅប្រសើរជាងនេះ ។ ការជួបជុំគ្រួសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានន័យថា បានរស់នៅក្នុងឃុំជាមួយគ្នា ពុំមែនរស់នៅក្រោមដំបូលផ្ទះជាមួយគ្នា ឬទទួលទានបាយជាមួយគ្នារាល់ព្រឹករាល់ល្ងាចនោះទេ ។ មនុស្សជំនាន់ក្រោយដែលពុំបានឆ្លងកាត់របបនេះ មិនងាយនឹងយល់ពីទំហំនៃការពិតដូចមនុស្សដែលបានហែលឆ្លងមហាសមុទ្រទុក្ខនេះឡើយ ។

អង្គការជាអ្នកគាត់តែងជោគវាសនាមនុស្សក្នុងរបបបញ្ញានិងវិន័យយ៉ាងតឹងរ៉ឹងបំផុត ។ មាគ៌ានិងគោលនយោបាយចង្អុលទិសដៅឲ្យយើងធ្វើដំណើរ ។ មនុស្សរស់នៅរបៀបជាកងទ័ព ឪពុកម្ដាយ ប្ដីប្រពន្ធ កូន រស់នៅក្នុងក្រុមរបស់ខ្លួនមានកងយុវជន យុវនារី កងពូ កងមីង កងកុមារ កងស្ត្រីមេម៉ាយ ។ល។ ការស្នាក់នៅ ការហូបចុក និងការធ្វើការងារពលកម្មគឺស្ថិតក្រោមកិច្ចដឹកនាំរបស់ប្រធានកង ។

ពេលវេលាជួបមុខប្រពន្ធកូនមានតែថ្ងៃ១០ ថ្ងៃ២០ នៃខែនីមួយៗ ឬមានការអនុញ្ញាតពីប្រធានកង ។ ឆ្នាំ១៩៧៨ មានប្រារព្ធពិធីមិទ្ទីងជាទូទៅមួយ ។ ពេលនោះតំណាងអង្គការបានប្រកាសលុបចោលការបែងចែកប្រជាជនជាបីប្រភេទមាន ÷ ប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម និងប្រជាជនថ្មី ។ សំឡេងហ៊ោកញ្ជ្រៀវបានលាន់ឮកងរំពងក្នុងបរិវេណមិទ្ទីង ។ នេះជាសញ្ញាប្រាប់ថា មនុស្សរាល់រូបត្រូវការសមភាពខាងឋានៈមុខមាត់

កិត្តិយស និងអ្វីៗទាំងអស់ ។ ខ្មែរក្រហមខ្លួនឯងខិតខំតស៊ូធ្វើបដិវត្តន៍ក្នុងបុព្វហេតុតាមតារឲ្យមានសមភាពនៅក្នុងសង្គម ពួកគេមិនគួរបំភ្លេចបញ្ហានេះឡើយ ។ ប៉ុន្តែកំណែទម្រង់បែបនេះ ហាក់ដូចជាយឺតពេលណាស់ទៅហើយ ។ ទស្សនៈឆ្វេងនិយមបានជិតជាមក្នុងសតិអារម្មណ៍កម្មាភិបាលជ្រុលនិយមមួយចំនួនមិនងាយកែតម្រង់បានឡើយ ក៏ដូចជាជនឱកាសនិយមថែមទៀត ហើយក៏គ្មានទិដ្ឋភាពអ្វីប្លែកសម្រាប់ប្រជាជនជាទូទៅដែរ គេត្រូវការកំណែទម្រង់ច្រើនជាងនេះ ដែលគេអាចទទួលយកបាន ។

សំអុល ត្រូវបានចាប់ខ្លួន១០ថ្ងៃមុនសេចក្តីប្រកាសខាងលើនេះពីក្នុងកងរបស់គាត់ ដែលបោះជំរំនៅវត្តកំពង់ស្វែង ទិសអាគ្នេយ៍ចម្ងាយ៤គីឡូម៉ែត្រពីក្រុងតាកែវ ។ ពេលនោះវត្តដើងចាបជាគុកដ៏ធំមួយរបស់ស្រុកទ្រាំង (១០៧) សំអុល ត្រូវបាននាំខ្លួនបញ្ជូនទៅកាន់ទីនោះ ។ នេះជាវគ្គចុងបញ្ចប់នៃជីវិតរបស់ សំអុល និងជាការព្រាត់ប្រាសជារៀងរហូតមួយក្នុងវ័យ៤២ឆ្នាំ ។ បងស៊ិន មានប្រសាសន៍ទាំងស្រងូតស្រងាត់ថា ៖ ពួកយើងអាចឆ្លងកាត់ភ្នក់ភ្លើងសង្គ្រាមរយៈពេល៥ឆ្នាំ ដោយសុវត្ថិភាព ប៉ុន្តែយើងមិនអាចឆ្លងផុតពីវាលពិឃាតអន្លង់មរណៈបានឡើយ ។ ប្អូនសម្លាញ់ទាំងពីរនាក់បានរអិលធ្លាក់ក្នុងអន្លង់មរណៈក្នុងពេលតែមួយ ។


សូ ស៊ីម

៣) ប្អូនស្រីឈ្មោះ សួន ធួន បច្ចុប្បន្នជាកសិករនៅភូមិជ្រៃគ្រោត ។ ធួន រៀបការនៅឆ្នាំ១៩៦៨ ។ ប្តីឈ្មោះ សូ ស៊ីម ជាកូនរបស់តា សូ គុំ និងយាយ សិត កសិករនៅភូមិត្រពាំងធំ ឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ ។ ស៊ីម កើតនៅឆ្នាំ១៩៤៥ ជាសិស្សនៅវិទ្យាល័យព្រះឧទ័យក្រុងតាកែវ ។ ស៊ីម ប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ (DESPC) រួចប្រលងចូលធ្វើជាកងរាជតម្រួតក្នុងឆ្នាំ១៩៦៤ ។

រដ្ឋប្រហារស្របច្បាប់ទម្លាក់សម្តេចព្រះប្រមុខរដ្ឋនរោត្តម សីហនុ តាមរយៈស្ថាប័នសភារបស់លោក លន់ នល់, សិរិមតៈ និង ចេង ហេង បានកើតឡើងនាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ កងរាជតម្រួតដឹកនាំដោយលោក អ៊ុំ ម៉ាណូរិន្ទ ជាបងថ្លៃ សម្តេចសីហនុ ត្រូវបានរំសាយចោលទាំងស្រុង ។ នាយប៉ូលិស ពលប៉ូលិសត្រូវបានប្តូរមុខងារជាកងយោធាខេមរជាតិវិញ ។ ភារកិច្ចថែរក្សាសណ្តាប់ធ្នាប់សន្តិសុខសាធារណៈជាកាតព្វកិច្ចរបស់កងអាវុធហត្ថលើផ្ទៃប្រទេស ។ ពេលនោះ ស៊ីម ជានាយទាហានមួយរូបក្នុងអង្គភាពកងពលថ្មើរជើងលេខ១៣ (១៣ BI) របស់ទ្រង់ ចន្ទរង្សី នៅបន្ទាយច្បារមន ខេត្តកំពង់ស្ពឺ និងជាគណនេយ្យករបើកប្រាក់បៀវត្សរ៍ ឲ្យពលទាហានអង្គភាព ។

ក្រោយថ្ងៃ១៧មេសា ១៩៧៥ ស៊ីម និង នាងធួន ព្រមទាំងកូនស្រី២នាក់ ឈ្មោះ សូ សុខជា និង សូ សោលី បាននាំគ្នាមកនៅភូមិជ្រៃគ្រោត ជួបជុំជាមួយ បងសំអុល ដែលជម្លៀសមកពីភ្នំពេញដូចគ្នា ។ ស៊ីម ព្រមទាំងប្រពន្ធកូន ត្រូវម្តាយក្មេកនាំទៅរស់នៅភូមិត្រពាំងធំ ឃុំរនាម ជួបជុំឪពុកម្តាយបងប្អូននឹងជាស្រុកកំណើត ។ ស៊ីម ត្រូវបានពួកខ្មែរក្រហមនាំខ្លួនទៅរៀនសូត្រជាមួយនឹងបងថ្លៃឈ្មោះ សំអុល នៅទីកន្លែងនិងក្នុងថ្ងៃតែមួយ ។

សព្វថ្ងៃនៅតែប្អូនស្រីពីរនាក់មួយឈ្មោះ សូ សុន មានប្តីមករស់នៅឃុំជាងទង ស្រុកត្រាំកក់ និងម្នាក់ទៀតឈ្មោះ សូ ជ្រិន រស់នៅឯស្រុកកំណើត ។ ចំណែកកូនស្រីទាំងពីរនាក់របស់ ស៊ីម មានប្តីនិងមានកូនរស់នៅភូមិជ្រៃគ្រោតទាំងអស់គ្នា ។ សុខជា និង សោលី និយាយទាំងអួលដើមកថា គេនៅចំណាំបានថា ប៉ារបស់គេរូបរាងស្អាតបាត សង្ហានិងមានចរិតស្លូតបូត ឱបថើប បីពផ្អកទឹកឲ្យពេលគាត់ត្រឡប់មកពីធ្វើការម្តងៗ ។ រូបថតនេះជាដួងព្រលឹងរបស់ប៉ាដែលមកសណ្ឋិតនៅក្នុងអារម្មណ៍របស់កូនរាល់ថ្ងៃ ។ រូបកាយរបស់ប៉ាបានឃ្លាតឆ្ងាយពីកូនទាំងពីរជារៀងរហូត មានតែរូបថតនេះទេដែលនៅនៃបនិត្យនិងសម្លឹងមើលកូនរាល់ថ្ងៃ ។

៤) សួន សំអឿន ៖ ឆ្នាំសិក្សា១៩៦៧-៦៨ គេរៀននៅអនុវិទ្យាល័យព្រែកសណ្តែក ។ សំអឿន បោះបង់ចោលការសិក្សាដោយសាររដ្ឋប្រហាររបស់ឧត្តមសេនីយ៍ លន់ នល់ ។ ចាប់ពីពេលនោះមក ក៏កើតមានមហាបាតុកម្មរបស់ប្រជារាស្ត្រ ហើយលោក គឹម គូ បានបញ្ជាឲ្យពលទាហានបាញ់រះលើពួកបាតុករចេញពីរថពាសដែក ធ្វើឲ្យរបួសនិងស្លាប់ប្រជារាស្ត្រក្នុង

ថ្កុកឈាមឆ្អិនឆ្អៅ ។ យុវសិស្សត្រូវបង្ខំឲ្យធ្វើទាហាន ឬកេណ្ឌធ្វើកុម្មុំង់ដូ ។

មូលហេតុនេះហើយ ដែល សំអឿន សម្រេចចិត្តបោះបង់ចោលការសិក្សារត់គៀសខ្លួនមកជាមួយឪពុកម្តាយមករស់នៅភូមិជ្រៃឆ្មោតជាភូមិកំណើតរបស់ឪពុក ។

ឆ្នាំ១៩៧២ សំអឿន បានរៀបអាពាហ៍ពិពាហ៍ជាមួយនាង ឆេង ហឿន ជាកូនស្រីរបស់លោកតា អ៊ុយ ឆេង និងលោកយាយ ឈឹម ប៉ូ ។ ថ្ងៃរៀបការរបស់ សំអឿន ប៉ះចំថ្ងៃអពមង្គល ។ កងទ័ពរដ្ឋការយួនធីវគី (ង្វៀង វ៉ាន់ធីវ, ង្វៀន ការគី) បើកប្រតិបត្តិការសឹកដេញតាមយួនយៀកកុង របប លន់ នល់ ចូលលុកលុយក្នុងតំបន់រំដោះ ។

យុទ្ធនាការនេះមិនតម្រង់ទៅរកខ្មែរក្រហម (កងទ័ពរណសិរ្ស) ឬយួនយៀកកុងទេ គឺជាប្រតិបត្តិការឆក់ប្លន់ ចាប់រំលោភនារី ប្រមូលយកលុយកាក់ ជ្រូកមាន់ទា គោក្របី ចានឆ្នាំងនិងរតនវត្ថុផ្សេងៗដូចជាមាស ប្រាក់ សំរិទ្ធ និងស្ពាន់ ។ ពិសេសគ្រប់វត្តអារាមដែលសម្បូរដោយទ្រព្យសម្បត្តិដ៏មានតម្លៃ ។ នេះជាភាពល្ងង់ខ្លៅ អសមត្ថភាពរបស់ឥស្សរជននយោបាយខ្មែរយើង ចាញ់កលល្បិចជនបរទេសបណ្តាលឲ្យទឹកដីមាតុភូមិក្លាយទៅជាសមរភូមិឆេះសន្ធោសន្ធៅ ដែលភាគីបដិបក្ខវៀតណាម យកទឹកដីកម្ពុជាធ្វើជាទីលានប្រយុទ្ធបញ្ចៀសនូវមហាវិនាសកម្មសម្រាលភាពហិនហោចខ្ទេចខ្ទាំក្នុងប្រទេសរបស់ខ្លួន ។

អាពាហ៍ពិពាហ៍ សំអឿន និងនាង ឆេង ហឿន ពុំបានប្រព្រឹត្តទៅដោយរលូនឡើយ ។ ញាតិមិត្តបងប្អូន បានរត់គៀសខ្លួនបែកខ្ញែកគ្នាអស់ អ្វីៗប្រព្រឹត្តទៅទាំងសោះកក្រោះ ។ ប្រពៃណីកិច្ចត្រូវច្បិចយកចំណុចសំខាន់ៗមកអនុវត្ត នេះជាមង្គលការមួយដែលមានតែគ្រាប់កាំភ្លើងតូចធំនិងគ្រាប់បែកទម្លាក់ពីយន្តហោះ ប្រោះព្រំជំនួសទឹកមន្តផ្កាស្លាជូនពរដល់គូស្វាមីភរិយាថ្មី ។

ទោះបីទើបតែរៀបការរួចថ្មីថ្មោងក៏ដោយ សំអឿន បានស្ម័គ្រចិត្តចូលរួមក្នុងចលនារណសិរ្សរួបរួមជាតិកម្ពុជា ។ ប៉ុន្តែគណៈឃុំមិនអនុញ្ញាតឲ្យ សំអឿន ទៅសមរភូមិមុខឡើយ ហើយ សំអឿន ត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងមន្ទីរឃុំជាជំនួយការខាងសរសេរនិងធ្វើបញ្ជីផ្សេងៗតាមសមត្ថភាពដែលជាអនុធនសិស្ស ។

សំអឿន មិនអាចមានលទ្ធភាពចូលបក្ស ឬក្លាយទៅជាកម្មាភិបាលបក្ខជនបានទេ ពីព្រោះលក្ខន្តិកៈបក្សមានទ្វារតូចចង្អៀតមិនងាយជ្រៀតចូលបានឡើយសម្រាប់អ្នកដែលមានប្រវត្តិរូបមិនល្អ ហើយនេះជាលក្ខខណ្ឌមួយដែលអ្នកផងមិនបានដឹង ។

ក្រោយពេលដែល សំអុល និង ស៊ឹម បាត់ខ្លួន ក្រុមគ្រួសារយាយយ៉ាង បានធ្លាក់ចុះក្នុងសភាពដុនដាបប្រកបដោយគ្រោះភ័យ ។ បងស៊ិន, សំអឿន, នាងធួន និងច័ន្ទជាប្អូនពៅបានដឹងខ្លួនជាស្រេចថា ខ្លួនលែងជាមនុស្សល្អដែលបដិវត្តត្រូវការហើយ ។ គេត្រូវបេះសម្រួបខ្លួនដើម្បីជីវិតគង់វង្សកំដរសង្គម ។ ភាពអស់សង្ឃឹមបានយាយីរាល់ថ្ងៃ ប្រសិនបើធ្វេសប្រហែសគ្រោះថ្នាក់នឹងមកដល់មួយរំពេច អ្វីៗមិនមានឆ្គងនឹងអ្នកដឹកនាំអង្គភាពឡើយ អ្វីៗត្រូវធ្វើឲ្យគេពេញចិត្តដើម្បីទាក់ទាញការអាណិតអាសូរពីមេដឹកនាំ ទោះបីជាមិនស្របនឹងទស្សនៈផ្ទាល់ខ្លួនក៏ដោយ ។ នេះជាការប្រកាន់យកក្នុងកាលៈទេសៈដែលឆាកជីវិតជួបប្រទះមហាគ្រោះភយន្តរាយ ។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នាងហឿន ទើបតែឆ្លងទន្លេកូនទី៣ សំអឿន បានលើកប្រពន្ធដាក់លើរទេះគោរត់គៀសខ្លួនចេញពីការវាយប្រយុទ្ធគ្នាផងនិងការស្អប់ខ្ពើមកងទ័ពយួនកុម្មុយនិស្តឈ្លានពានផង ។ សំអឿន ទៅមុខលែងរួច ប្រពន្ធរបស់គេធ្លាក់ខ្លួនឈឺព្រោះទើបឆ្លងទន្លេ គេទ័លច្រកនៅតំបន់ភ្នំធំ ស្រុកជុំគិរី ខេត្តកំពត ។ កងទ័ពយួនបានវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងនៅត្រពាំងអណ្តើក បណ្តាលឲ្យស្លាប់នឹងរបួសប្រជាជនជាច្រើន ។

សំអឿន ក៏បត់រទេះត្រឡប់មកក្រោយវិញ ប៉ុន្មានខែក្រោយមកប្រពន្ធក៏ស្លាប់ចោល បន្សល់កូនកំព្រាបីនាក់និងម្តាយចាស់ជរា ។ វៀតណាមនិងរណសិរ្សសាមគ្គីសង្គ្រោះជាតិបានវាយរំលំរបបប្រល័យពូជសាសន៍ខ្មែរក្រហមមិនស្របនឹងទស្សនៈរបស់ សំអឿន ឡើយ ពីព្រោះសំអឿន គិតថានេះគ្រាន់តែជាការផ្លាស់ប្តូរតែកុង ឯរថយន្តនៅតែដដែល ហើយអ្វីដែលយកមិនបាននោះគឺមាតុភូមិកំពុងធ្លាក់ចូលទៅក្នុងយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិនដែលជាមហិច្ឆតាដ៏យូរលង់របស់យួនកុម្មុយនិស្ត ហូ ជីមិញ បានកំណត់ទុកលើជ្រោយឥណ្ឌូចិនតាំងពីសម័យអាណានិគមបារាំង

មកម៉្លេះ ។

ដោយស្មារតីនិងឆន្ទៈនិយម សំអឿន បានលបលួចចូលរួមតស៊ូជាសម្ងាត់នៅឆ្នាំ១៩៨២ ក្នុងចលនាសេរីកាមានឈ្មោះថា “ម៉ូលីណាកា” ។ មន្ត្រីរដ្ឋការនៃរបបថ្មីនេះជាច្រើនរូបក្នុងភូមិ ឃុំ និងស្រុកក៏លបលួចធ្វើសកម្មភាពប្រឆាំងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានេះដែរ ។ យួនបាននុះរើការចាត់តាំងនិងផ្លាស់ប្តូរសមាសភាពជាច្រើនលើកច្រើនសាន្ទវពួកដែលគេហៅថារដ្ឋអំណាចមុខពីរ” ។

ជំនាញការវៀតណាមត្រូវបានចាត់តាំងបញ្ចូលមកគ្រប់គ្រងក្នុងស្ថាប័នរដ្ឋទាំងអស់រហូតដល់ថ្នាក់មូលដ្ឋានភូមិឃុំ និងបណ្តេញទាំងប្រជាជនទាំងរដ្ឋអំណាចមុខពីរចេញពីមុខតំណែងឬចាប់ដាក់គុក ។ គុកគេពាត្រពាំងផ្ទុង និងគ្រប់ពន្ធនាគារស្រុក ខេត្ត ពេញប្រៀបទៅដោយអ្នកទោសនយោបាយមានបណ្តាញអតីតខ្មែរក្រហម ព្រលឹងខ្មែរ-ម៉ូលីណាកា ។ល ។ ដូច្នេះសត្រូវពិតប្រាកដរបស់យួន មិនមែនតែក្រុមខ្មែរក្រហម ប៉ុល ពត នោះទេ។ ក្រុមណាបក្សណាឲ្យតែប្រឆាំងនឹងនយោបាយសហព័ន្ធឥណ្ឌូចិនរបស់ អ៊ំហូត្រូវចាត់ទុកជាសត្រូវទាំងអស់ រួមទាំងសម្តេច ព្រះនរោត្តម សីហនុ និងសម្តេច សឺន សាន ផង ។

ជាំរំជាយដែនថៃ ជាមូលដ្ឋានបង្អែកនៃក្រុមអ្នកតស៊ូស្នេហាជាតិ ។ គេបានបង្កើតរដ្ឋាភិបាលត្រីភាគីនិងត្រូវបានទទួលស្គាល់ពីសហគមន៍អន្តរជាតិ ។ នេះជាសញ្ញានៃការបង្រួបបង្រួមកម្លាំងស្នេហាជាតិការពារឯករាជ្យភាព អធិបតេយ្យភាពជាតិកុំឲ្យមាតុភូមិក្លាយទៅជារដ្ឋមួយចំណុះសហព័ន្ធមានយួនកុម្មុយនិស្តជាមេដឹកនាំ ។

ទំនាក់ទំនងនៅតាមព្រំដែនមានការលំបាក ឧបសគ្គច្រើនអនេក គ្មានថវិកាជាសោហ៊ុយ គ្មានសេរីភាពក្នុងការធ្វើដំណើរ ក្រុមសាមគ្គីបង្កប់បង្កើនផលជាការចាត់តាំងមួយយ៉ាងណែនបំផុត ។ សមាជិកណាម្នាក់ទៅណាមកណា ឬធ្វើសកម្មភាពអ្វីកម្រនឹងស្គាត់កំបាំងពីត្រចៀកប្រធានក្រុមសាមគ្គីណាស់ ។

សំអឿន បានងាកមកកទំនាក់ទំនងជាមួយក្រុមតស៊ូអតីតខ្មែរក្រហមនៅជួរភ្នំដងរែកមៀលដែលជិតបំផុត និងមានភាពងាយស្រួលព្រោះមានបណ្តាញសម្ងាត់បណ្តាក់គ្នាដូចខ្សែ ។ ក្រុមនេះបានឃោសនាថា ការតស៊ូរបស់គេពេលនេះមានសំណូមពរត្រឹមកម្រិតមួយគឺរំដោះប្រទេសពីទំរុកញ្ញាះយួនតែប៉ុណ្ណោះ មិនមែនដើម្បីបង្កើតរបបកុម្មុយនិស្តដូចមុនឡើយ ។ នេះជាមាគ៌ាជាយុទ្ធសាស្ត្រថ្មី បើព្រមទទួលធ្វើខ្ញុំយួននោះ យើងមិនចាំបាច់ប្រឆាំងនឹងសហរដ្ឋអាមេរិកទេ យើងនាំគ្នាធ្វើខ្ញុំអាមេរិកវាប្រសើរ


ប័ណ្ណឃោសនារបស់ ខៀវ សំផន


ជាង ។ នេះជាមូលដ្ឋានដែលយើងបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីជាមួយសម្តេច សីហនុ, សម្តេច សឺន សាន ពីព្រោះថ្ងៃអនាគតយើង ពុំមានមនោគមវិជ្ជាអ្វីផ្សេងពីគ្នាទេ និងគ្មានការប្រជុំជីវភាពបក្សទេពីពេលនេះតទៅ ។ រីឯរបបគ្រប់គ្រងប្រទេសគឺជាសិទ្ធិរបស់ប្រជាជនមិនមែនជាសិទ្ធិអំណាចរបស់បក្សទៀតទេ ។

ប្រការនេះបានធ្វើឲ្យ សំអឿន ផ្លាស់ប្តូរចិត្តនិងមានទំនុកចិត្តឡើងវិញលើក្រុមតស៊ូខ្មែរក្រហម ព្រមទាំងចូលរួមយ៉ាងសកម្មទៀតផង ។ ពេលនោះ លោក ខៀវ សំផន ហាក់ចេញមុខធ្វើជាតួឯកជាថ្មីម្តងទៀត មានទាំងប័ណ្ណសមាជិកគាំទ្រចេញផ្សាយមកដល់ទីនេះ ។


លិខិតសំគាល់

ឈ្មោះ ...

... លោក ខៀវ សំផន ...

ឆ្នាំ ១៩៨៣ សំអឿន បានរៀបការជាមួយនារីម្នាក់ទៀតឈ្មោះ នាង អ៊ុច នៅឃុំរកា ស្រុកដូនកែវ ខេត្តតាកែវ ។ សំអឿន បានចាកចោលកូនកំព្រាទាំងបីឲ្យនៅជាមួយម្តាយក្មេកចាស់ជរា ។ ក្រៅពីមុខរបរធ្វើស្រែ សំអឿន ដើរចាក់មីក្រូតាមពិធីមង្គលការ ឬបុណ្យទានផ្សេងៗដើម្បីរកចំណូលសម្រាប់គ្រួសារផង និងជា

ឱកាស ដើរឌឺបខៀវចលនាអូសទាញជនទាំងឡាយដែលគេមានទំនុកចិត្តផង ។ នេះជាសកម្មភាពដែលផុសចេញពីឧត្តមគតិនិងឆន្ទៈរបស់គេផ្ទាល់តែម្តង ។

គ្រួសារថ្មីនេះប្រសូតបានកូនស្រីមួយឈ្មោះ មីរិទ្ធ ។ នៅទីនោះ សំអឿន ប្រាស្រ័យទាក់ទងអតីតមិត្តរួមថ្នាក់ម្នាក់យ៉ាងស្និតល្អួត ជានាយទាហានមួយរូបនៃអគ្គភាពយោធាខេត្តតាកែវមានឋានៈជាប្រធានភ័ស្តុភារ គ្រប់គ្រងឃ្លាំងអាវុធយុទ្ធភណ្ឌ ។ គេបានលួចបញ្ចោញនឹងផ្តល់ឲ្យក្រុមតស៊ូខ្មែរក្រហមមានគ្រាប់កាំភ្លើង គ្រាប់បែក គ្រាប់មីន ។ល ។ និងដាក់មីនតាមច្រកចេញចូលរបស់កងទ័ពយួននៅជិតវត្តឈើទាលនៅព្រៃលើចម្ងាយ៨គីឡូម៉ែត្រពីភូមិភាគនិរតី ក្រុងតាកែវ ។ មិត្តរបស់ សំអឿន ក៏ខំពង្រីកកម្លាំងក្នុងជួរកងទ័ព ប៉ុន្តែចៃដន្យធ្វើសកម្មភាពប៉ះចំភ្នាក់ងារចារកម្មរបស់យួនបង្កប់ ហើយក៏ត្រូវចាប់ខ្លួនតែម្តង ។ ការណ៍នេះក៏រាលដាលមកដល់ សំអឿន ទៀត ។

សំអឿន ទទួលរងទារុណកម្មយ៉ាងធ្ងន់ធ្ងរក្នុងពន្ធនាគារខេត្តតាកែវ ។ គេវាយរាប់រយរំពាត់ខ្សែតី ឆក់ខ្សែភ្លើង គេយកថង់ប្លាស្ទិករុំមុខឲ្យថប់ដង្ហើមនិងសន្លប់ជាច្រើនដង ប៉ុន្តែគេមិនឆ្លើយដាក់មិត្តរួមតស៊ូណាម្នាក់ឡើយ ។ ជំនាញការវៀតណាម និងកងនគរបាលអស់លទ្ធភាពចម្រាញ់យកចម្លើយពី សំអឿន។ បីខែក្រោយមក សំអឿន ក៏ត្រូវបញ្ជូនទៅពន្ធនាគារតេ៣រាជធានីភ្នំពេញ ។ សំអឿន ទទួលរងទារុណកម្មកាន់តែធ្ងន់ជាងនៅខេត្តទៅទៀត ។ ដងខ្លួនរបស់គេសុទ្ធតែស្លាកស្នាម រូបកាយស្គាំងស្គមនិងកើតកមរមាស់ពេញខ្លួន ។ យាយយ៉ាង និងយាយប៊ូ បងស៊ីននាងធួន យូរៗនាំគ្នាទៅមើលម្តង ហើយពេលទៅមើលម្តងៗលុះត្រាតែមានមាសសូកអ្នកយាមគុកទើបបានជួប ។

រយៈពេល៦ឆ្នាំក្នុងគុកតេ៣ ម្តាយនិងបងប្អូនប្រមូលមាសប្រាក់ស្ទើររលីងពីខ្លួន ហើយបើគ្មានការជួយឧបត្ថម្ភពីគ្រួសារទេសំអឿន ពិតជាស្លាប់ក្នុងពន្ធនាគារដូចអ្នកទោសឯទៀត ដែលកើតរោគហើមស្ពឹកមកពីកង្វះជីវជាតិអាហារនិងគ្មានពន្លឺថ្ងៃមិនខាន ។ ក្រុមគ្រួសាររបស់គេបានចំណាយមាសអស់៦តម្លឹង ដើម្បីជាថ្នូរដោះដូរឲ្យ សំអឿន មានសេរីភាពវិញ ។ បើពុំនោះទេ សំអឿន នឹងត្រូវបញ្ជូនទៅគុកត្រពាំងផ្លុងក្នុងខេត្តកំពង់ចាម ជាប់ជាអ្នកទោសអស់មួយជីវិត ។ នេះជាការផ្តន្ទាទោសមួយសម្រាប់ជនណាដែលមានគំនិតប្រឆាំងនឹងការឈ្លានពានរបស់វៀតណាម ។

ក្រោយពេលចេញពីពន្ធនាគារ សម្ព័ន្ធភាពប្តីប្រពន្ធរវាងសំអឿន និងនាង អ៊ូច មិនសូវផ្អែមដូចប្រក្រតីទេ ។ សំអឿន គិតថាភរិយាខ្លួនមិនមានភក្តីភាពក្នុងពេលដែលខ្លួនអវត្តមានរយៈពេលប៉ុន្មានឆ្នាំនេះ ។ សំអឿន ក៏ត្រឡប់មករស់នៅជាមួយម្តាយក្មេកនិងកូនកំព្រាទាំងបីនាក់វិញ ។


សូ ស៊ីម ជាមួយមិត្តភក្តិថតរូបនៅក្នុងជំនាន់ លន់ នល់

សហភាពសង្គមនិយមសូវៀតបានដួលរលំរដ្ឋបីក្នុងចំណោមរដ្ឋទាំង១៥បានប្រកាសឯករាជ្យ ។ កិច្ចការស្វែងរកដំណោះស្រាយនយោបាយរួមបញ្ចប់ជម្លោះរ៉ាំរ៉ៃកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ ហ្វ៊ុនស៊ិនប៉ិច ហ្វ៊ីម២ គូកូ ប៉ាត់តាយ៉ា ប៉ារីសបានឈានចូលមកដល់កិច្ចព្រមព្រៀងនិងត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ១៩៩១ ។ យូណាមិកមានវត្តមានដល់កម្ពុជា បន្ទាប់មក

អ៊ុនគាត់ ដើម្បីអនុវត្តកិច្ចព្រមព្រៀងខាងលើ ។

សំអឿន រង់ចាំឱកាសនេះយ៉ាងអន្ទះសា មិនបង្អង់គេលួចធ្វើដំណើរទៅកាន់ជំរំព្រំដែនជាប្រញាប់ ដើម្បីបានចូលរៀនសូត្រនយោបាយ នៅជំរំតាទុំក្នុងនាមជាសមាជិកនៃគណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច ។ ពេលត្រឡប់មកវិញ សំអឿន មកនៅទីស្នាក់ការលេខ៤៨រាជធានីភ្នំពេញ ។ កិច្ចព្រមព្រៀងនេះទាមទារឲ្យដោះលែងអ្នកទោសនយោបាយទាំងអស់ដោយគ្មានលក្ខខណ្ឌ ។ សំអឿន មកភ្នំពេញ ដើម្បីទាក់ទងបណ្តាញរបស់ខ្លួនចូលរួមជាមួយគណបក្ស ហ៊្វុនស៊ិនប៉ិច និងចលនាអូសទាញ ប្រមូលកម្លាំងគាំទ្របន្ថែមទៀត និងប្រមូលរូបថតធ្វើប័ណ្ណបញ្ចូលជាសមាជិកគណបក្ស ។ សំអឿន មានទម្លាប់ឆាប់ជឿទុកចិត្តគេឯង និងមានចរិតក្មេងខ្ចីខ្វះបទពិសោធន៍ខាងនយោបាយអូសទាញ ប៉ះចំភ្នាក់ងារសម្ងាត់បង្កប់ក្នុងជួរប្រជាជន ។ នេះជាការប្រឈមមុខប្រកបដោយគ្រោះថ្នាក់ធំធេងណាស់នាសម័យនោះ ។ ពេលនោះ គ្មានការចាប់មនុស្សដាក់គុកដោយមូលហេតុនយោបាយទេ ក៏ប៉ុន្តែគេបានបង្កើតក្រុមអត្តឃាតប្រដាប់ដោយអាវុធខ្លី ក្នុងឯកសណ្ឋានស៊ីវិល ជាការរាយអន្ទាក់សម្រាប់ចាប់សត្វបក្សាបក្សីម្រឹគីម្រឹគាទាំងឡាយ ដែលកំពុងស្វែងរកចំណីក្នុងរូបភាពជាក្រុមចោរប្លន់ប្រដាប់អាវុធបំភាន់មតិជាតិនិងមតិអន្តរជាតិ ។ នេះជាករណីប្រកបដោយគ្រោះថ្នាក់ដែល សំអឿន និងជនទូទៅមិនបានស្វែងយល់ទាល់តែសោះ ។


សូ ស៊ីម

ថ្ងៃមួយ សំអឿន បានចេញដំណើរ ទៅភូមិត្រពាំងធំឃុំរនាម ដើម្បីបំពេញកិច្ចការដោយមិនដឹងថាខ្លួនកំពុងឋិតនៅក្នុងគោលដៅមួយដែលក្រុមបិសាចតាមឃ្លាំមើលគ្រប់ជំហាន ។ ក្នុងឱកាសស្ងាត់កំបាំង ក្រុមនេះនឹងសម្លាប់យកម៉ូតូដែល សំអឿន កំពុងជិះ តែម្នាក់ឯង ។ សំណាងល្អ សំអឿន បានទៅដល់គោលដៅដោយសុវត្ថិភាព ។ យប់នោះ សំអឿន សម្រាកនៅផ្ទះបងប្អូន ។ រាត្រីយប់ជ្រៅពួកអន្យតិរ្ថិយ៍ លបចូលទៅចាប់ សំអឿន ប៉ុន្តែ សំអឿន ស្រែកផ្អើលគោឡោផ្អើលមនុស្សពេញភូមិ ។ ស្រាប់តែក្រុមនេះសុទ្ធតែសមត្ថកិច្ចនគរបាលក្នុងឯកសណ្ឋានស៊ីវិល ។ ពួកគេខកខានមិនហ៊ានធ្វើឃាត ប៉ុន្តែក្រុមនេះបានបញ្ជូន សំអឿន ទៅកាន់អធិការដ្ឋានស្រុកទ្រាំង និងចោទពីបទធ្វើនយោបាយខុសច្បាប់ ពីព្រោះមិនទាន់ដល់ពេលវេលាធ្វើការឃោសនាទេ ។ តាមពិតសកម្មភាពនេះ មិនមែនជាវេទិកាឃោសនាសំឡេងឆ្នោតទេ វាគ្រាន់តែជាលេសរបស់គេប៉ុណ្ណោះ ។

ក្នុងពេលជាប់ឃុំឃាំង សំអឿន ត្រូវបានសួរចម្លើយរកបណ្តាញខ្សែរយៈ និងគំរាមឲ្យបញ្ឈប់សកម្មភាព ។ ប៉ុន្មានថ្ងៃបន្ទាប់ សំអឿន ត្រូវបញ្ជូនមកខេត្ត និងបង្ខំឲ្យបងប្អូនផ្តិតមេដៃលើកិច្ចសន្យាទទួលទៅអប់រំណែនាំ ។ មកដល់ផ្ទះបានមួយខែ សំអឿន ក៏ លួចរត់ទៅស្នាក់នៅទីស្នាក់ការលេខ៤៨វិញ ។ ក្រោយពេលដែលគណបក្សហ៊្វុនស៊ិនប៉ិច បើកទីស្នាក់ការតាមបណ្តាខេត្ត សំអឿន ក៏បានមកនៅទីស្នាក់ការខេត្តតាកែវ ។

ក្រោយពេលបោះឆ្នោតសកលឆ្នាំ ១៩៩៣ សំអឿន ក្លាយទៅជានគរបាល នៅស្នងការនគរបាលខេត្ត ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៨ សំអឿន ត្រូវបានក្រសួង ផ្លាស់ទៅក្រុងព្រះសីហនុ ។ សំអឿន មានឋានន្តរស័ក្តិថ្នាក់វរសេនីយ៍ត្រីនៃកងកម្លាំងនគរបាលជាតិនៅស្នងការដ្ឋាននគរបាលក្រុង ។

សំអឿន ទទួលបានសុភមង្គលល្អណាស់ក្នុងសង្គមគ្រួសារថ្មីនេះ និងកូនស្រីមួយជាត្រួយបណ្តូលចិត្តផង ។ ថ្វីបើ សំអឿន ជាបុរសពោះម៉ាយនិងភរិយាជាស្ត្រីមេម៉ាយក៏ដោយ ។ សំអឿន មានលំនៅដ្ឋានមានសម្បត្តិទ្រព្យសមរម្យ ក្នុងជីវភាពជាអ្នកទីក្រុង ប៉ុន្តែ សំអឿន ទៅធ្វើការនៅក្រុងកំពង់សោមតែម្នាក់ឯង ។ ភរិយារបស់ខ្លួនជាប់ដៃក្នុងមុខរបរចិញ្ចឹមជីវិតថែរក្សាផ្ទះសម្បែង

និងម្តាយចាស់ជរាផង ។

ក្រៅពីការងាររបម្រើរាជការបម្រើប្រជាពលរដ្ឋ សំអឿន បានបបួលមិត្តភក្តិស្មុះស្មែងរកទិញដីឡូត៍បានមួយចំនួន នេះជាមុខរបរមួយដែលកាក់កបនាសម័យបច្ចុប្បន្ន ។ មិនយូរប៉ុន្មានហាងឆេងដីធ្លីនៅទីក្រុងមានតម្លៃខ្ពស់ពួកគេបបួលគ្នាលក់ដីនោះ ។ ពេលទទួលបានប្រាក់កក់ សំអឿន បាននាំគ្នាជប់លៀងសប្បាយនៅក្នុងភោជនីយដ្ឋានមួយ ។ ស្អែកឡើង មានព័ត៌មានដ៏សែនក្រៀមក្រំបំផុតតាមប្រព័ន្ធទូរស័ព្ទថា សំអឿន បានស្លាប់ក្នុងផ្ទះតែម្នាក់ឯងគ្មានរណាម្នាក់ដឹងអំពីមូលហេតុនេះសោះ ។ មរណភាពរបស់ សំអឿន បានបន្សល់ទុកនូវក្តីមន្ទិលសង្ស័យឲ្យប្រពន្ធនិងកូនជាទីស្រឡាញ់ ។ ប្រពន្ធកូនរបស់ សំអឿន បានដឹកសាកសពមកធ្វើបុណ្យនៅភូមិជ្រៃគ្មោត និងបញ្ចុះសពក្នុងដីភូមិរបស់ខ្លួន ។

មនុស្សក៏ស្លាប់ ទ្រព្យក៏បង់ ដូចពាក្យពីបូរាណពោលថា "ប្រាក់ក៏បង់ ព្រោះថង់វាដាច" ។ ក្រុមគ្រួសាររបស់ សំអឿន បានរុករកឯកសារក្រែងប្រទះឃើញមានលិខិតស្នាមណាមួយអាចជាភស្តុតាងតាមផ្លូវច្បាប់ក្នុងការទាមទារចំណែកប្រាក់កាសខ្លះសម្រាប់ប្រពន្ធនិងកូន ក៏ប៉ុន្តែការស្មុះស្មែងជាការឥតប្រយោជន៍ ពីព្រោះគេពុំអាចរកឃើញឯកសារណាមួយសោះ ។

នេះជាខ្សែជីវិតបត់បែននៃកូនប្រុសទី៤របស់យាយនិងបងសិន ។ យាយ យ៉ាង ក៏ ចាប់ផ្តើមធ្លាក់ខ្លួនឈឺដោយជំងឺចាស់ជរាហើយក៏បានធ្វើមរណកាលប៉ុន្មានខែក្រោយបន្ទាប់ពី សំអឿន ។ ចំណែកនាងជាភរិយាវិញបានស្គាល់រសជាតិជាស្ត្រីមេម៉ាយដល់ទៅពីរលើកក្នុងមួយជីវិត ។ ស្វាមីទី១របស់នាងស្លាប់ក្នុងសម័យខ្មែរក្រហម ។ រៀងរាល់ឆ្នាំរដូវភ្ជុំបិណ្ឌ ចូលឆ្នាំ ឬថ្ងៃចូលឆ្នាំចិន (មាឃ) នាងតែងទិញនំចំណីមកសែនផ្លូវខុសទិសដល់ស្វាមីរបស់នាងមិនដែលអាក់ខានឡើយ ។

៥) ប្អូនប្រុសពៅឈ្មោះ ច័ន្ទ គ្រាន់តែធំដឹងក្តីសង្គ្រាមក៏ឆេះសន្ធោសន្ធៅព្រមគ្នាដែរ ។ ច័ន្ទ ស្ថិតនៅក្នុងកងយុវជនរហូត ។ ការដ្ឋានលើកទំនប់ដឹកប្រឡាយនិងបង្កបង្កើនផលជញ្ជូនគ្រាប់ទៅឲ្យកងទ័ពនិងសែងអ្នករបួស សាកសពយុទ្ធជនពលីមកសមរភូមិក្រោយ តាមខ្លឹមសារនៃមាគ៌ាសង្គ្រាមប្រជាជនរបស់អង្គការគឺប្រជាជនទាំងអស់ត្រូវចូលរួមបំពេញភារកិច្ចទាំងសមរភូមិមុខនិងសមរភូមិក្រោយ និងទំនុកបម្រុងស្បៀង អាហារផ្គត់ផ្គង់ឲ្យកងទ័ព (បាយស្ទូក) យាមកាមកាត់ផ្លូវដឹកជញ្ជូនរបស់ខ្មាំង ។ល ។ នេះហៅថាសង្គ្រាមប្រជាជនបើកវគ្គអប់រំប្រជុំរៀនសូត្រមិទ្ទីងឲ្យយល់ជ្រួតជ្រាបទាំងអស់គ្នា ។

ឆ្នាំ១៩៨៣ ច័ន្ទ បានរៀបការជា មួយនាង ទាង ជាកូនក្រមុំអ្នកភូមិជ្រៃគ្មោតជាមួយគ្នា មានមុខរបរជាកសិករមានជីវភាពរស់នៅមធ្យម ។ ពេលភរិយារបស់ សំអឿន មកលេងស្រុកម្តងៗ គាត់តែងមកស្នាក់អាស្រ័យនៅផ្ទះរបស់ប្អូន ច័ន្ទ ។ នៅឆ្នាំ២០០៤ ច័ន្ទ ធ្លាក់ខ្លួនឈឺ ។ តែបី-បួនថ្ងៃ ប៉ុណ្ណោះ ច័ន្ទ ធ្វើមរណភាពទាំងវ័យក្មេង ។

អត្ថបទស្តីពីប្រវត្តិនិងទុក្ខវេទនារបស់គ្រួសារយាយយ៉ាង និងរូបថតទាំងនេះ គឺជាប្រវត្តិនៃគ្រួសាររងគ្រោះយ៉ាងសែនអាណោចអាធ័មមួយជាមួយប្រជាជនជិតពីរលាននាក់ ដែលមិនត្រូវឲ្យបាត់បង់ឡើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក្រោមកិច្ចដឹកនាំរបស់លោកនាយក ឆាំង យុ ព្រមទាំងសហការីបានផ្តល់នូវជំនឿយ៉ាងមុតមាំក្នុងការប្រមូលចងក្រងរក្សាទុកនូវឯកសារដ៏មានតម្លៃ ជាប្រវត្តិសាស្ត្រនេះសម្រាប់សង្គមមនុស្សជំនាន់នេះ និងជំនាន់ក្រោយទៀតបានរៀនសូត្រពីយុគសម័យដ៏ខ្មៅងងឹតនេះ ។

នេះជាវត្ថុបំណងរបស់យើងខ្ញុំ គ្មានអ្វីផ្សេងពីនេះទេ ហេតុនេះសូមលោកនាយកទទួលនូវការគោរពរាប់អានអំពីយើងខ្ញុំ ។ សូមអរគុណ ។

**អៀប ឌុច**

## ពាក្យស្លោកខ្មែរក្រហម

- **បើមិនមានគោលជំហរ ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនធ្វើម្ចាស់ខ្លួនឯង ការតស៊ូបដិវត្តន៍តែងតែជួបបរាជ័យ នេះគឺមិនមែនគ្រាន់តែក្នុងករណី គ្មានបក្សដឹកនាំចលនាតស៊ូបដិវត្តន៍របស់ប្រជាជនប៉ុណ្ណោះទេ។**

*(សៀវភៅកំណត់ហេតុលេខ០ ៧/៧)*

# សេចក្តីប្រកាសរកបងប្អូន៨នាក់

នាងខ្ញុំឈ្មោះ ផាច់ សាលី អាយុ៥៧ឆ្នាំ មានស្រុកកំណើតនៅសង្កាត់គីឡូម៉ែត្រលេខ៦ ភូមិស្ពានខ្ពស់ ខណ្ឌឬស្សីកែវ សព្វថ្ងៃរស់នៅទីក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ផាច់ ឃៀច ជាអតីតទាហានសម័យសម្តេចឪ និងម្តាយឈ្មោះ លី ធីវ៉ាន់ ។ នាងខ្ញុំសូមសួររកបងប្អូន ប្រុសស្រីចំនួន៨នាក់ ដែលបែកគ្នាតាំងពីសម័យ ប៉ុល ពត ដែលមានឈ្មោះដូចជា ៖ ១) បងប្រុស ផាច់ មឿង ២) បងស្រី ផាច់ សារីម ៣) បងស្រី ផាច់ សារឿន ៤) ប្អូនប្រុស ផាច់ មារឌី ៥) ប្អូនប្រុស ផាច់ ទ្រី ៦) ប្អូនប្រុស ផាច់ សុខា ៧) ប្អូនប្រុស ផាច់ សំអុល និង៨) ប្អូនប្រុស ផាច់ ពៅ ។

ប្រសិនបើបង-ប្អូនៗបានឃើញប្រកាសនេះ ឬញាតិមិត្តណាបានស្គាល់ឈ្មោះខាងលើសូមទាក់ទងមក ឈ្មោះ លឹម ហុក ទូរស័ព្ទ លេខ ០១២ ៣០៩ ៩០៥ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទូរស័ព្ទលេខ ៨៥៥ ០២៣ ២១១ ៨៧៥ ឬប្រអប់សំបុត្រ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកឪពុកនិងប្អូនស្រី

នាងខ្ញុំឈ្មោះ កាន់ បូរីនីន សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិកជាមួយម្តាយឈ្មោះ ឈុន បូរីន និងប្អូនស្រី៣នាក់ឈ្មោះ ១) កាន់ បូរីយ៉ាន ២) កាន់ ស្រីនូត និងទី៣) កាន់ ស្រីពៅ សូមសួររកឪពុក កាន់ បូ និងប្អូនស្រី កាន់ បុប្ផាគន្ធា ហៅ ស្រីអូន ដែលទើបមានអាយុ៦-៧ឆ្នាំ បានបែកគ្នានៅខេត្តបាត់ដំបងក្នុងឆ្នាំ១៩៧៩ ។ រយៈពេលពីរខែមុនពេលកងទ័ពវៀតណាមចូលទីក្រុងភ្នំពេញ អ្នកទាំងពីរត្រូវខ្មែរក្រហមជម្លៀសទៅភ្នំធិបតីក្នុងខេត្តបាត់ដំបង ។ ក្រោយមកព្ទដំណឹងថាលោកឪពុកមានជំងឺឬសដូងបាតរហូតដល់ធ្លាក់ឈាមមិនដឹងរស់ឬស្លាប់ ចំណែកប្អូនស្រី បុប្ផាគន្ធា គិតតែអង្គុយយំនិងរត់រកឲ្យអ្នកជិតខាងជួយ តាំងពីនោះមកខ្ញុំក៏លែងទទួលដំណឹងពីអ្នកទាំងពីរទៀត ។ បើប្អូនស្រី ឬបងប្អូនណាបានព្ទនិងស្គាល់ឈ្មោះទាំងពីរនេះ សូមជួយផ្តល់ដំណឹងឲ្យនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រ ១១១០ ភ្នំពេញ ទូរស័ព្ទ លេខ ៨៥៥ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកឪពុកម្តាយនិងបងប្អូន៦នាក់

ខ្ញុំបាទឈ្មោះ ជា វណ្ណៈ ជាគ្រូបង្រៀននៅសាលាបឋមសិក្សារមូល ឃុំរអាង ស្រុកកំពង់សៀម ។ សព្វថ្ងៃខ្ញុំបាទរស់នៅភូមិអំពិល ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម សូមសួររកឪពុកនិងបងប្អូន៦នាក់ ទៀតដែលមានឈ្មោះដូចខាងក្រោមនេះ ÷

១) ឡាយ យូ អាយុប្រហែល៧៨ឆ្នាំ (ឪពុក) ២) ឡាយ ដី (ម្តាយ)៣) ឡាយ យូវ៉ាន់ឌី ៤) ឡាយ សុរិប្រាសិទ្ធិ ៥) ឡាយ មុន្នីធីរិទ្ធិ ៦) ឡាយ សុគន្ធា ៧) ឡាយ សុជាតា និង៨) ឡាយ សុភាព ។

មុនឆ្នាំ១៩៧០ ក្រុមគ្រួសារខ្ញុំបាទរស់នៅទីក្រុងភ្នំពេញ ។ ឪពុកជាអតីតទាហានជនាន់បារាំង ទាហាន ជនាន់សម្តេច និងទាហានលន់នល់ ។ នៅឆ្នាំ១៩៧៥ ឪពុកម្តាយនិងបងប្អូនទាំង៦នាក់របស់ខ្ញុំបានធ្វើដំណើរទៅខេត្តតាកែវ ក្នុងគោលបំណងត្រឡប់ទៅស្រុកកំណើតនៅកម្ពុជាក្រោមវិញ ប៉ុន្តែតាំងពីពេលនោះមកក៏បាត់ដំណឹងមិនដឹងថាអ្នកទាំងអស់នៅរស់ឬស្លាប់ឡើយ ។

បើបងប្អូនណាស្គាល់ឬដឹងដំណឹងពីឈ្មោះខាងលើសូមមេត្តាជួយផ្តល់ដំណឹងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រ ១១១០ ភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ដោយអនុគ្រោះ ។ សូមអរគុណ ។

# ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា











- ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ (តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម) ចាប់ដំណើរការ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៦
- ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ជារៀងរាល់ថ្ងៃអង្គារ៍ក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ នៅក្នុងឆ្នាំ២០០៦
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានទីតាំងនៅតាមផ្លូវជាតិលេខ៤ ភូមិអង្គ ឃុំកន្ធោក ស្រុកអង្គស្នួល ទំនាក់ទំនងជាមួយមន្ត្រីផ្នែកកិច្ចការសាធារណៈ ទូរស័ព្ទលេខ ០២៣ ២១៩ ៨១៤ ពត៌មានបន្ថែមសូមមើលគេហទំព័រ www.cambodia.gov.kh/krt ឬ www.eccc.gov.kh
- មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ វិថីព្រះសីហនុ (ខាងកើតវិមានឯករាជ្យ) ប្រអប់សំបុត្រ១១១០ ទំនាក់ទំនងជាមួយលោក ទ៊ាន់ថាន់ ពៅដារ៉ា ទូរស័ព្ទលេខ ០១២ ៨៤៦ ៥២៦ ពត៌មានបន្ថែម សូមមើលគេហទំព័រ www.dccam.org

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 80, August 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.